សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de droit et des Sciences Economoiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ស៊ីន លីនដា**
**ក. សុវណ្ណ បញ្ញា**

សាស្ត្រាចារ្យណែនាំ
លោក **ធឹង ស៊ីវៀង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស៊ីន លីនដា** និងឈ្មោះ **សុខណ្ណា បញ្ញា** ជានិស្សិតច្បាប់ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសរសេរសារណាក្រោមប្រធាបបទស្តីពី "**បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ**"។ យើងខ្ញុំគិតថានាពេលបច្ចុប្បន្ន សិទ្ធិបញ្ចេញមតិនៅកម្ពុជានៅមានកម្រិតនៅឡើយដែលជាហេតុ ធ្វើអោយកម្ពុជាមិនទាន់ឆ្លើយតបទៅនឹងលទ្ធិប្រជាធិបតេយ្យអោយបានល្អប្រសើរ និងពេញលេញនូវឡើយទេ។ ម្យ៉ាងទៀតការលើកឡើងពី បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិលើប្រព័ន្ធព្វផ្សាយ និងបញ្ហាប្រឈមទៅនិងបទដ្ឋានគតិយុទ្ធ។ វាជាការឆ្លុះបញ្ចាំងពីភាពខ្វះខាត និងការមិនគោរពតាមកាតព្វកិច្ចអោយបានគ្រប់ជ្រុងជ្រោយរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋខ្លួនអោយស្របតាមច្បាប់។ យើងខ្ញុំសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាវជ្រៅចំពោះអ្នកដែលបានផ្តល់កម្លាំងកាយចិត្ត និងអនុសាសន៍ ក៏ដូចជាការិះគន់មួយចំនួន ដែលធ្វើអោយយើងខ្ញុំសរសេរសារណានេះបានជោគជ័យដែលមានដូចជា៖

កូនសូមសម្តែងនូវសេចក្តីអំណរគុណ នូវគុណូបការៈដ៏ថ្លៃថ្លា និងមិនអាចកាត់ថ្លៃបានរបស់ **លោកឪពុក ពៅ ដា អ្នកម្តាយ កុយ សុន** និង**អ្នកម្តាយ អ៊ិត សុផានី** ដែលបានចញ្ចឹមបីបាច់ថែរក្សារូបកូនរហូតដល់ធំក្តី ខិតខំតស៊ូពុះពារ និងឆ្លងកាត់គ្រប់ឧបសគ្គ ដើម្បីអោយកូនបានសិក្សា និងមានចំណេះដឹងដូចសព្វថ្ងៃនេះ។ លើសពីនេះទៀត អ្នកមានគុណតែងទូន្មានរូបកូនអោយបានខិតខំប្រឹងប្រែងរៀនសូត្រ និងធ្វើជាមនុស្សល្អ ជាទំពាំងស្នង ឬស្សីរបស់ប្រទេសជាតិ ដើម្បីដឹកនាំប្រទេសអោយមានភាពរីកចម្រើន។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងយកអស់ពីសម្ថភាព និងលទ្ធភាពក្នុងការដឹកនាំគ្រប់គ្រងស្ថាប័នអោយបានដំណើរការទៅប្រកបដោយនិរន្តរភាព និងប្រសិទ្ធិភាពខ្ពស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យច្បាប់ ជាពិសេសគឺជម្រុញលើកទឹកចិត្ត និងអនុញ្ញាតអោយយើងខ្ញុំមានឱកាសក្នុងការសរសេរសារណា ដើម្បីជាប្រយោជន៍ក្នុងការបង្កើតចំណេះដឹងខ្លួនឯងផង ជាការចែករំលែក និងផ្សព្វផ្សាយចំណេះដឹង ដែលទាក់ទងទៅនឹងសិទ្ធិបញ្ចេញមតិនៅកម្ពុជានាពេលបច្ចុប្បន្ន។

**សាស្ត្រាចារ្យលោក នឹម ស៊ីនៀង** ជាសាស្ត្រចារ្យណែនាំក្នុងការសរសេរសារណានេះដែលលោកបានបង្ហាត់បង្ហាញ ក៏ដូចជាផ្តល់ដំបូន្មានក្នុងការជ្រើសរើសនូវប្រធានបទមួយដែលសមស្របទៅនឹងសមត្ថភាព និងសេចក្តីត្រូវការរបស់សង្គមកម្ពុជាបច្ចុប្បន្ន។ លោកសាស្ត្រចារ្យបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងណែនាំ និងកែតម្រូវទៅលើការសរសេរទាំងអក្ខរាវិរុទ្ធ និងខ្លឹមសារនៃសារណា ដើម្បីអោយអត្ថបទនេះមានន័យគ្រប់គ្រាន់ និងអាចក្លាយជាប្រភពនៃឯកសារដែលនិស្សិតដទៃទៀតអាចស្វែងរក និងធ្វើការិចារណាទៅលើសារ

ណានេះ។ លើសពីនេះទៅទៀតលោកគ្រូសាស្ត្រាចារ្យបានលើកទឹកចិត្តអោយយើងខ្ញុំខិតខំស្វែងរកនូវឯកសារ និងផ្តល់ជាមតិកែតម្រូវជាច្រើន ដើម្បីអោយយើងខ្ញុំមានកម្លាំងចិត្ត និងអាចសរសេរសារណានេះបានជោគជ័យ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០

**ក. ស៊ីន លីនដា ក. សុវណ្ណា បញ្ញា**

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**..........១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃសិទ្ធិបញ្ចេញមតិ**

**១.១. ប្រវត្តិនៃសិទ្ធិមនុស្ស**..........៣

**១.១.១. និយមន័យនៃសិទ្ធិបញ្ចេញមតិ**..........៣

**១.១.២. ទស្សនៈទានរបស់អ្នកប្រាជ្ញ**..........៤

១.១.២.១. ចន ឡុក ( John Locke )..........៤

១.១.២.២. តូម៉ាស ហាប់ ( Thomas Hobbes )..........៥

១.១.២.៣. ហ្សង់ ហ្សាក់រ៉ូសូ ( Jean-Jacques Rousseau )..........៥

១.១.២.៤. ម៉ុងតេស៊ីវ ( Montesquieu )..........៧

១.១.២.៥. ម៉ារីវ៉ាឡូស្តូន ( Mary Wollstonecraft )..........៨

**១.២. បទបញ្ញត្តិទូទៅស្តីពីសិទ្ធិបញ្ចេញមតិ**..........៨

**១.២.១. បទដ្ឋានគតិយុត្តិអន្តរជាតិ**..........៨

១.២.១.១. រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ..........៨

១.២.១.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស..........៩

១.២.១.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ..........៩

១.២.១.៤. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌..........១២

**១.២.២. បទដ្ឋានគតិយុត្តិជាតិ**..........១៣

១.២.២.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា..........១៤

១.២.២.២. ច្បាប់ស្តីពីរបបសារព័ត៌មាន..........១៥

១.២.២.៣. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី..........១៦

១.២.២.៤. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា..........១៧

១.២.២.៥. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន..........១៨

## ជំពូកទី ២

## បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ

**១.១. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី** ........................................ ២១

**១.១.១. ការរឹតបន្តឹងចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី** ........................................ ២១

១.១.១.១. សិទ្ធិទទួលបានព័ត៌មាន ........................................ ២២

ក. ទូរទស្សន៍ និងវិទ្យុ ........................................ ២២

ខ. កាសែត និងទស្សនាវដ្ដី ........................................ ២៣

គ. សិក្ខាសាលា ........................................ ២៣

១.១.១.២. សិទ្ធិស្វែងរកព័ត៌មាន ........................................ ២៤

ក. ទូរទស្សន៍ និងវិទ្យុ ........................................ ២៤

ខ. កាសែត និងទស្សនាវដ្ដី ........................................ ២៥

គ. សិក្ខាសាលា ........................................ ២៥

១.១.១.៣. សិទ្ធិផ្សព្វផ្សាយព័ត៌មាន ........................................ ២៥

ក. ទូរទស្សន៍ និងវិទ្យុ ........................................ ២៦

ខ. កាសែត និងទស្សនាវដ្ដី ........................................ ២៦

គ. សិក្ខាសាលា ........................................ ២៦

១.១.១.៤. ការរឹតបន្តឹងចំពោះសិទ្ធិបង្កើតសមាគមន៍ ........................................ ២៧

១.១.១.៥. ការរឹតបន្តឹងចំពោះសិទ្ធិការជួបប្រជុំជាសាធារណៈ ........................................ ២៨

**១.២. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបទំនើប** ........................................ ២៩

**១.២.១. ការរឹតបន្តឹងលើប្រព័ន្ធអ៊ីនធឺណេត** ........................................ ៣០

១.២.១.១. ទូរស័ព្ទដៃ ........................................ ៣១

១.២.១.២. គេហទិនានុលេខន៍ (ប្លុក) ........................................ ៣២

១.២.១.៣. ហ្វេសប៊ុក ........................................ ៣២

១.២.១.៤. ធ្វីតទ័រ ........................................ ៣៣

**១.៣. បញ្ហាប្រឈមទាក់ទងនឹងច្បាប់** ........................................ ៣៤

១.៣.១. ច្បាប់ថ្មីស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ........................................ ៣៤

១.៣.២. ច្បាប់ស្ដីពីសហជីព ........................................ ៣៧

១.៣.៣. ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ........................................ ៣៨

១.៣.៤. ច្បាប់ស្តីពីគណបក្សនយោបាយ...................................................................................៣៨
១.៣.៥. ច្បាប់ស្តីពីការអប់រំ.......................................................................................................៣៩
១.៣.៦. ច្បាប់ថ្មីស្តីពីទូរគមនាគមន៍.......................................................................................៤០
១.៣.៧. សេចក្តីព្រាងច្បាប់អំពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត.......................................................៤៣
១.៣.៨. ច្បាប់ថ្មីស្តីពីការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន...................................................៤៥

## ជំពូកទី ៣

## ដំណោះស្រាយបលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ

**១.១. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី** ...................................៤៩
**១.១.១. ការរឹតបន្តឹងចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី**.................................................៤៩
១.១.១.១. សិទ្ធិទទួលបានព័ត៌មាន.........................................................................៤៩
ក. ទូរទស្សន៍ និងវិទ្យុ...................................................................................៥០
ខ. កាសែត និងទស្សនាវដ្តី..............................................................................៥០
គ. សិក្ខាសាលា.............................................................................................៥០
១.១.១.២. សិទ្ធិស្វែងរកព័ត៌មាន...........................................................................៥០
ក. ទូរទស្សន៍ និងវិទ្យុ...................................................................................៥១
ខ. កាសែត និងទស្សនាវដ្តី..............................................................................៥១
គ. សិក្ខាសាលា.............................................................................................៥១
១.១.១.៣. សិទ្ធិផ្សព្វផ្សាយព័ត៌មាន.......................................................................៥២
ក. ទូរទស្សន៍ និងវិទ្យុ...................................................................................៥២
ខ. កាសែត និងទស្សនាវដ្តី..............................................................................៥២
គ. សិក្ខាសាលា.............................................................................................៥២
១.១.១.៤. ការរឹតបន្តឹងចំពោះសិទ្ធិបង្កើតសមាគមន៍...............................................៥៣
១.១.១.៥. ការរឹតបន្តឹងចំពោះសិទ្ធិការជួបប្រជុំជាសាធារណៈ.....................................៥៣
**១.២. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបទំនើប**.........................................៥៤
**១.២.១. ការរឹតបន្តឹងលើប្រព័ន្ធអ៊ីនធឺណេត**.............................................................................៥៤
១.២.១.១. ទូរស័ព្ទដៃ.........................................................................................៥៤
១.២.១.២. គេហទិនានុលេខន៍ (ប្លុក).....................................................................៥៥
១.២.១.៣. ហ្វេសប៊ុក...........................................................................................៥៥
១.២.១.៤. ធ្វីតទ័រ..............................................................................................៥៦

**១.៣ បញ្ហាប្រឈមទាក់ទងនឹងច្បាប់**......................................................................៥៦
១.៣.១. ច្បាប់ថ្មីស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល..........................................៥៦
១.៣.២. ច្បាប់ស្តីពីសហជីព..............................................................................................៥៨
១.៣.៣. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.................................................៥៩
១.៣.៤. ច្បាប់ស្តីពីគណបក្សនយោបាយ............................................................................៥៩
១.៣.៥. ច្បាប់ស្តីពីការអប់រំ ............................................................................................៥៩
១.៣.៦. ច្បាប់ថ្មីស្តីពីទូរគមនាគមន៍...................................................................................៦០
១.៣.៧. សេចក្តីព្រាងច្បាប់អំពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត..................................................៦១
១.៣.៨. ច្បាប់ថ្មីស្តីពីការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន............................................៦១
**សេចក្តីសន្និដ្ឋាន**..................................................................................................៦៤
**អនុសាសន៍**..........................................................................................................៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់ យើងខ្ញុំយល់ឃើញថាចំណេះដឹងផ្នែកច្បាប់មានសារៈសំខាន់ណាស់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជាមាគ៌ាសម្រាប់ប្រទេសឆ្ពោះទៅកាន់នីតិរដ្ឋ។ ប្រទេសកម្ពុជាកំពុងតែឈានទៅរកភាពរីកចម្រើនដោយបានប្រកាន់ខ្ជាប់នូវបទបញ្ញត្តិច្បាប់ និងការបង្កើតនូវច្បាប់ថ្មីៗ មួយចំនួនដើម្បីបំពេញតម្រូវការ ក៏ដូចជាដោះស្រាយនូវបញ្ហាដែលកើតមាននៅក្នុងសង្គមលិទ្ធិប្រជាធិបតេយ្យរបស់ខ្លួន។ ប៉ុន្តែទន្ទឹមនេះប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍន៍ដូចនេះ ការរំលោភបំពានលើសិទ្ធិមនុស្សតែងតែមានពីសំណាក់និយោជក ក្រុមហ៊ុនឯកជន អ្នកមានអំណាច និងមានទ្រព្យសម្បត្តិតែងតែមាន។ ហើយក្នុងការអភិវឌ្ឍន៍ខ្លួនឈានទៅរកនីតិរដ្ឋកម្ពុជា បានជួបប្រទះនូវបញ្ហាមួយចំនួនទាក់ទិនទៅនឹងការរំលោភបំពានសិទ្ធិមនុស្សជាបន្តបន្ទាប់ និងជាច្រើនករណីក្នុងរយៈពេលចុងក្រោយនេះ។ យើងខ្ញុំយល់ឃើញថា ការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាពីសំណាក់រដ្ឋាភិបាលដោយមិនបានអនុវត្តតួនាទី និងការហាមឃាត់សិទ្ធិប្រជាពលរដ្ឋកើតឡើងគ្រប់រូបភាព និងតាមគ្រប់មធ្យោបាយ។ ក្នុងនោះយើងខ្ញុំបានលើកយក បញ្ហាការរំលោភសិទ្ធិមនុស្សទាក់ទងនឹងបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិដោយសារវាជា បញ្ហាដ៏ក្ដៅគគុកមួយនៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើអោយប្រជាពលរដ្ឋ ព្រមទាំងសមាគន៍អន្តរជាតិ បានរិះគន់យ៉ាងខ្លាំងទៅលើទង្វើអសកម្មរបស់ រាជរដ្ឋាភិបាល។

ឆ្លងកាត់របបបន្តបន្ទាប់ជាច្រើនទើបកម្ពុជាបានក្លាយ ជាប្រទេសមានសន្តិភាពដូចសព្វថ្ងៃក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សស្របតាមរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ដែលពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិ និងត្រូវបានការពារសិទ្ធិរបស់ខ្លួនតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ព្រមទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិដោយឡែកផ្សេងទៀត។ ទោះបីជាយ៉ាងនេះក្ដី ក៏លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជាហាក់ដូចជាមិនទាន់មានភាពល្អប្រសើរ និងទូលំទូលាយនៅឡើយទេ ដោយសារតែនៅក្នុងពេលបច្ចុប្បន្ននេះ លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកំពុងធ្លាក់ចុះដល់ចំណុចដែលគួរអោយបារម្ភណ៍។ ដោយសារតែមួយរយៈពេលចុងក្រោយនេះមានការហាមឃាត់ ការគាប់សង្កត់ការគំរាមកំហែង និងរិតត្បិតសិទ្ធិបញ្ចេញមតិពីសំណាក់រដ្ឋាភិបាលទៅលើសកម្មជនសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលដែលជាអង្គការក្រៅរដ្ឋាភិបាល។ ដោយមើលឃើញដូចនេះហើយទើបយើងខ្ញុំ សម្រេចចិត្តលើកយកប្រធានបទ **បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ** មួយនេះមកធ្វើសារណាបញ្ចប់ការសិក្សា ដោយបង្ហាញនូវទិដ្ឋភាពជាក់ស្ដែងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ យើងខ្ញុំយល់ឃើញថាប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋគ្រប់រូបដែលទទួលបាននូវ សិទ្ធិបញ្ចេញមតិតាមគ្រប់ធ្យោបាយ និងគ្រប់ទម្រង់ស្របតាមសិទ្ធិរបស់ខ្លួនដែលទទួលបានពីសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ របស់អង្គការសហប្រជាជាតិ និងស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ ប៉ុន្តែជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ យើងខ្ញុំបានមើលឃើញពីការរំលោភបំពាន និងរិតត្បិតសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការសម្ដែងមតិពីសំណាក់រ

ដ្ឋាភិបាលតាមគ្រប់មធ្យោបាយ និងគ្រប់ទម្រង់។ ប្រជាពលរដ្ឋអាចធ្វើការបញ្ចេញមតិតាមប្រព័ន្ធផ្សព្វផ្សាយដែលកម្ពុជាមានគ្រប់មធ្យោបាយទាំង ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងបែបទំនើបសុទ្ធតែជាមធ្យោបាយដ៏សំខាន់សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប បញ្ចេញនូវគំនិត និងការចែករំលែកនូវយោបល់ បទពិសោធន៍របស់ខ្លួនបានដោយសេរី។ ប៉ុន្តែតាមការសង្កេតឃើញមានបញ្ហាប្រឈមជាច្រើនគួរអោយកត់សម្គាល់ដែលជាកត្តារាំងស្ទះដល់ការប្រើប្រាស់នូវសិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។ ហេតុនេះយើងខ្ញុំក៏បានផ្តល់ជាអនុសាសន៍ ផ្ទាល់ខ្លួនក្នុងការរួមចំណែកជួយអោយសេរីភាពបញ្ចេញមតិនៅកម្ពុជាមានភាពប្រសើរជាងពេលបច្ចុប្បន្ន ដែលអនុសាសន៍នោះសំដៅដល់ការកែលម្អ ក៏ដូចចាការរិះគន់នូវចំណុចខ្វះខាតរបស់រដ្ឋាភិបាលមួយចំនួនផងដែរ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាដែលស្តីពី បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ អាចជួយផ្តល់ជាចំណេះដឹងបន្ថែមដល់សិស្ស និងនិស្សិតជំនាន់ក្រោយអោយបានយល់ដឹងអោយបានកាន់តែស៊ីជម្រៅពីស្ថានភាពនៃសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ម្យ៉ាងទៀតក្នុងនាមជាទំពាំងស្នងឬស្សីនិស្សិតទាំងអស់គួរតែមានការយកចិត្តទុកដាក់ទៅលើបញ្ហាសិទ្ធិមនុស្សជាធំ ព្រោះប្រសិនបើសិទ្ធិមនុស្សមិនត្រូវបានគោរពនោះទេ កម្ពុជាក៏មិនអាចក្លាយជានីតិរដ្ឋបានដែរ។ ការហ៊ាននិយាយ ហ៊ានសរសេរ ហ៊ានចែករំលែក នូវការពិតអំពីមតិយោបល់របស់ខ្លួនដោយស្របច្បាប់។ សិទ្ធិបញ្ចេញមតិត្រូវបានការពារយ៉ាងដាច់ខាតពីបទដ្ឋានអន្តរជាតិ និងជាតិ ហើយគ្មានការរំលោភសិទ្ធិមនុស្សណាមួយត្រូវធ្វើឡើង ប្រសិនបើការបញ្ចេញមតិទាំងនោះត្រឹមត្រូវតាមច្បាប់។ ជាទីបញ្ចប់ យើងខ្ញុំជឿជាក់ថាសារណានេះនូវមានចំណុចខ្វះខាតនៅឡើយទាំងផ្នែកអក្ខរាវិរុទ្ធ ខ្លឹមសារ ក៏ដូចជាការរៀបរៀងចងក្រងជាសារណានេះឡើង។ យើងខ្ញុំរីករាយ និងទទួលយកនូវមតិរិះគន់ ដើម្បីកែប្រែនូវចំណុចអវិជ្ជមាន និងចំណុចខ្វះខាតទាំងនោះដើម្បីអោយបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិនៃសិទ្ធិមនុស្សនៅកម្ពុជាមានភាពប្រសើរឡើងវិញ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០

ក. ស៊ីន លីនដា ក. សុវណ្ណ បញ្ញា

# សេចក្តីផ្តើម

ជាទូទៅ ក្នុងការរស់នៅរបស់មនុស្សតែងតែចាំបាច់មានតម្រូវការជាច្រើនក្នុងការរស់រាន និងការការពារ ប្រកបដោយភាពថ្លៃថ្នូរដែលទាមទារអោយពីសំណាក់រដ្ឋភិបាលជាអ្នកផ្តល់នូវតម្រូវការទាំងនោះ។ ក្នុងនាម ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ និងកំពុងអភិវឌ្ឍន៍អោយបាននូវការគោរពសិទ្ធិមនុស្ស និងប្រឆាំង ដាច់ខាតរាល់ការរំលោភសិទ្ធិមនុស្សក្នុងសង្គមប្រជាធិបតេយ្យរបស់ខ្លួន។ ក្រោមការផ្លាស់ប្តូររបបដឹកនាំមួយ ដែលបានគ្រប់គ្រង (អ៊ុន តាក់) ជាលទ្ធផលនៃកិច្ចព្រមព្រៀងក្រុងប៉ារីសដែលបានចុះហត្ថលេខានៅឆ្នាំ ១៩៩១[1] គោរពតាមរដ្ឋធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដែលស្ថិតនៅកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានតម្រូវថា រដ្ឋធម្មនុញ្ញរួមមាន "គោលការណ៍ជាមូលដ្ឋានរួមទាំងអ្នកដែលទាក់ទងនឹងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន"។

ចាប់តាំងពីការអនុម័តនៃរដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំ ១៩៩៣ អង្គការសហប្រជាជាតិបានតែងតាំងតំណាងពិសេសរបស់អគ្គលេខាធិការសិទ្ធិមនុស្សនៅកម្ពុជានិងឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស ក្នុងកម្ពុជា។ រហូតមកទល់បច្ចុប្បន្ននេះ កម្ពុជាសម្រេចបាននូវការគោរពសិទ្ធិមនុស្សជាច្រើនគួរអោយកត់សម្គាល់ ដោយយើងសង្កេតឃើញថា កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា សេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិមនុស្សរួមមាន សិទ្ធិស្ត្រី សិទ្ធិកុមារ និងជនពិការផងដែរ។ គួរកត់សម្គាល់ផងដែរថាសិទ្ធិចម្បងរបស់មនុស្សមាន ៥ (ប្រាំ) គឺសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌។ ជាក់ស្តែង ក្នុងសង្គមកម្ពុជាបច្ចុប្បន្នប្រជាពលរដ្ឋបានឃើញនូវទង្វើ អសកម្មមួយចំនួនក្នុងពេលដែលប្រជាពលរដ្ឋព្យាយាមបញ្ចេញនូវមតិ តាមមធ្យោបាយមួយចំនួនហើយត្រូវបានរឹតត្បិតពីសំណាក់បុគ្គលដែលមានអំណាចនៅក្នុងជួររាជរដ្ឋាភិបាល។ សិទ្ធិមនុស្សនៅកម្ពុជាកំពុងប្រឈមមុខនឹងការរិះគន់ទាំងក្នុងប្រទេស និងសហគមន៍អន្តរជាតិ ព្រោះវាជាមូលហេតុមួយដ៏ចម្បងដែលបានរំខានដល់ការរីកលូតលាស់របស់ប្រទេសកម្ពុជាកាន់តែខ្លាំងឡើង។ ដោយយោងទៅលើភាពអកម្ម និងការខ្វះចន្លោះមួយចំនួនក្នុងការអនុវត្តសិទ្ធិមនុស្សកម្ពុជា យើងខ្ញុំបានសម្រេចធ្វើការសិក្សាស្រាវជ្រាវលើមូលហេតុ ក៏ដូចជាករណីសិក្សាជាក់ស្តែងទៅលើការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិមិនពេញលេញក្នុងប្រទេសកម្ពុជា ។

ជាចុងក្រោយ យើងនឹងធ្វើការសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាល ដែលជាតួអង្គសំខាន់ក្នុងការជំរុញការអនុវត្តសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជារឹតតែមានប្រសិទ្ធិភាព និងការផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងសារព័ត៌មាន និងអង្គការសង្គមស៊ីវិលដែលជាតួអង្គសំខាន់បន្ទាប់ពីរដ្ឋាភិបាលក្នុងការសង្កេតមើលលើ

[1] Ben Kiernan, The Pol Pot regime: race power, and genocide in Cambodia under the Khmer Rouge [របបប៉ុល ពត: ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានៅក្រោមរបបខ្មែរក្រហម] (២០០៨), ៥៤៥។

ភាពខ្វះខាត និងកែលម្អលើភាពអសកម្មរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តសិទ្ធិមនុស្ស។ ដោយសារតែប្រធានបទរបស់យើងខ្ញុំស្តីពី "**បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ**" ហេតុនេះទំហំនៃការស្រាវជ្រាវ គឺសំដៅលើបញ្ហាប្រឈមដែលកើតមានដោយសារការបញ្ចេញមតិរបស់ប្រជាពលរដ្ឋរបស់ប្រជាពលរដ្ឋកម្ពុជា និងផ្តោតសំខាន់ទៅលើដំណោះស្រាយ ចំពោះបញ្ហាប្រឈមនៃមូលនៃការបញ្ចេញមតិនៅកម្ពុជាមិនទាន់មានភាពពេញលេញនៅឡើយ។ ដោយសារតែប្រភពពត៌មានដែលទាក់ទងនឹងសិទ្ធិមនុស្សភាគច្រើន មានតែនៅអង្គការសង្គមស៊ីវិល ហេតុនេះយើងខ្ញុំសម្រេចចិត្តស្រាវជ្រាវឯកសារពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងបានស្រាវជ្រាវឯកសារនានាជាច្រើនទៀតតាមរយៈគេហទំព័រពត៌មានដូចជា វិទ្យុសំឡេងសហរដ្ឋអាមេរិក និងកាសែតភ្នំពេញប៉ុស្តិ៍ជាដើម ។ ចំណែកឯប្រភពទិន្នន័យបន្ទាប់បន្សំវិញ គឺបានមកពីកាសែតឯករាជ្យក្នុងស្រុករបាយការណ៍ការបោះពុម្ពផ្សាយ និងប្លុកជាដើមដែលមានប្រភពដើមអោយច្បាស់លាស់។ ប្រធានបទយើងខ្ញុំចែកចេញជា ៣ ជំពូក

ជំពូកទី១៖ **សញ្ញាណទូទៅនៃសិទ្ធិបញ្ចេញមតិ** គឺរៀបរាប់ពីប្រវត្តិនៃសិទ្ធិមនុស្សតាំងពីមុនសតវត្សទី២១ រហូតដល់មានការបង្កើតជាលិខិតូបករណ៍អន្តរជាតិ និយមន័យសិទ្ធិនៃការបញ្ចេញមតិនិងទស្សនៈទានរបស់អ្នកប្រាជ្ញល្បី។ ជាចុងក្រោយបានលើកឡើងពីបទបញ្ញត្តិទូទៅស្តីពីសិទ្ធិនៃការបញ្ចេញមតិដែលរួមមាន បទដ្ឋានគតិយុត្តិជាតិ និងបទដ្ឋានគតិយុត្តិអន្តរជាតិផងដែរ។

ជំពូកទី២៖ **បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ** គឺនិយាយពីបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នចំពោះសិទ្ធិបញ្ចេញមតិពីសំណាក់នីតិបុគ្គល និងរូបវន្តបុគ្គលដែលមានអំណាចនៅក្នុងជួររាជរដ្ឋាភិបាល។

ជំពូកទី៣៖ **ដំណោះស្រាយលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ** ចំណុចនេះបង្ហាញពីការបកស្រាយអំពីមូលហេតុនៃបញ្ហាប្រឈមចំពោះសិទ្ធិមនុស្សដែលលកើតមានឡើងដោយសាររាជរដ្ឋាភិបាលអនុវត្តផ្ទុយពីអ្វីដែលមាននៅក្នុងបទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិ។ ដែលមានជាការផ្តល់មតិយោបលការយល់ឃើញពីសំណាក់អ្នកវិភាគពីបញ្ហាសង្គម ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជាអោយមានភាពប្រសើរឡើងវិញ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃសិទ្ធិ

# បញ្ញេញូមតិ

# ជំពូកទី ១
# សញ្ញាណទូទៅនៃសិទ្ធិបញ្ចេញមតិ

សិទ្ធិ បានផ្តល់អោយប្រជាពលរដ្ឋរស់នៅដោយសប្បាយរីករាយ សុខភាពល្អ និងរស់នៅដោយមានសេរីភាព។ ភាគច្រើននៃប្រវត្តិសាស្ត្រ ប្រជាជនទទួលបានសិទ្ធិ និងការទទួលខុសត្រូវតាមរយៈសមាជិករបស់ខ្លួននៅក្នុងក្រុមដូចជាគ្រួសារមួយ ប្រទេស ជនជាតិដើមភាគតិច សាសនា វណ្ណៈសង្គម សហគមន៍ ឬរដ្ឋ។ យើងក៏ចាំបាច់ត្រូវតែមានសេរីភាពជាមូលដ្ឋានខ្លះទៀតដូចជា សេរីភាពក្នុងការបញ្ចេញមតិ និងការគោរពប្រតិបត្តិសាសនា។ ការទទួលបានជាតម្រូវការ និងសិទ្ធិសេរីភាពទាំងនេះ គឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស។ មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង មានសិទ្ធិទាំងនេះ មិនថាបុរស ឬ ស្ត្រី ក្មេង ឬចាស់, មាន ឬក្រ, កើតនៅទីកន្លែងណា និងមានជំនឿសាសនាអ្វីនោះទេ។ គ្មាននរណាម្នាក់អាចដកហូតសិទ្ធិទាំងនេះពីយើងបានឡើយ ហើយសិទ្ធិទាំងនេះត្រូវបានគោរពគ្រប់ពេលទាំងអស់[2]។ ប្រសិនបើមានការដកហូតសិទ្ធិ រំលោភបំពាន ឬបំបិទសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនូវអ្វីដែលមានក្នុងសេរីភាពជាមូលដ្ឋានរបស់មនុស្ស។ តើរាជរដ្ឋាភិបាលត្រូវមានវិធានការអ្វីខ្លះដើម្បីធ្វើការដោះស្រាយ រាល់បញ្ហាប្រឈមដែលកើតមានឡើងចំពោះ សេរីភាពជាមូលដ្ឋានជាពិសេសនៅត្រង់បញ្ហាប្រឈមចំពោះសិទ្ធិក្នុងការបញ្ចេញមតិ?

## ១.១ ប្រវត្តិនៃសិទ្ធិមនុស្ស

### ១.១.១. និយមន័យនៃសិទ្ធិបញ្ចេញមតិ

សិទ្ធិបញ្ចេញមតិ គឺជាសិទ្ធិនៃការសម្តែងមតិមួយដែលដើរតួយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងសង្គមប្រជាធិបតេយ្យ ។ ជនគ្រប់រូបត្រូវមានសិទ្ធិសម្តែងកង្វល់ និងទស្សនៈរបស់ខ្លួនដោយសេរីដោយគ្មានការជ្រៀតជ្រែក ឬរំខានពីសំណាក់រាជរដ្ឋាភិបាលឡើយ ។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាការពារយ៉ាងច្បាស់ដល់សិទ្ធិនេះសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយចែងថា ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ និងសេរីភាពខាងការជួបជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំអោយប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃដល់ទំនៀមទម្លាប់ល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ[3]។ សិទ្ធិបញ្ចេញមតិ រាប់ញ្ចូលទាំងទង្វើនៃការស្វែងរក ការទទួល និងការចែករំលែកព័ត៌មាន ឬគំនិត មិនគិតពីមធ្យោបាយប្រើប្រាស់ណាមួយ

2 ស្ពានទៅកាន់សន្តិភាពកម្ពុជា៖ សៀវភៅពលរដ្ឋវិជ្ជាៈ សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា (ឧសភា ២០១១), ២៣។

3 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ សិទ្ធិសេរីភាពក្នុងការសម្តែងមតិៈ https://cambodia.ohchr.org/kh/civil-society-fund-freedoms/freedom-expression ។

ទេ។ មាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ក៏បានចែងថា មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការបង្ហាញនូវមតិទាំងនោះ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងដើម្បីស្វែងរក ការទទួល ការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។

### ១.១.២. ទស្សនៈទានរបស់អ្នកប្រាជ្ញ

#### ១.១.២.១. ចនឡក់ (John Locke)

លោក John Locke ជាទស្សនវិទូ និងជាអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស។ ទស្សនទាននយោបាយសង្គមរបស់លោក John Locke ដែលធ្វើអោយមានកិត្យានុភាពល្បីល្បាញ ជាអ្នកនយោបាយវិទ្យាដែលបានបកស្រាយស្ថានភាពធម្មជាតិរបស់មនុស្សជាស្ថានភាពដែលមនុស្សមានសេរីភាពគ្រប់គ្រាន់ក្នុងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ស្ថានភាពធម្មជាតិ ជាស្ថានភាពដែលពោរពេញដោយសមត្ថភាពទាំងអំណាចទាំងសិទ្ធិ សុទ្ធតែមានស្មើៗគ្នាសម្រាប់បុគ្គលទាំងអស់ ដោយមិនមានបុគ្គលណាម្នាក់មានសិទ្ធិអំណាចច្រើនជាងបុគ្គលដទៃ ហើយសិទ្ធិសេរីភាពមិនអាចកាត់ផ្តាច់ពីបុគ្គលម្នាក់ណាឡើយ ក្នុងស្ថានភាពធម្មជាតិ។ សភាពធម្មជាតិ ជាកន្លែងដំបូងដែលបានផ្តល់សិទ្ធិអោយមនុស្សជា សភាពសន្តិភាព និងជាសភាពដែលមនុស្សសុឆន្ទៈចង់ជួយគ្នាទៅវិញទៅមក ជាសភាពដែលមនុស្សមានវិចារណញ្ញាណអាចយល់ដឹងពីច្បាប់ធម្មជាតិ និងចេះសម្របសម្រួលអាកប្បកិរិយារបស់ខ្លួនទៅនឹងច្បាប់ធម្មជាតិ។ តែសភាពធម្មជាតិ ក៏ជាសភាពខ្វះខាតមិនមានការកំណត់អំពីច្បាប់ និងប្រកាសអោយប្រើប្រាស់ច្បាប់សម្រាប់ទាំងអស់គ្នាឡើយ។ ក្នុងសភាពធម្មជាតិ ខ្វះខាតនូវអំណាចតុលាការ សម្រាប់ទប់ស្កាត់មិនអោយមានការសងសឹកគ្នា ការដណ្តើមគ្នាយកឈ្នះចាញ់តាមលក្ខណៈបុគ្គលដែលស្តែងឡើងក្នុងរូបភាពជាកូនក្តីផង ជាមេធាវីផង ជាចៅក្រមផងដែរ[4]។

ទ្រឹស្តីនយោបាយរបស់លោក Locke ត្រូវបានបង្កើតឡើងលើទ្រឹស្តីកិច្ចសន្យាសង្គម។ គាត់ជឿជាក់ថាធម្មជាតិមនុស្ស គឺកំណត់សម្គាល់ដោយហេតុផល ការអត់ឱន និងបានអនុញ្ញាតអោយមនុស្សមានភាពអាត្មានិយម។ នៅក្នុងរដ្ឋតាមបែបធម្មជាតិ មនុស្សទាំងអស់មានសេរីភាពស្មើគ្នា និងឯករាជ្យហើយមនុស្សគ្រប់រូបមានសិទ្ធិតាមធម្មជាតិក្នុងការការពារជីវិត សុខភាព សេរីភាព ឬទ្រព្យសម្បត្តិរបស់ពួកគេ។ លោក Locke បានសន្មតថា សិទ្ធិតែមួយគត់ក្នុងការការពារខ្លួននៅក្នុងរដ្ឋតាមបែបធម្មជាតិមិនគ្រប់គ្រាន់ឡើយ។ ហេតុនេះហើយ

---

[4] នួន សុធិមន្ត, វិទ្យាសាស្ត្រនយោបាយៈ គំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០), ៥១-៥២។

មនុស្សបានបង្កើតសង្គមស៊ីវិល ដើម្បីដោះស្រាយជម្លោះតាមបែបស៊ីវិល ដោយមានជំនួយពីរដ្ឋាភិបាលនៅក្នុងរដ្ឋនៃសង្គមមួយ[5]។

### ១.១.២.២. តូម៉ាសហាប់ ( Thomas Hobbes )

លោក Thomas Hobbes ជាទស្សនវិទូនយោបាយជនជាតិអង់គ្លេស ហើយគាត់មានឈ្មោះល្បីដោយស្នាដៃទស្សនវិជ្ជានយោបាយ និងស្នាដៃកិច្ចសន្យាសង្គម។ លោក Thomas Hobbes បានគិតដល់ជីវិតមនុស្សតើនឹងទៅជាយ៉ាងណាបើគ្មានរដ្ឋាភិបាល ដែលក្នុងស្ថានភាពនេះ គាត់ហៅថា រដ្ឋបែបធម្មជាតិ (State of Nature)។ នៅក្នុងរដ្ឋបែបធម្មជាតិនេះ មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានអ្វីៗនៅក្នុងពិភពលោក បញ្ហានេះជៀសមិនរួចនាំទៅដល់ជម្លោះ និងសង្គ្រាមដែលមនុស្សទាំងអស់ប្រយុទ្ធជាមួយគ្នា។ លោក Thomas Hobbes បាននិយាយថា មនុស្សគឺជាឆ្កែចចកសម្រាប់មនុស្សគ្នាឯង មានន័យថា នៅក្នុងសភាពធម្មជាតិ មនុស្សតែងច្បាំងគ្នា ប្រឆាំងគ្នាឯងផង និងប្រឆាំងអ្នកដទៃនៅក្នុងក្រុមផ្សេងៗទៀតផង។ នៅក្នុងសភាពធម្មជាតិ មានតែសង្គ្រាមជាអចិន្ត្រៃយ៍ មានតែអន្តិសុខដែលមនុស្សខ្សោយតែងជាអ្នករងគ្រោះរបស់អ្នកខ្លាំង ឬរបស់អ្នកមានល្បិចជាងខ្លួន។ មនុស្សមិនគ្រាន់តែអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសិទ្ធិធ្វើអ្វីៗដែលគេចង់ធ្វើ ឬទទួលយកនូវអ្វីដែលគេចង់បាន ដរាបណាគេមានអំណាចជាចាំបាច់។ មានតែរដ្ឋប៉ុណ្ណោះ ដែលអាចការពារបុគ្គលបាន ដើម្បីជៀសផុតពីសង្គ្រាមនេះ មនុស្សនៅក្នុងរដ្ឋបែបធម្មជាតិ ស្រុះស្រួលគ្នាចំពោះកិច្ចសន្យាសង្គមមួយ និងបង្កើតសង្គមស៊ីវិលឡើង។ សង្គម គឺជាបណ្តុំប្រជាពលរដ្ឋដែលស្ថិតនៅក្រោមអំណាចអធិបតេយ្យ ដែលមនុស្សទាំងអស់នៅក្នុងសង្គមនេះ ត្រូវលះបង់សិទ្ធិធម្មជាតិរបស់គេដើម្បីបុព្វហេតុសុវត្ថិភាព។ ប៉ុន្តែលោក Thomas Hobbes បានថ្លែងថា ក្នុងករណីមានការរំលោភបំពានអំណាចធ្ងន់ធ្ងរ នឹងមានការងើបបះបោរប្រឆាំង។ ជាពិសេសទ្រឹស្តីនៃការបែងចែក អំណាចមិនមានឡើយ គឺអ្នកដឹកនាំត្រូវត្រួតត្រាទាំងអំណាចស៊ីវិលយោធា តុលាការ និងអំណាចសាសនា[6] ។

### ១.១.២.៣. ហ្សង់ហ្សាក់រ៉ូសូ ( Jean-Jacques Rousseau )

ទស្សនវិជ្ជារបស់គាត់ មានឥទ្ធិពលទៅលើបដិវត្តន៍នៅប្រទេសបារាំង និងមានឥទ្ធិពលទៅលើកំណើតគំនិតនយោបាយសម័យទំនើប។ ស្នាដៃដ៏សំខាន់បំផុតរបស់គាត់ គឺកិច្ចសន្យាសង្គម ដែលគូសបញ្ជាក់អំពីមូលដ្ឋានសម្រាប់រៀបចំនយោបាយធម្មានុរូប។ លោក Rousseau បានអះអាងថា រដ្ឋតាមបែបធម្មជាតិ គឺជាលក្ខខណ្ឌដំបូងដែលគ្មានច្បាប់ ឬសីលធម៌ដែលមនុស្សបានចាកចេញ ដើម្បីគុណប្រយោជន៍ និងភាពចាំបាច់នៃការសហការគ្នា។ នៅពេលសង្គមរីកចម្រើនការបែងចែកការងារ និងទ្រព្យសម្បត្តិឯកជន តម្រូវអោយមនុស្ស

[5] ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និង ទ្រឹស្តីរដ្ឋ (ភ្នំពេញ: សុខលាភបោះពុម្ភ, (២០០៨), ១១៧។

[6] ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (ភ្នំពេញ: សុខលាភបោះពុម្ភ, ២០០២), ១៣០-១៣២។

រៀបចំស្ថាប័ននានាដែលមានច្បាប់។ នៅក្នុងដំណាក់កាលនៃសង្គមអន់ថយ មនុស្សតែងតែមានការប្រកួតប្រជែងគ្នា និងកាន់តែត្រូវការពឹងពាក់គ្នាឡើង។ សម្ពាធទាំងពីរនេះ បានគម្រាមកំហែងដល់ជីវិត និងសេរីភាពរបស់ពួកគេ។ ឆន្ទៈសេរីភាព និងសមភាព គឺជាសិទ្ធិធម្មជាតិរបស់មនុស្សដែលគេមិនអាចដកហូតយកបានឡើយហើយក៏មិនអាចអោយ ឬផ្ទេរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានឡើយ។ សេរីភាព ជាសិទ្ធិរបស់មនុស្សគ្រប់រូប បើមានការលុបបំបាត់សេរីភាពរបស់អ្នកណាម្នាក់ គឺលុបបំបាត់សិទ្ធិ និងភារកិច្ចរបស់មនុស្សជាតិ[7]។ តាមលោក Rousseau ការចូលរួមទៅក្នុងសង្គមស៊ីវិលតាមរយៈកិច្ចសន្យាសង្គម និងតាមរយៈការលះបង់ចោលនូវសិទ្ធិពីធម្មជាតិរបស់ខ្លួន ធ្វើអោយមនុស្សអាចរក្សាខ្លួនឯងផង និងនៅមានសេរីភាពផង។ លោក Rousseau យល់ថាសភាពធម្មជាតិ មិនមែនជាសភាពដែលលូតលាស់គ្មានកម្មសិទ្ធិឯកជនទេ គេម្នាក់ៗអាចបេះផ្លែឈើដែលមិនមែនជារបស់អ្នកណាម្នាក់បាន បើគ្មានកម្មសិទ្ធិឯកជនទេ ក៏គ្មានចោរដែរ។ នៅក្នុងសភាពធម្មជាតិ គេម្នាក់ៗជាមួយនិងគ្រួសារ អាចធ្វើដំណើរទៅទីកន្លែងណាដែលគេចង់ទៅមិនមានព្រំដែនអ្វីឡើយ ដូច្នេះបើគ្មានព្រំដែនក៏គ្មានរដ្ឋដែរ បើគ្មានរដ្ឋក៏គ្មានសង្គ្រាមដែរ ។

លោក Rousseau ពន្យល់ថា ការទទួលយកអំណាចនៃឆន្ទៈរបស់មនុស្ស ធានាកុំអោយបុគ្គលនីមួយៗត្រូវរលាយទៅនឹងឆន្ទៈរបស់បុគ្គលមួយក្រុមតូច ហើយក៏ធានាផងដែរថា ពួកគេគោរពខ្លួនឯងផងដែរ ពីព្រោះពួកគេតំណាងអោយសមូហភាពជាអ្នករៀបចំច្បាប់។ មនុស្សចាកចោលសភាពដាច់ឆ្ងាយពីគ្នា ដើម្បីចុះកិច្ចសន្យាមួយ គឺកិច្ចសន្យាសង្គម។ កម្មវត្ថុនៃកិច្ចសន្យាសង្គមនេះ គឺការបង្កើតអោយមានសង្គម។ ពិតមែនហើយ ដែលមនុស្សអាចរស់នៅដោយស្វែងរកដោយខ្លួនឯង ប៉ុន្តែមនុស្សយល់ឃើញថា វាមានប្រយោជន៍ច្រើន បើគេរស់នៅជាមួយគ្នាធ្វើការជាមួយគ្នា។ ទោះបីជាលោក Rousseau អះអាងថា អធិបតេយ្យគួរតែស្ថិតនៅក្នុងដៃប្រជាជន ប៉ុន្តែ គាត់ក៏បានបង្ហាញនូវភាពខុសគ្នារវាងអំណាចអធិបតេយ្យ និងរដ្ឋាភិបាល។ រដ្ឋាភិបាល រួមមានតុលាការ ដែលមានភារកិច្ចអនុវត្ត និងពង្រឹងការអនុវត្តឆន្ទៈរួមរបស់មនុស្ស។ អំណាចអធិបតេយ្យជា នីតិរដ្ឋដែលសម្រេចដោយប្រជាធិបតេយ្យដោយផ្ទាល់នៅក្នុងសភា។ ប៉ុន្តែ នៅក្រោមរបបរាជានិយម អំណាចអធិបតេយ្យពិតប្រាកដ ក៏នៅតែជាច្បាប់ដដែល។ លោក Rousseau បានប្រឆាំងទៅនឹងគំនិតដែរថា ប្រជាជនគួរប្រើប្រាស់អំណាចអធិតេយ្យតាមរយៈសភាតំណាងរាស្ត្រ[8]។

[7] ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (ភ្នំពេញៈ សុខលាភបោះពុម្ព, ២០០២), ១៤១-១៤៣។
[8] នួន សុធិមន្ត, វិទ្យាសាស្ត្រនយោបាយៈ គំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០), ៦០។

**១.១.២.៤. ម៉ុងតេស៊ីខ** ( Montesquieu )

សៀវភៅរបស់លោក Montesquieu ដែលត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៧៤៨ គឺជាស្នាដៃដ៏ល្បីល្បាញបំផុតរបស់លោក។ វាបានបង្ហាញពីគំនិតរបស់គាត់អំពីរបៀបដែលរដ្ឋាភិបាលអាចធ្វើការបានល្អបំផុត។ Montesquieu ជឿជាក់ថាអ្វីៗទាំងអស់ ត្រូវបានបង្កើតឡើងដោយច្បាប់ ឬច្បាប់ដែលមិនដែលផ្លាស់ប្តូរ។ លោកបានប្តេជ្ញាសិក្សាច្បាប់ទាំងនេះ តាមបែបវិទ្យាសាស្ត្រដោយសង្ឃឹមថា ចំណេះដឹងអំពីច្បាប់របស់រដ្ឋាភិបាលនឹងកាត់បន្ថយបញ្ហាសង្គម និងធ្វើឱ្យជីវិតមនុស្សកាន់តែប្រសើរឡើង។ យោងទៅតាមម៉ុងតេណេស មានរដ្ឋាភិបាលចំនួនបីប្រភេទ គឺរបបរាជានិយមមួយ (គ្រប់គ្រងដោយស្តេចរឺមហាក្សត្រី) សាធារណរដ្ឋ (គ្រប់គ្រងដោយមេដឹកនាំដែលបានជាប់ឆ្នោត) និងភាពស្អប់ខ្ពើម (គ្រប់គ្រងដោយមេដឹកនាំផ្តាច់ការ)។ លោក Montesquieu ជឿជាក់ថា រដ្ឋាភិបាលដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជន គឺជាទម្រង់រដ្ឋាភិបាលល្អបំផុត។ ទោះយ៉ាងណា លោកបានជឿជាក់ថា ជោគជ័យនៃលទ្ធិប្រជាធិបតេយ្យដែលជារដ្ឋាភិបាល ដែលប្រជាជនមានអំណាចពឹងផ្អែកលើការរក្សាតុល្យភាពអំណាចត្រឹមត្រូវ ។

លោក Montesquieu បានអះអាងថា រដ្ឋាភិបាលល្អបំផុត នឹងជាស្ថាប័នមួយដែលអំណាចមានតុល្យភាពក្នុងចំណោមមន្ត្រីបីក្រុម។ គាត់បានគិតថា ប្រទេសអង់គ្លេសដែលបានបែងចែកអំណាចរវាងព្រះមហាក្សត្រ (ដែលបានអនុវត្តច្បាប់) សភា (ដែលបង្កើតច្បាប់) និងចៅក្រមនៃតុលាការអង់គ្លេស (ដែលបកស្រាយច្បាប់) គឺជាគំរូដ៏ល្អមួយនៃរឿងនេះ។ លោក Montesquieu បានហៅគំនិតនៃការបែងចែកអំណាចរដ្ឋាភិបាលជាបីសាខា គឺការបំបែកអំណាច។ គាត់គិតថា វាសំខាន់បំផុតក្នុងការបង្កើតសាខារបស់រដ្ឋាភិបាលដាច់ដោយឡែកពីគ្នា ដោយមានអំណាចស្មើៗគ្នា ប៉ុន្តែ មានអំណាចខុសគ្នា។ តាមវិធីនោះ រដ្ឋាភិបាលនឹងជៀសវាងកុំដាក់អំណាចច្រើនពេកជាមួយបុគ្គល ឬក្រុមណាមួយ។ គាត់បានសរសេរថា នៅពេលដែលច្បាប់ជាអ្នកបង្កើត " អំណាច និងការអនុវត្តច្បាប់ " មានន័យថាមនុស្សមានសាមគ្គីភាពតែមួយ វាគ្មានសេរីភាពទេ។ យោងទៅតាមលោក Montesquieu សាខានៃរដ្ឋាភិបាលនីមួយៗ អាចកំណត់អំណាចរបស់សាខាពីរផ្សេងទៀត។ ដូច្នេះគ្មានស្ថាប័នណាមួយរបស់រដ្ឋាភិបាល អាចគំរាមកំហែងដល់សេរីភាពរបស់ប្រជាជនបានឡើយ។ គំនិតរបស់គាត់អំពីការបំបែកអំណាច បានក្លាយជាមូលដ្ឋានសម្រាប់រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ។

ទោះបី ម៉ុនណេស្គីជឿជាក់លើគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យក៏ដោយ ក៏គាត់មិនមានអារម្មណ៍ថាមនុស្សទាំងអស់មានភាពស្មើគ្នាទេ។ លោក Montesquieu បានយល់ព្រមពីទាសភាព គាត់ក៏បានគិតថា ស្ត្រីខ្សោយជាងបុរស ហើយពួកគេត្រូវគោរពតាមបទបញ្ជារបស់ប្តីរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ គាត់ក៏មានអារម្មណ៍ថា ស្ត្រីពិតជាមានសមត្ថភាពគ្រប់គ្រងដែរ។ វាប្រឆាំងនឹងហេតុផល និងប្រឆាំងនឹងធម្មជាតិ សម្រាប់

ស្ត្រីធ្វើជាស្រីកំណាន់នៅក្នុងផ្ទះ ប៉ុន្តែមិនមែនសម្រាប់ពួកគេគ្រប់គ្រងចក្រភពមួយទេ។ ក្នុងករណីដំបូង រដ្ឋទន់ខ្សោយរបស់ពួកគេមិនអនុញ្ញាតឱ្យពួកគេមានភាពលេចធ្លោនោះទេ។ ទីពីរ គឺពួកគេមានចំណុចខ្លាំងត្រង់ភាពទន់ខ្សោយផ្តល់ឱ្យពួកគេនូវភាពទន់ភ្លន់ និងកម្រិតមធ្យមដែលជាជាងគុណធម៌ដ៏សាហាវ និងសាហាវដែលអាចបង្កើតឱ្យមានបរិយាកាសល្អ។ តាមរបៀបនេះលោក Montesquieu បានអះអាងថា ស្ត្រីខ្សោយពេកមិនអាចគ្រប់គ្រងនៅផ្ទះបានទេ ប៉ុន្តែភាពស្ងប់ស្ងាត់ និងសុភាពរាបសា គឺជាគុណសម្បត្តិដែលមានប្រយោជន៍ក្នុងការសម្រេចចិត្តនៅក្នុងរដ្ឋាភិបាល[9]។

**១.១.២.៥. ម៉ារីវាឌ្យូស្តូន** ( Mary Wollstonecraft )

លោកស្រី Mary Wollstonecraft ជាអ្នកនិពន្ធជនជាតិអង់គ្លេសមួយរូប ដែលប្រកាន់ជំហរយ៉ាងរឹងមាំក្នុងការពារសិទ្ធិរបស់ស្ត្រី។ ស្នាដៃដែលល្បីល្បាញបំផុតរបស់គាត់ គឺសៀវភៅដែលមានចំណងជើងថា "ការការពារសិទ្ធិស្ត្រី" (A Vindication of the Right of Woman)។ នៅក្នុងសៀវភៅនោះលោកស្រី បានប្រកាន់ជំហរយ៉ាងរឹងមាំប្រឆាំងនឹងទស្សនៈដែលគិតថា ស្ត្រីគឺជាគ្រឿងលំអដែលគ្មានប្រយោជន៍ក្នុងផ្ទះ។ លោកស្រីបញ្ជាក់ថា សង្គមបានចិញ្ចឹមសត្វតិរច្ឆានដែលស្លូតបូតនៅក្នុងផ្ទះ វាប្រៀបដូចជាការបង្ខាំងទុកស្ត្រីទាំងនេះអោយមានការកើតមានឡើងនូវកំហឹង និងប្រែខ្លួនជាអ្នកដឹកនាំផ្តាច់ការលើកូន និងអ្នកបម្រើរបស់ពួកគេ។ គោលគំនិតរបស់លោកស្រី គឺស្វែងរកដំណោះស្រាយ និងទាមទារអោយមានបដិវត្តន៍វិស័យអប់រំ ដើម្បីអោយស្ត្រីទទួលបានសិទ្ធិអប់រំដូចបុរស[10]។

## ១.២. បទបញ្ញាតិទូទៅស្តីពីសិទ្ធិបញ្ចេញមតិ

### ១.២.១. បទដ្ឋានគតិយុត្តអន្តរជាតិ

#### ១.២.១.១. រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ

ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលប្រទេសនៅលើពិភពលោកជាសមាជិកនៃអង្គការសហប្រជាជាតិអនុម័តយល់ព្រម។ ស្របតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ក៏បានទទួលស្គាល់នូវការគោរពសិទ្ធិមនុស្ស ដូចដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិនេះផងដែរ។ ប្រការ ១ ចំណុចទី៣ នៃរដ្ឋធម្មនុញ្ញសហប្រជាជាតិ ដែលស្តីពីវត្ថុបំណងនៃសហប្រជាជាតិចែងថា ត្រូវបង្កើតអោយមានពិតប្រាកដនូវសហប្រតិបត្តិការអន្តរជាតិ ដោយដោះស្រាយនូវបញ្ហាអន្តរជាតិខាងសេដ្ឋកិច្ច សង្គមកិច្ចឬ មនុស្សធម៌ ដោយពង្រីក និងលើកទឹកចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពជា

[9] Baron de Montesquieu៖ A short Biography: https://www.rjgeib.com/thoughts/montesquieu/montesquieu-bio.html ។

[10] Encyclopedia Britannica: https://www.britannica.com/biography/Mary-Wollstonecraft ។

សាធារណៈសម្រាប់មនុស្សទូទៅ ឥតសម្គាល់ជាតិសាសន៍ ភេទ ភាសា ឬសាសនាឡើយ[11]។ ប្រការនេះបង្ហាញអោយឃើញពីការងារសំខាន់មួយ ដែលអង្គការសហប្រជាជាតិត្រូវបំពេញក្នុងចំណោមការងារសំខាន់ដទៃផ្សេងទៀតពោល គឺការធានាអោយបាននូវការគោរពសិទ្ធិមនុស្សរបស់មនុស្សគ្រប់ៗគ្នា នៅលើសកលលោកដោយមិនមាននូវការប្រកាន់ ឬបែងចែកពូជសាសន៍ ភេទ សាសនាជាដើមឡើយ។

### ១.២.១.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាសេចក្តីប្រកាសអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ នៅទីក្រុងប៉ារីស[12]។ សេចក្តីប្រកាសនេះ បានក្រោកឡើងដោយផ្ទាល់ពីបទពិសោធន៍នៃសង្គ្រាមលោកលើកទី២ និងតំណាងអោយការបញ្ចេញមតិជាសកល ដំបូងនៃសិទ្ធិដែលមនុស្សទាំងអស់មានសិទ្ធិទទួលបាន។ ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស មានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពី សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារជម្រើសពីរបស់ខ្លួន។ ការអនុម័តនៃសេចក្តីប្រកាសជាសកល គឺជាការរំលឹកនូវព្រឹត្តិការណ៍អន្តរជាតិដ៏សំខាន់សម្រាប់សម្គាល់ជារៀងរាល់ឆ្នាំនៅថ្ងៃទី១០ ខែធ្នូ ហើយត្រូវបានគេស្គាល់ថា ជាទិវាសិទ្ធិមនុស្ស ឬទិវាសិទ្ធិមនុស្សអន្តរជាតិ។ មិនតែប៉ុណ្ណោះ ក្នុងមាត្រា ១៩ នៃសេចក្តីប្រកាសនេះបានថ្លែងថា ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិនិងសម្តែងមតិ[13]។ សិទ្ធិនេះ រាប់បញ្ចូលសេរីភាពក្នុងការប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួលបាន និងការផ្សព្វផ្សាយនូវព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។

### ១.២.១.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដោយមហាសន្និបាទអង្គការសហប្រជាជាតិ ហើយចូលជាធរមានតាមច្បាប់អន្តរជាតិ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦[14]។ កតិកាសញ្ញានេះ ជាសន្ធិសញ្ញាអន្តរជាតិមួយក្នុងចំណោមសន្ធិសញ្ញាអន្តរជាតិពីរ ដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់អនុភាពតាមផ្លូវច្បាប់ដល់ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ ការព្រាងសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយ គឺមិនទាន់គ្រប់គ្រាន់ទេ ដោយសារតែនិន្នាការនយោបាយខុសគ្នា ក្នុងសហគមន៍អន្តរជាតិនាពេលនោះ ទើបនាំអោយមានការព្រមព្រៀងគ្នាលើសេចក្តីព្រាងសន្ធិសញ្ញា

[11] ការបកប្រែជាភាសាខ្មែររបស់គេហទំព័របណ្ណាល័យច្បាប់។

[12] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តថ្ងៃទី១០ ធ្នូ ១៩៤៩)។

[13] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តថ្ងៃទី១០ ធ្នូ ១៩៤៩), មាត្រា ១៩ ។

[14] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តកាលពីថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃទី២៣ មីនា ១៩៧៦)។

ចំនួនពីរស្របគ្នា។ ហេតុដូច្នេះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានដើរទន្ទឹមគ្នាជាមួយនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ កតិកាសញ្ញាទាំងពីរនេះ ធ្វើតាមទម្រង់ដូចគ្នា និងមានបទបញ្ញត្តិរួមដូចគ្នាជាច្រើន។ ការបែងចែកសិទ្ធិមនុស្សជាពីរកតិកាសញ្ញានេះ ព្រមទាំងការអនុម័តជាបន្តបន្ទាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលគ្របដណ្តប់លើវិស័យផ្សេងៗគ្នា អង្គការសហប្រជាជាតិ តែងតែបានសង្កត់ធ្ងន់លើពាក្យ ***សកលភាពនៃភាពទាក់ទងគ្នា និងភាពពុំនាក់អាស្រ័យគ្នា*** នៃសិទ្ធិមនុស្សទាំងអស់។ និយាយជារួម សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនសំខាន់ជាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌ ក៏មិនសំខាន់ជាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ ពីព្រោះមនុស្សទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្សទាំងអស់ស្មើគ្នា។ កតិកាសញ្ញាទាំងពីរនេះ មានទំនាក់ទំនងយ៉ាងស្អិតរមួតរវាងសិទ្ធិទាំងពីរនេះ នៅពេលខ្លះមានលក្ខណៈច្បាស់លាស់ណាស់ ដោយសារកតិកាសញ្ញាទាំងពីរមានបញ្ញត្តិអំពីសិទ្ធិស្វ័យសម្រេច ការមិនរើសអើង និងសមភាព ព្រមទាំងសិទ្ធិសហជីព និងការការពារគ្រួសារ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើតគោលការណ៍ទូទៅដែលណែនាំរដ្ឋតាមរយៈបទបញ្ញត្តិក្នុងពីរផ្នែកដំបូងនៃកតិកាសញ្ញានេះ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានការពារ ដែលគោលការណ៍ទាំងនោះ រួមមានដូចជា ៖

- សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនទាំងអស់ដើម្បីធ្វើសេចក្តីសម្រេចលើឋានៈនយោបាយរបស់ខ្លួនដោយសេរីនិងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា១)[15]
- គោលការណ៍នៃការមិនរើសអើង ក្នុងការអនុវត្តសិទ្ធិតាមកតិកាសញ្ញានេះ (មាត្រា២)[16]
- គោលការណ៍សមភាពរវាងបុរស និងស្ត្រីក្នុងការអាស្រ័យសិទ្ធិទាំងនេះ (មាត្រា៣)[17]

សិទ្ធិភាគច្រើននៅក្នុងអនុសញ្ញានេះ គឺជាសិទ្ធិដាច់ខាត ហើយត្រូវតែអនុវត្តភ្លាមៗទាំងស្រុង ខណៈដែលសិទ្ធិទាំងនេះចូលជាធរមាន។ ជាក់ស្តែង ការទទួលយកបម្រាមនៃអំពើទារុណកម្ម គឺរាល់ទារុណកម្មត្រូវតែបញ្ចប់ដោយគ្មានមូលហេតុអ្វីទាំងអស់។ ទោះជាយ៉ាងនេះក្តី ក្នុងកាលៈទេសៈកំណត់មួយចំនួនតូច រដ្ឋអាចព្យួរសិទ្ធិទាំងនេះអោយរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ដូចជារដ្ឋស្ថិតក្នុងពេលមានអាសន្ន ជាទូទៅការគំរាមកំហែង

[15] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តកាលពីថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃទី២៣ មីនា ១៩៧៦), មាត្រា ១។

[16] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តកាលពីថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃទី២៣ មីនា ១៩៧៦), មាត្រា ២។

[17] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តកាលពីថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃទី២៣ មីនា ១៩៧៦), មាត្រា ៣។

ដល់អាយុជីវិតរដ្ឋ អាចចាត់វិធានការធានាដែលតម្រូវចាំបាច់បំផុត ដើម្បីដោះស្រាយការគំរាមកំហែងនេះ។ ប៉ុន្តែកាតព្វកិច្ចនៃការមិនរើសអើង និងសិទ្ធិសំខាន់ៗមួយចំនួនទៀត រួមមាន សិទ្ធិមានអាយុជីវិត សេរីភាពចាកផុតពីការធ្វើទារុណកម្ម និងទាសភាព សេរីភាពខាងមនសិការ និងសាសនាព្រមទាំងកិច្ចធានាការពារតាមផ្លូវច្បាប់មួយចំនួន ត្រូវបានចាត់ទុកថា ***មិនអាចព្យួរជាបណ្តោះអាសន្ន*** បានទេ មានន័យថា រដ្ឋមិនអាចព្យួរសិទ្ធិទាំងនេះជាបណ្តោះអាសន្នបានទេទោះជាស្ថិតក្នុងកាលៈទេសៈប្រទេសប្រកាសស្ថានភាពគ្រាអាសន្នក៏ដោយ។ ដោយឡែកព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ ជាក់ស្តែង ក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ[18] ដែលបានធានាការពារអនុសញ្ញានេះថា ជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រាដទៃទៀតគូសបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការធានាថាប្រជាជនកម្ពុជាទាំងអស់អាចអាស្រ័យនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ពួកគេ។ សេចក្តីប្រកាសនៃសិទ្ធិក្នុងជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញ រួមមាន ការការពារអាយុជីវិត សន្តិសុខ និងសេរីភាព (មាត្រា ៣២)[19] សិទ្ធិប្រជាធិបតេយ្យ (មាត្រា ៣៤ ៣៥ និង៤២)[20] សិទ្ធិបង្កើតសហជីព (មាត្រា ៣៦)[21] ការធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋានចំពោះការចាប់ខ្លួន និងការឃុំខ្លួន (មាត្រា ៣៨)[22] សេរីភាពក្នុងការដើរហើរ (មាត្រា ៤០)[23] សេរីភាពនៃការបញ្ចេញមតិ (មាត្រា ៤១)[24] សេរីភាពខាងសាសនា (មាត្រា ៤៣)។ រីឯ ឯករាជ្យភាពតុលាការវិញ ត្រូវបានធានាការពារនៅក្នុងជំពូកទី១១ នៃរដ្ឋធម្មនុញ្ញ។ បន្ទាប់ពីកម្ពុជាបានក្លាយជារដ្ឋសមាជិកនៃកតិកាសញ្ញានេះ កម្ពុជាត្រូវជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ពីការប្តេជ្ញាចិត្តចំពោះប្រជាជនពលរដ្ឋរបស់ខ្លួន និងចំពោះសហគមន៍អន្តរជាតិ ក្នុងការអនុវត្តបទបញ្ញត្តិនៃសន្ធិសញ្ញានេះដើម្បីលើកស្ទួយ ការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។ កតិកាសញ្ញានេះ បានបង្កើតគណៈកម្មាធិការអន្តរជាតិមួយ ដើម្បីជួយរដ្ឋភាគីក្នុងការបំពេញបាននូវការប្តេជ្ញាចិត្តដែលសុទ្ធតែជាអ្នកជំនាញការឯករាជ្យ ហើយត្រូវបានទទួលស្គាល់ជាទូទៅថា គណៈកម្មាធិការសិទ្ធិមនុស្ស ដើម្បីឃ្លាំមើលការរីកចម្រើន និងផ្តល់ប្រឹក្សាយោបល់ដល់រដ្ឋជាភាគី។ រដ្ឋភាគីទាំងអស់ តម្រូវអោយរាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការនេះ ពីការចាត់វិធានការរបស់ខ្លួន ដើម្បីធានាបាននូវការអនុវត្តកតិកាសញ្ញនេះ។ បន្ទាប់ពីបានរបាយការណ៍ទាំង

[18] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣១។
[19] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣២។
[20] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣២, ៣៥, ៤២។
[21] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣៦។
[22] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣៨។
[23] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៤០។
[24] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៤១, ៤៣។

នេះ ត្រូវយកមកពិភាក្សាជាមួយរដ្ឋាភិបាលសាមី រួចផ្តល់អនុសាសន៍ដល់រដ្ឋនោះ។ ដូចគ្នាដែរ កម្ពុជាបានដាក់របាយការណ៍ដំបូងរបស់ខ្លួនជូនអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៨ ហើយគណៈកម្មាធិការបានយករបាយការណ៍នោះមកពិនិត្យនៅខែកក្កដា ឆ្នាំ១៩៩៩។

### ១.២.១.៤.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដោយមហាសន្និបាទអង្គការសហប្រជាជាតិ ហើយបានចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦[25] ។ កតិកាសញ្ញានេះ មិនខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ ដោយបានផ្តល់អានុភាពតាមផ្លូវច្បាប់ដល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ ទោះជាយ៉ាងនេះក្តី កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយសារវាមិនអាចអនុវត្តបានភ្លាមៗ និងដាច់ខាតនោះទេ ព្រោះសិទ្ធិទាំងនេះទាមទារនូវពេលវេលា និងធនធានសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធ។ ជាក់ស្តែងការអនុវត្តយ៉ាងពេញលេញនូវសិទ្ធិអប់រំទាមទារជាដំបូងអោយមានការសាងសង់អគារ និងការបណ្តុះបណ្តាលគ្រូបង្រៀន ដែលត្រូវចំណាយធនធានទៅលើប្រទេសជាច្រើន ដែលជាប្រទេសខ្សត់ខ្សោយ។ ដើម្បីដោះស្រាយបញ្ហានេះ កតិកាសញ្ញានេះ តម្រូវអោយរដ្ឋភាគីធានាការរីកចម្រើនជាលំដាប់នៃសិទ្ធិទាំងនេះ។ ទោះជាធនធានអាចមានកម្រិតក៏ដោយ ប៉ុន្តែយ៉ាងហោចណាស់រដ្ឋភាគី ត្រូវតែធ្វើអោយមានការរីកចម្រើនជាបន្តបន្ទាប់ និងជាក់ស្តែង ដើម្បីធ្វើអោយកាន់តែប្រសើរឡើយតាមតែអាចធ្វើបានដល់ការរីកចម្រើននៃសិទ្ធិទាំងនេះ។ ហើយនៅពេលណា ដែលសិទ្ធិទាំងនេះ អាចអនុវត្តបានយ៉ាងពេលលេញភ្លាមៗត្រូវតែអនុវត្ត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចែងនូវសិទ្ធិសំខាន់ៗដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបានរួមមាន ៖

- សិទ្ធិធ្វើការងារ(មាត្រា ៦)[26] សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និង អំណោយផល និងសិទ្ធិទទួលបានការសំរាកលំហែ (មាត្រា ៧)
- សិទ្ធិសហជីព (មាត្រា ៨)
- សិទ្ធិទទួលបានសន្តិសុខសង្គម (មាត្រា ៩)
- សិទ្ធិគ្រួសារ រួមទាំងអាពាហ៍ពិពាហ៍ និង ការគាំពារស្ត្រីនិងកុមារ (មាត្រា ១០)

[25] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (អនុម័តនៅថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ មករា ១៩៧៦) ។
[26] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (អនុម័តនៅថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ មករា ១៩៧៦), មាត្រា ៦-១៥ ។

- សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមមានចំណីអាហារ សំលៀកបំពាក់ លំនៅដ្ឋាន និង ការកែលំម្អក៏រិតជីវភាពជាបន្តបន្ទាប់ (មាត្រា ១១)
- សិទ្ធិទទួលបានសុខភាពផ្លូវកាយ និង ផ្លូវចិត្ត (មាត្រា ១២)
- សិទ្ធិទទួលបានការអប់រំ រួមទាំងការអប់រំមិនបង់ថ្លៃ និង ជាកាតព្វកិច្ចនៅបឋមសិក្សា (មាត្រ តា ១៣ និង មាត្រា ១៤)
- សិទ្ធិវប្បធម៌ (មាត្រា ១៥)

ព្រះរាជាណាចក្រកម្ពុជា បានចូលជាភាគីនៃកតិកាសញ្ញានេះ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ធានាការពារអនុសញ្ញា ជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រាដទៃៗទៀត សបញ្ជាក់អោយឃើញថា ប្រជាជនកម្ពុជាទាំងអស់អាចទទួលបានសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងវិសាលភាពមួយដ៏ពេញលេញបំផុតតាមដែលអាចធ្វើទៅបាន។ ជាក់ស្តែង ក្នុងមាត្រា ៣៦ ចែងអំពីសិទ្ធិធ្វើការងារ សិទ្ធិទទួលបានលក្ខណ្ឌការងារត្រឹមត្រូវ និងសិទ្ធិចូលរួមសហជីពមាត្រា ៦៥ ការពារសិទ្ធិទទួលបានការអប់រំដែលមានគុណភាព មាត្រា ៧២ ធានាការពារសិទ្ធិសុខភាពរបស់ប្រជាជន និងមាត្រា ៧៥ តម្រូវអោយរដ្ឋភាគីបង្កើតប្រព័ន្ធសន្តិសុខសង្គមសម្រាប់កម្មករ។ លើសពីនេះទៅទៀត រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ត្រូវប្តេជ្ញាចិត្ត ដោយចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះសហគមន៍អន្តរជាតិ ក្នុងការអនុវត្តបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញាដើម្បីលើកស្ទួយ និងការពារសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌។ ដើម្បីតាមដានការអនុវត្តកតិកាសញ្ញានេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ បានបង្កើតគណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ដែលហៅថា គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ ដើម្បីតាមដានការរីកចម្រើនរបស់រដ្ឋភាគី។ ក្នុងនោះ រដ្ឋភាគីទាំងត្រូវតែធ្វើរបាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការ ស្តីអំពីដំណាក់កាលនានាដែលខ្លួនបានប្រកាន់យកក្នុងការអនុវត្តឲ្យបាននូវកាតព្វកិច្ច ដែលមានចែងក្នុងកតិកាសញ្ញានេះ។ ចំពោះប្រទេសកម្ពុជាវិញ របាយការណ៍ដំបូងរបស់ខ្លួន បានដល់ពេលកំណត់ដាក់ជូនគណៈកម្មាធិការនាខែមិថុនា ឆ្នាំ១៩៩៤ តែរហូតមកដល់ខែតុលា ឆ្នាំ២០០៨ ទើបរដ្ឋាភិបាលបានដាក់របាយការណ៍របស់ជូនគណៈកម្មាធិការ ហើយគណៈកម្មាធិការពិនិត្យរបាយការណ៍នេះទៅក្នុងសម័យប្រជុំរបស់ខ្លួនក្នុងខែឧសភា ឆ្នាំ២០០៩។

### ១.២.២. បទដ្ឋានគតិយុត្តិជាតិ

#### ១.២.២.១. រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

សិទ្ធិសេរីភាពបញ្ចេញមតិ ក៏ត្រូវបានធានាក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់កំពូលរបស់ប្រទេស ដែលរដ្ឋធម្មនុញ្ញនេះ ត្រូវបានប្រសូតឡើងបន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្ថលេខាប្រកាសអោយប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ក្នុងមាត្រា ៣១ ដែលបានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទទួលអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស[27]។ ម៉្យាងវិញទៀត ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជា ដែលមានអាណត្តិក្នុងការការពាររដ្ឋធម្មនុញ្ញ បានអះអាងក្នុងសេចក្តីសម្រេចកាលពីឆ្នាំ២០០៧ ថា តួនាទីសន្ធិសញ្ញាសិទ្ធិមនុស្សគឺត្រូវចាត់ទុកជាច្បាប់ជាតិ ហើយអាចអនុវត្តបានចំពោះមុខតុលាការ។ សេចក្តីសម្រេចនោះ បានចែងថា គ្មានច្បាប់ណាត្រូវបានយកមកប្រើប្រាស់ប្រាកចាកពីរដ្ឋធម្មនុញ្ញ ឬសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាជារដ្ឋភាគីនោះឡើយ។ កម្ពុជា គឺប្រកាន់នូវប្រព័ន្ធច្បាប់មួយនេះអាស្រ័យហេតុនេះ សន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ននោះ គួរតែត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិនៅក្នុងច្បាប់ជាតិ។ បន្ថែមលើសនេះទៀត សិទ្ធិសេរីភាពបញ្ចេញមតិ គឺត្រូវបានធានាដោយឡែកក្រោមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ពលរដ្ឋខ្មែរ មានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ រដ្ឋធម្មនុញ្ញ លើកកម្ពស់ដល់មជ្ឈដ្ឋានណាមួយ ដែលពលរដ្ឋត្រូវបានគេពង្រឹងអំណាចដើម្បីអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈ[28]។ ដូចគ្នាដែរទៅនឹងលិខិតបទដ្ឋានអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ការទទួលស្គាល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជារឿងសំខាន់ ហើយចាំបាច់បំផុតដែលរដ្ឋត្រូវធ្វើ ប៉ុន្តែ ឆ្លើយតបមកវិញប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ ក៏មិនអាចសំអាងថាជាសិទ្ធិរបស់ខ្លួនប្រើប្រាស់សិទ្ធិដោយរំលោភលើច្បាប់ហួសដែនកំណត់បានដែរ។ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រទេសជាតិ និងសេចក្តីស្នើទាំងឡាយរបស់ពលរដ្ឋត្រូវទទួលបានការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ [29] ។

[27] រដ្ឋធម្មនុញ្ញ, លេខ នស/ រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣១។
[28] រដ្ឋធម្មនុញ្ញ, លេខ នស/ រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៤១។
[29] រដ្ឋធម្មនុញ្ញ, លេខ នស/ រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣៥។

ហើយសិទ្ធិក្នុងការបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ក៏ត្រូវបានចែងដោយរដ្ឋធម្មនុញ្ញក្នុងមាត្រា ៣៧ ផងដែរ ដែលថាសិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី[30]។

### ១.២.២.២. ច្បាប់ស្តីពីរបបសារព័ត៌មាន

ច្បាប់ស្តីពីរបបសារព័ត៌មាន ត្រូវបានចូលជាធរមាននៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ក្រោយពីបានទទួលការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជារួមមក។ លិខិតបទដ្ឋានគតិយុត្តិមួយនេះមានសារៈសំខាន់ខ្លាំងណាស់ចំពោះសិទ្ធិនយោបាយ ដោយសារវាបានកំណត់ពីសិទ្ធិ និងសេរីភាពខាងសារពត៌មានរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ជាពិសេស ច្បាប់នេះបានចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកសារពត៌មានអ្នកបោះពុម្ពផ្សាយ។ សិទ្ធិរបស់អ្នកសារព័ត៌មាន និងអ្នកបោះពុម្ពផ្សាយដែលត្រូវមានក្នុងច្បាប់ស្តីពីរបបសារព័ត៌មាននេះមានដូចជា សិទ្ធិក្នុងការទទួលបានព័ត៌មាន និងបោះពុម្ពនូវសេចក្តីថ្លែងការណ៍ណាមួយរបស់អង្គនីតិបញ្ញត្តិ (រដ្ឋសភា) អង្គនីតិប្រតិបត្តិ (រាជរដ្ឋាភិបាល) អង្គតុលាការ[31]។ មួយទៀត គឺសិទ្ធិក្នុងការបង្កើតនូវសហគមអ្នកសារព័ត៌មានរបស់អ្នកសារព័ត៌មាន[32]។

ចំណែកឯ កាតព្វកិច្ចរបស់អ្នកសារព័ត៌មាន ក៏ដូចជាអ្នកបោះពុម្ព មានដូចជា កាតព្វកិច្ចក្នុងការផ្សាយ និងបោះពុម្ពផ្សាយនូវសេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗរបស់អង្គស្ថាប័នទាំងបី ដោយគោរពទៅតាមការចែងក្នុងមាត្រា ៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ៖

- ➢ អាចផ្សាយ ឬបោះពុម្ពផ្សាយនូវគ្រប់សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗរបស់រដ្ឋសភារួមទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាបាន លើកលែងតែករណីរដ្ឋសភាធ្វើការប្រជុំសម្ងាត់ដូចមានចែងក្នុងមាត្រា ៨៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[33]។
- ➢ អាចផ្សាយ ឬបោះពុម្ពផ្សាយនូវគ្រប់សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗនូវគ្រប់ទិដ្ឋភាពនៃសដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែ ៖
  - តុលាការ ហាមមិនអោយបើកចំហរដល់សាធារណៈជន
  - ប៉ះពាល់អាថ៌កំបាំងរបស់បុគ្គលម្នាក់ៗ នៅក្នុងដំណើរការជំនុំជម្រះក្តី
  - សំណុំរឿងដែលនៅក្នុងការស៊ើបអង្កេតរបស់តុលាការនៅឡើយ[34]

---

[30] រដ្ឋធម្មនុញ្ញ, លេខ នស/ រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣, មាត្រា ៣៧។

[31] ច្បាប់ស្តីពីរបបសារព័ត៌មាន, មាត្រា ១។

[32] ច្បាប់ស្តីពីរបបសារព័ត៌មាន, មាត្រា ៦។

[33] ច្បាប់ស្តីពីរបបសារព័ត៌មាន, មាត្រា ៤ ចំណុច១។

[34] ច្បាប់ស្តីពីរបបសារព័ត៌មាន, មាត្រា ៤ ចំណុច៣។

ក្នុងនាមជាប្រទេសដែលប្រកាន់នូវសិទ្ធិប្រជាធិបតេយ្យ ប្រទេសកម្ពុជា បានបើកចំហយ៉ាងទូលាយចំពោះសេរីភាពខាងសារព័ត៌មាន ក្នុងគោលបំណងអោយប្រជាពលរដ្ឋរបស់ខ្លួនទាំងអស់ ទទួលបាននូវគ្រប់ព័ត៌មានទាំងអស់នូវរាល់ព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងសង្គម មិនថាបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច ឬនយោបាយនោះទេ។ ប៉ុន្តែ សេរីភាពទាំងនោះ ក៏ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ក្នុងប្រទេសកម្ពុជាផងដែរ គឺច្បាប់ស្តីពីរបបសារព័ត៌មាន។ ទោះជាយ៉ាងនេះក្តី ជាគោលការណ៍ សារព័ត៌មាន សិទ្ធិទទួលបានព័ត៌មានដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែ ព័ត៌មានណាដែលអន្តរាយដល់សន្តិសុខ អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ ការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ក្នុងការនាំអោយមានជំនុំជំរះក្តីដោយអយុត្តិធម៌ និង មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ជាដើម (មាត្រា៥)[35]។ ម្យ៉ាង ច្បាប់ស្តីពីរបបសារព័ត៌មានក៏បានបញ្ញត្តិផងដែរ ពីការទទួលខុសត្រូវនៃអ្នកសារព័ត៌មានដោយក្នុងនោះពួកគេមាន សិទ្ធិបង្កើតសមាគមអ្នកសារព័ត៌មានដោយមានលក្ខណៈឯករាជ្យ ហើយត្រូវគ្រប់គ្រងដោយលក្ខន្តិកៈរបស់ខ្លួន ដែលមិនផ្ទុយនឹងច្បាប់ជាធរមាន (មាត្រា ៦)[36]។

### ១.២.២.៣. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ និងត្រូវបានចូលជាធរមាន នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ ក្រោយពីព្រះមហាក្សត្រទ្បាយព្រះហស្តលេខាប្រកាសអោយប្រើ។ ច្បាប់នេះ ត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋកម្ពុជា គឺមានបំណងធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី។ ជាការឆ្លើយតបទៅនឹងការប្រើប្រាស់សិទ្ធិសេរីភាព នៅក្នុងសង្គមប្រជាធិបតេយ្យរាជរដ្ឋាភិបាល មានកាតព្វកិច្ចត្រូវតែការពារនូវសិទ្ធិទាំងនោះរបស់ប្រជាពលរដ្ឋ លើកលែងក្នុងករណីដែលប្រជាពលរដ្ឋណាម្នាក់ប្រើប្រាស់សិទ្ធិនេះដោយរំលោភបំពានទៅលើសិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ (មាត្រា ២)[37]។ ច្បាប់នេះ បានសម្តែងការគាំទ្រដល់ការធ្វើបាតុកម្មអហិង្សារបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយបានបញ្ញត្តិយ៉ាងច្បាស់ពីនីតិវិធីនៃការធ្វើបាតុកម្មដោយសន្តិវិធីនៅទីសាធារណៈ ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែនដី

[35] ច្បាប់ស្តីពីរបបសារព័ត៌មាន, នស/ រកម/ ០៨៩៥/ ០០៧, ០១ កញ្ញា ១៩៩៥, មាត្រា ៥។
[36] ច្បាប់ស្តីពីរបបសារព័ត៌មាន, នស/ រកម/ ០៨៩៥/ ០០៧, ០១ កញ្ញា ១៩៩៥, មាត្រា ៦។
[37] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, លេខ នស/ រកម/ ១២០៩/ ០១២, ០៥ ធ្នូ ២០០៩, មាត្រា ២។

រាជធានី ឬខេត្តដែលមានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ (មាត្រា ៥)[38] ជាពិសេសដើម្បីអោយការធ្វើបាតុកម្មដោយសន្តិវិធីនេះ ប្រព្រឹត្តទៅបានដោយរលូន ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ក៏បានបញ្ជាក់ផងដែរនូវការទទួលខុសត្រូវរបស់អ្នកដឹកនាំធ្វើបាតុកម្ម និង អាជ្ញាធរមានសមត្ថកិច្ច ដោយពួកគេត្រូវសហការជាមួយនគរបាលមូលដ្ឋាន និងកងរាជអាវុធហត្ថដើម្បីទប់ស្កាត់ផលអាក្រក់ដែលនឹងកើតមានដោយការធ្វើកំណត់ផ្លូវខាងលើ អោយមានភាពងាយស្រួល និងសម្រួលចរាចរណ៍សម្រាប់យានយន្ត ដើម្បីកុំអោយមានការរំខានធ្ងន់ធ្ងរដល់ដំណើរការអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម ឬជំនួយផ្សេងៗ (មាត្រា ១៥)[39]។ បទបញ្ញត្តិនៃច្បាប់នេះ ក៏បានហាមឃាត់នៅក្នុងករណីដែលបាតុករណាមានការប្រើប្រាស់ឧបករណ៍ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ ឬអាចបង្កទុក្ខទោសដល់អ្នកដទៃ ឬប្រព្រឹត្តអំពើណាមួយដែលជ្រៀតជ្រែកសិទ្ធិសេរីភាពរបស់អ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតឧបករណ៍ទាំងនោះចេញ ឬហាមប្រាមកុំអោយបាតុករនោះប្រព្រឹត្តអំពើនេះទៀត។ តែប្រសិនបើ បាតុករនោះមានភាពរឹងរូសមិនព្រមបញ្ឈប់អំពើនេះ សមត្ថកិច្ចត្រូវធ្វើការឃាត់ខ្លួនបណ្តោះអាសន្នរហូតដល់បាតុកម្មដោយសន្តិវិធីបានបញ្ចប់សព្វគ្រប់ ទើបធ្វើការដោះលែងវិញ (មាត្រា ៣២)[40]។

#### ១.២.២.៤. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាន ៦៧២មាត្រា។ យោងតាមមាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ គន្ថីទី១ នៃក្រមព្រហ្មទណ្ឌ ត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ ឯបទបញ្ញត្តិផ្សេងទៀត ត្រូវយកទៅអនុវត្តក្នុងរយៈពេល ០១ឆ្នាំក្រោយ ចូលជាធរមាននៃក្រមនេះ។ ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាន ៥ ផ្នែកៗ ធំ ៖

➢ ***ការបរិហារកេរ្តិ៍ និង ការជេរប្រមាថ***

ស្ថិតក្នុងគន្ថីទី២ "បទល្មើសប្រឆាំងនឹងបុគ្គល" មាតិកាទី២ ជំពូកទី៦ ផ្នែកទី២ នៃក្រមព្រហ្មទណ្ឌ ការបរិហារកេរ្តិ៍ និង ការជេរប្រមាថ មានចែកចេញជា បទបរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥) អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន (មាត្រា៣០៦) បទជេរប្រមាថជាសាធារណៈ(មាត្រា៣០៧) អំពើជេរប្រមាថតាមសារព័ត៌មាន (មាត្រា៣០៨) នីតិវិធីបណ្តឹងចំពោះបទបរិហាកេរ្តិ៍ និង បទជេរប្រមាថ (មាត្រា៣០៩) និង ទោសបន្ថែម(មាត្រា ៣១០) ។

[38] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, លេខ នស/ រកម/ ១២០៩/ ០១២, ០៥ ធ្នូ ២០០៩, មាត្រា ៥។
[39] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, លេខ នស/ រកម/ ១២០៩/ ០១២, ០៥ ធ្នូ ២០០៩, មាត្រា ១៥។
[40] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, លេខ នស/ រកម/ ១២០៩/ ០១២, ០៥ ធ្នូ ២០០៩, មាត្រា ២៣។

➢ ***ការគំរាមកំហែងថា នឹងធ្វើការបំផ្លាញ ធ្វើអោយទ្រុឌទ្រោម ឬ ធ្វើអោយខូចខាត***

ស្ថិតក្នុងគន្ថីទ៣ "បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិជាតិ" មាតិកាទី២ ជំពូកទី១ ផ្នែកទី២ នៃក្រមព្រហ្មទណ្ឌ ការគំរាមកំហែងថា នឹងធ្វើការបំផ្លិចបំផ្លាញធ្វើអោយទ្រុឌទ្រោម ឬធ្វើអោយខូចខាត មានចែកចេញជា បទគំរាមកំហែងថា នឹងធ្វើអោយខូចខាត (មាត្រា៤២៣) បទគំរាមកំហែងថានឹងធ្វើអោយខូចខាត ដែលភ្ជាប់នឹងបញ្ជាអ្វីមួយ (មាត្រា៤២៤) បទក្លែងព័ត៌មាន (មាត្រា៤២៥) និង ទោសបន្ថែម (មាត្រា៤២៦)។

➢ ***ការញុះញង់អោយប្រព្រឹត្តបទល្មើស***

ស្ថិតក្នុងគន្ថីទី៤ "បតល្មើសប្រឆាំងនឹងជាតិ" មាតិកាទី១ ជំពូកទី៣ ផ្នែកទី៣ នៃក្រមព្រហ្មទណ្ឌ ការញុះញង់អោយប្រព្រឹត្តបទល្មើស មានចែកចេញជា លក្ខខណ្ឌអត្ថិភាពនៃការញុះញង់ (មាត្រា៤៩៤) បទញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ (មាត្រា៤៩៥) បទញុះញង់អោយមានការរើសអើង (មាត្រា៤៩៦) អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន (មាត្រា៤៩៧) និង ទោសបន្ថែម (មាត្រា៤៩៨)។

➢ ***ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ***

ស្ថិតក្នុងគន្ថីទី៤ "បទល្មើសប្រឆាំងនឹងជាតិ" មាតិកាទី១ ជំពូកទី១ ផ្នែកទោសនៃក្រមព្រហ្មទណ្ឌ ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ មានចែកចេញជា បទប្រមាថ (មាត្រា៥០២) បទប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា៥០៣) ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា៥០៤) បទញុះញង់អោយប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា៥០៥) បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ (មាត្រា៥០៦) និងទោសបន្ថែម (មាត្រា៥០៧)។

➢ ***ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ***

ស្ថិតក្នុងគន្ថីទី៤ "បទល្មើសប្រឆាំងនឹងជាតិ" មាតិកាទី២ ជំពូកទី១ ផ្នែកទី២ ក្រមព្រហ្មទណ្ឌ ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ មានចែកចេញជា បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២០) បទផ្តល់ដោយខុសច្បាប់នូវបញ្ជាអោយឃុំ ឬដោះលែង (មាត្រា ៥២១) បទផ្សព្វផ្សាយនូវអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ (មាត្រា ៥២២) បទធ្វើអោយបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣) បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ (មាត្រា ៥២៤) ការប៉ុនប៉ង (មាត្រា ៥២៥) និងទោសបន្ថែម (មាត្រា ៥២៦)។

### ១.២.២.៥.សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលពត៌មាន

សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានមាន ៩ជំពូក និង ៣៨មាត្រា ដែលតាក់តែងឡើងអស់រយៈពេលជាង ៦ឆ្នាំ ត្រូវបានអន្តរក្រសួងបញ្ចប់ការពិនិត្យទាំស្រុងកាលពីចុងខែវិច្ឆិកា ឆ្នាំ២០០៩ ដោយគ្រោងដាក់

បញ្ជូលច្បាប់នេះទៅទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យសម្រេចដើម្បីដាក់ទៅរដ្ឋសភាអនុម័តជាផ្លូវការនៅដើមខែមករា ឆ្នាំ២០២០។ ធានាអភិវឌ្ឍលើវិស័យព័ត៌មានជាពិសេស សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋកម្ពុជាអោយកាន់តែទូលំទូលាយ និងដោយសេរីស្របតាមច្បាប់ក្រសួងព័ត៌មានដោយបានសហការជាមួយអង្គការ យូណេស្កូ និងប្រទេសស៊ុយអែត[41] បានរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ដែលគិតមកដល់ពេលនេះ (ខែមិថុនា ឆ្នាំ២០២០) សេចក្តីព្រាងនេះ កំពុងស្ថិតក្នុងការរដ្ឋសភាមិនទាន់អនុម័តនៅឡើយ។ ក្នុងដំណាក់កាលនៃសេចក្តីព្រាងនេះ ដោយមានការចូលរួមពីអន្តរក្រសួង រួមជាមួយដៃគូសហការ លើសពីនេះ គឺមានការដាក់អោយមានការបញ្ចេញមតិយោបល់ ការយល់ឃើញរបស់សាធារណៈជនទៅលើសេចក្តីព្រាងច្បាប់នេះ តាមគេហទំព័ររបស់ក្រសួងព័ត៌មានផងដែរ។ យោងតាមមាត្រា១ នៃសេចក្តីព្រាងបឋមនៃច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ច្បាប់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធានាអោយសាធារណជនគ្រប់រូបនូវសិទ្ធិ និងសេរីភាពក្នុងការទទួលបានព័ត៌មាន។ ច្បាប់នេះចែងពី ភារកិច្ចដែលស្ថាប័នសាធារណៈនានាត្រូវផ្តល់ និងធ្វើការផ្សព្វផ្សាយពត៌មានជាសាធារណៈ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ ក្រៅពីមាត្រានេះ នៅមានមាត្រាផ្សេងទៀត ដែលបានបង្ហាញអោយឃើញពីចេតនាក្នុងការកែប្រែ និងធ្វើអោយមានភាពល្អប្រសើរជាងមុន លើការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋខ្មែរស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញ[42]ក៏ដូចជាការកំណត់នូវនិយមន័យពាក្យពេចន៍សំខាន់ៗ ដូចជា ពាក្យពត៌មានប៉ះពាល់ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈជាដើម[43] ការកំណត់ពីសិទ្ធិ និងកាតព្វកិច្ចក្នុងការផ្តល់ពត៌មាន[44] នីតិវិធីស្នើសុំព័ត៌មាន[45] ការកំណត់វិសាលភាពទទួលបានព័ត៌មាន[46] និង ការបង្រួមនូវការទទួលទោសព្រហ្មទណ្ឌអោយស្ថិតក្នុងទំហំតូចជាងមុន[47] ជាដើម។

[41] គេហទំព័រក្រសួងព័ត៌មាន សេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន http://a2i.gov.kh/។

[42] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, មាត្រា ២ (សូមមើលឧបសម្ព័ន្ធទី១)។

[43] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, មាត្រា ៤។

[44] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, ជំពូកទី ២។

[45] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, ជំពូកទី ៣។

[46] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, ជំពូកទី ៤។

[47] សេចក្តីព្រាងច្បាប់បឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន, ជំពូកទី ៥។

# ជំពូកទី ២
# បញ្ហាប្រឈមចំពោះសិទ្ធិ
# បញ្ចេញមតិ

# ជំពូកទី ២

# បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ

ការទទួលស្គាល់នូវលិទ្ធិប្រជាធិបតេយ្យនីតិរដ្ឋ ការគោរពសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជាដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ សបញ្ជាក់អោយឃើញថា កម្ពុជាបានទទួលយកនូវការអនុវត្តតាមគោលការណ៍ទាំងអស់នោះ។ ជាក់ស្តែង ក្នុងការធានាការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននៃសេរីភាពបញ្ចេញមតិប្រទេសកម្ពុជា មាននូវការរៀបចំជាលិខិតបទដ្ឋានដូចបានសិក្សានៅចំណុចខាងលើ ដែលធ្វើយ៉ាងអោយស្របទៅនឹងរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ។ ការអនុវត្តជាក់ស្តែង ទៅលើការធានាប្រើប្រាស់នូវសេរីភាពមួយនេះរបស់ប្រជាពលរដ្ឋអោយស្របតាមច្បាប់ដែលមានជាធរមាន។ ទោះជាយ៉ាងណាក៏ដោយទាំងច្បាប់ និងការអនុវត្តនូវសេរីភាពបញ្ចេញមតិនេះ គឺតែងតែមាននូវបញ្ហាប្រឈមផ្សេងៗ ដែលមិនអាចជៀសបាន។ មុននឹងចូលទៅក្នុងបញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិរបស់ប្រទេសកម្ពុជា សូមក្រឡេកមើលនូវការវិវត្តរបស់សេរីភាពនេះក្នុងប្រទេសកម្ពុជាជាមុនសិន។ ក្រោយពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឬក្រោយពីការកសាងប្រទេសជាថ្មី សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា បានវិវត្តខ្លួនពីមួយដំណាក់កាលទៅមួយដំណាក់កាល។ ការវិវត្តខ្លួននេះ គឺចាប់ពីចំណុចដែលប្រទេសកម្ពុជា ស្ថិតនៅទីតាំងដ៏គួរអោយកត់សម្គាល់មួយនៃការរំលោភបំពានលើសេរីភាពបញ្ចេញមតិ ប្រែក្លាយមកកាន់កម្រិតល្អមួយ មាននូវការផ្តល់សិទ្ធិសេរីភាពបានទូលំទូលាយជាងកាលពីមុន។ ដំណើរវិវត្តខ្លួននៃសេរីភាពបញ្ចេញមតិរបស់ប្រទេសកម្ពុជា មិនមែនមានតែការអង្កេតមើលតែពីសំណាក់ជាតិ ដែលមានដូចជា អង្គការក្រៅរដ្ឋាភិបាល (NGO) អ្នកឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស អ្នកវិភាគឯករាជ្យជាដើមប៉ុណ្ណោះទេ ក៏មានការចូលរួមអង្កេត និងតាមដានពីសំណាក់អន្តរជាតិមកលើស្ថានភាពនៃការគោរពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ជាការអង្កេតពីសំណាក់អន្តរជាតិមកកាន់កម្ពុជា រួមមានអង្គការសហប្រជាជាតិ ដែលជាប្រចាំ តែងតែមាននូវវត្តមាននៃការធ្វើទស្សនៈកិច្ចរបស់អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិមកកាន់កម្ពុជាក្នុងការតាមដាន។

មើលពីខាងក្រៅកម្ពុជាហាក់ដូចជា មានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចម្រុះ មានចំនួនស្ថានីយ៍ទូរទស្សន៍ និងវិទ្យុ ការបោះពុម្ពផ្សាយ និងការបើកអោយប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត។ ខណៈនេះ ទំនាក់ទំនងបង្ហាញថាប្រទេសកម្ពុជា មានទម្រង់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នាច្រើន វាមិនមានន័យថា នេះអាចបំពេញនូវពហុនិយមបានឡើយ។ ផ្ទុយទៅវិញ ពហុនិយមពិតប្រាកដ នឹងត្រូវមានប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់ដណ្តប់បានទូលាយ និងបានច្រើនមុខខុសៗគ្នា ដែលនេះឆ្លុះបញ្ចាំងនូវក្រុមទាំងឡាយ និងទស្សនៈនានានៅក្នុងសង្គម ហើយដែលអាចឮដល់មនុស្សទាំងអស់។ នៅកម្ពុជា ភាពពិតគឺថា លក្ខខណ្ឌដែលសហគ្រាសព័ត៌មានត្រូវបានគេបង្ខំអោយធ្វើការ

តាមបញ្ហានោះ វាពិបាកនឹងអោយមានការចែកចាយនូវទស្សនៈផ្សេងៗគ្នាណាស់។ ហេតុនេះ យើងសង្កេតឃើញថាកម្ពុជាបច្ចុប្បន្ន មានប្រព័ន្ធផ្សព្វផ្សាយចម្រុះគឺ ***ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប***[48]។

## ១.១. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី

### ១.១.១. ការរឹតបន្តឹងចំពោះសិទ្ធបញ្ចេញមតិតាមបែបប្រពៃណី

នៅគ្រប់ប្រទេសលិទ្ធិប្រជាធិបតេយ្យ ទាមទារអោយមាននូវប្រពន្ធផ្សព្វផ្សាយពហុបែបនូវសេរីភាពខាងបញ្ចេញមតិយោបល់ និងនូវសេរីភាពខាងការចែកចាយព័ត៌មានដើម្បីប្រយោជន៍សាធារណៈ។ ប្រព័ន្ធផ្សព្វផ្សាយពហុបែប នឹងបង្កើតលំហដើម្បីជជែកវែកញែក ដោយអនុញ្ញាតអោយមតិយោបល់ខ្វែងគំនិតគ្នា អាចសម្ដែងចេញបាន។ សារពត៌មានដោយឯករាជ្យពេញលេញ គឺជាស្នូលនៃលទ្ធិប្រជាធិបតេយ្យ ដោយសារវាបានផ្ដល់អោយប្រជាពលរដ្ឋនូវការទទួលបានព័ត៌មាន។ ការទទួលបានព័ត៌មាន និងមានមតិខ្វែងគំនិតគ្នាក្នុងវេទិកាសាធារណៈ អនុញ្ញាតអោយប្រជាពលរដ្ឋ អាចធ្វើការជ្រើសរើសដោយត្រឹមត្រូវ និងកំណត់នូវប្រយោជន៍របស់ខ្លួនឯង។ ប្រព័ន្ធផ្សព្វផ្សាយ មានសារៈសំខាន់ដល់ការពង្រឹងរដ្ឋាភិបាលបែបប្រជាធិបតេយ្យតាមរយៈការត្រួតពិនិត្យ តាមដានដោយដាក់ចេញនូវអត្ថបទ និងរឿងរ៉ាវស្ដីពីកិច្ចការសាធារណៈ និងបុគ្គលសាធារណៈ ដែលធានាអោយបាននូវគណនេយ្យភាព តម្លាភាព និងជាគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ ទោះបីជា ប្រព័ន្ធផ្សាយដោយសេរី និង ពហុបែប មានសារៈសំខាន់ដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យយ៉ាងណា ក៏គណៈកម្មការសិទ្ធិមនុស្សអាស៊ីបានរកឃើញថា សេរីភាពខាងសារព័ត៌មាននៅកម្ពុជា ចាប់ផ្ដើមធ្លាក់ចុះជាលំដាប់។ ដោយសារមានការរឹតត្បិតនេះ បានធ្វើអោយមានការយោលយោគរវាងសេរីភាព និងការគាប់សង្កត់ ដែលជាហេតុថា សារពត៌មាន មិនអាចចាត់ទុកថាមានសេរីភាពពេញលេញបានឡើយ។ ជាក់ស្ដែង អ្នកសារព័ត៌មានបន្តប្រឈមនឹងការគំរាម និងការរុកគួនតាមរយៈការប្រើប្រាស់បណ្ដឹងបរិហាកេរ្តិ៍លើអ្នកសារព័ត៌មាន ក្នុងគោលបំណងបំបិទនូវការជជែកវែកញែក និងការពិភាក្សា។ កាសែតណាជំទាស់ ត្រូវបានបង្ខំអោយបិទទ្វារ និងត្រូវតែអព្យាក្រឹត្យ ដូចក្នុងករណីកាសែតស្រឡាញ់ខ្មែរកាលពីឆ្នាំ២០០៦។ កាលពីខែឧសភា ឆ្នាំ២០០៨ ក្រសួងពត៌មាន បានបិទស្ថានីយ៍វិទ្យុអង្គរវដ្ដា ហើយព្យួរអាជ្ញាប័ណ្ណរបស់វិទ្យុនេះ បន្ទាប់ពីវិទ្យុនេះ បានធ្វើការលក់ម៉ោងផ្សាយទៅអោយគណបក្សចំនួន ៤ ជាពិសេស ការរាយការណ៍ពីប្រធានបទរសើប ឬពាក់ព័ន្ធនឹងនយោបាយ[49] ។ គួររំឭកថា កាលពីចុងឆ្នាំ២០១៧ ពោលនៅមុនការបោះឆ្នោតជាតិឆ្នាំ២០១៨ រដ្ឋាភិបាលបានចាត់វិធានការអោយវិទ្យុអាស៊ីសេរីត្រូវបិទការិយាល័យនៅភ្នំពេញ និងបញ្ឈប់ការផ្សាយរបស់វីទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរីមួយរយៈ បន្ទាប់ពីវិទ្យុ

[48] សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យ: ឆឹង ស៊ីនាង ទំព័រ ១០០។
[49] សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យ: ឆឹង ស៊ីនាង ទំព័រ ៩៩។

នេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចោទថា សារព័ត៌មាននេះ ជំពាក់ពន្ធរដ្ឋាភិបាលជាង ៦ លានដុល្លារអាមេរិក ក្រោយពីប្រតិបត្តិការបានជិត ២០ឆ្នាំ[50]។

### ១.១.១.១. សិទ្ធិទទួលបានពត៌មាន

សិទ្ធិទទួលបានព័ត៌មាន ត្រូវបានចាត់ទុកថាជាគ្រឹះដ៏សំខាន់មួយ ដែលប្រជារដ្ឋគ្រប់រូបមិនអាចខ្វះបាន ដោយសារសិទ្ធិនេះ ចូលរួមចំណែកក្នុងការទទួលបានសិទ្ធិមនុស្សយ៉ាងពេញលេញរបស់ពលរដ្ឋក្នុងប្រទេសនីមួយៗ ទាក់ទិននឹងសិទ្ធិបញ្ចេញមតិនេះផងដែរ។ ពលរដ្ឋ មានលទ្ធភាពក្នុងការបញ្ចេញមតិរបស់ខ្លួនបានដោយការស្វែងយល់ពីមជ្ឈដ្ឋាន និងបរិបថរបស់សង្គមដែលគេរស់នៅ ហើយការទទួលបានព័ត៌មាននេះ ជាទូទៅត្រូវបានផ្តល់អោយរដ្ឋ ពោលគឺរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ។

ជាគោលការណ៍រដ្ឋាភិបាល ដែលជាតួអង្គយ៉ាងសំខាន់ក្នុងការផ្តល់នូវព័ត៌មានដល់ប្រជាពលរដ្ឋ រដ្ឋាភិបាលមានកាតព្វកិច្ច និងប្រើប្រាស់អោយអស់ពីលទ្ធភាពនូវគ្រប់មធ្យោបាយក្នុងការបញ្ជូនព័ត៌មាន និងផ្តល់ពត៌មានទាំងអស់នោះទៅដល់ពលរដ្ឋរបស់ខ្លួន តាមរយៈមធ្យោបាយដូចជា ៖

**ក. ទូរទស្សន៍ និង វិទ្យុ**

ផ្សព្វផ្សាយ ជាពិសេសនូវពត៌មានជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងសិទ្ធបញ្ចេញមតិរបស់ប្រជាពលរដ្ឋចំពោះការអភិវឌ្ឍន៍ និងការជិះជាន់គាបសង្កត់ពីក្រុមហ៊ុនឯកជន ដែលមានអ្នកមានអំណាចនៅពីក្រោយមកលើប្រជាពលរដ្ឋ។ បច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍រាល់គំរោងការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ត្រូវតែធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋអោយបានដឹងដំណឹងជាមុន អំពីគុណសម្បត្តិ និងគុណវិបត្តិ។ ផ្ទុយទៅវិញ រាល់តំបន់ដែលរាជរដ្ឋាភិបាល ឬក្រុមហ៊ុនឯកជនចង់អភិវឌ្ឍ គឺតែងតែមានផលប៉ះពាល់ ឬបញ្ហាផ្សេងៗទៀត។ ប៉ុន្តែ រាល់ផលប៉ះពាល់ ឬបញ្ហា មិនបានផ្សព្វផ្សាយអោយបានទូលំទូលាយដល់ប្រជាពលរដ្ឋ ឬសាធារណជននោះទេ។ ចំពោះបញ្ហាសិទ្ធិបញ្ចេញមតិ មិនថានៅលើទូរទស្សន៍ ឬក្នុងវិទ្យុទេ គឺពុំសូវមានការចាក់ផ្សាយអោយបានពេញនៅឡើយទេ ព្រោះថាសិទ្ធិបញ្ចេញមតិនាពេលបច្ចុប្បន្ន កំពុងធ្លាក់ចុះដល់ចំណុចមួយគួរអោយកត់សម្គាល់ជាខ្លាំង។ នៅឆ្នាំ២០១៥ បណ្តាញអ៊ីនធឺណេត ឬFacebook បានក្លាយជាប្រភពពត៌មានដ៏សំខាន់ទី១សម្រាប់ពលរដ្ឋខ្មែរ ហើយអ្នកប្រើប្រាស់បណ្តាញនេះដើម្បីទទួលព័ត៌មាន មានចំនួន៣០ភាគរយ គឺបានវ៉ាប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ និងវិទ្យុភាគច្រើនដែលគ្រប់គ្រងដោយរដ្ឋ ឬស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋា

[50] Cambonomist, https://cambonomist.com/news/govt-approved-voc-khmer-office-registration/ .

ភិបាល ដែលមានអ្នកប្រើប្រាស់២៩ភាគរយ សម្រាប់ទូរទស្សន៍ និង១៥ភាគរយសម្រាប់វិទ្យុ។ នេះបើយោងតាមរបាយការណ៍សិក្សាស្រាវជ្រាវមួយរបស់អង្គការមូលនិធិអាស៊ី Asia Foundation[51]។

### ខ. កាសែត និង ទស្សនាវដ្ដី

សារព័ត៌មាននៅក្នុងប្រទេសកម្ពុជា មានជាងប្រមាណ ១០០ ប៉ុណ្ណោះ ទោះជាយ៉ាងណា មានសារព័ត៌មានតិចតួចប៉ុណ្ណោះ ដែលរក្សាកាលវិភាគបោះពុម្ពផ្សាយទៀងទាត់ និងបានបង់ថ្លៃបុគ្គលិក។ កាសែត និងទស្សនាវដ្ដីជាច្រើន ត្រូវបានគ្រប់គ្រងដោយគណបក្សនយោបាយ ឬបុគ្គលអ្នកនយោបាយ។ ដូច្នេះ ការផ្សព្វផ្សាយព័ត៌មាន មានលក្ខណៈលំអៀង។ ជាក់ស្ដែង នាពេលបច្ចុប្បន្នគ្រប់កាសែត ឬទស្សនាវដ្ដី មិនសូវហ៊ានសរសេរអំពីការរិះគន់អំពីគណបក្សកាន់អំណាច អំពីផលប៉ះពាល់នៃដំណើរការគ្រប់គ្រងប្រទេសគ្រប់ផ្នែកគ្រប់វិស័យទេ។ ជាក់ស្ដែង ដូចជានៅតំបន់បឹងកក់ គ្មានកាសែត ឬទស្សនាវដ្ដីណា ហ៊ានចុះផ្សាយអំពីបញ្ហាប្រឈមដែលកើតមានឡើងនៅតំបន់នោះ អោយបានទូលំទូលាយទេ។ ពេលខ្លះ អ្នកយកព័ត៌មាននឹងទាមទារការទូទាត់ពីប្រភពរបស់ពួកគេដើម្បីរក្សារឿងអាស្រូវ ដោយមិនគិតថាតើពិត ឬមិនពិតនោះទេ។[52] សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) និងក្លឹបអ្នកសារព័ត៌មានបរទេសនៅកម្ពុជា (OPCC) បានលើកឡើងថា សេរីភាពសារព័ត៌មាននៅកម្ពុជាក្នុងរយៈពេល៤ខែចុងក្រោយនេះនៅតែបន្តរងការគំរាមកំហែងពីអ្នកមានអំណាចតាមរយៈការចោទប្រកាន់របស់តុលាការ ឬការចាប់ដាក់ពន្ធនាគារ។

### គ. សិក្ខាសាលា

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ផ្នែកសិទ្ធិបញ្ចេញមតិ គឺកំពុងតែមានការប្រឈមជាច្រើនដូចជានៅព្រឹកថ្ងៃអាទិត្យ ទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកបណ្ឌិត កែម ឡី ត្រូវបានខ្មាំងកាំភ្លើងធ្វើការបាញ់ប្រហារលើរូបលោកធ្វើអោយលោកបានបាត់បង់ជីវិតនៅនឹងកន្លែង។ លោកគឺជាអ្នកសិក្សាស្រាវជ្រាវដល់ទីកន្លែងផ្ទាល់ដើម្បីរកការពិតលើរឿងរ៉ាវមួយចំនួនធំដែលពាក់ព័ន្ធនឹងនយោបាយ ជាពិសេសក្នុងវិស័យអភិបាលកិច្ច និងយុត្តិធម៌សង្គម។ តាមរយៈការសិក្សាស្រាវជ្រាវ ដោយលោកធ្វើការកត់ត្រាចងក្រងឡើងជាសៀវភៅ ដើម្បីយកមកផ្សព្វផ្សាយ និងចែករំលែកអោយប្រជាពលរដ្ឋបានដឹងពីបញ្ហាទាំងលើ។ ហើយលោកក៏ជាអ្នកនិយាយការពិត

[51] វីអូអេ៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.html .

[52] សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យៈ ឆឹង ស៊ីនាង ទំព័រ ៨៩។

ជាក់ស្តែងអស់ទាំងនោះដោយត្រង់ៗ និងតាមរយៈរឿងនិទាន នៅក្នុងវេទិកានានា តាមវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។[53]

### ១.១.១.២. សិទ្ធិស្វែងរកពត៌មាន

សិទ្ធិស្វែងរកព័ត៌មាន ដោយគ្រាន់តែពឹងផ្អែកលើព័ត៌មានដែលបានផ្តល់អោយដោយរដ្ឋាភិបាលតែមួយផ្នែកមិនអាចជុំរុញអោយមានការបញ្ចេញមតិពេញលេញ និងត្រឹមត្រូវនោះទេ។ ប្រជាពលរដ្ឋខ្លួលឯង ក៏មានសិទ្ធក្នុងការស្វែងរកព័ត៌មាន តាមគ្រប់មធ្យោបាយតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើឲ្យសេរីភាពនៃការបញ្ចេញមតិមានលក្ខណៈទូលំទូលាយ និងប្រត្យក្ស។ ជាឧទាហរណ៍ នៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន ការទទួលបាននូវពត៌មាននៅមានភាពខ្វះចន្លោះនៅឡើយ ដោយសាររដ្ឋាភិបាលរបស់ប្រទេសទាំងនោះ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយពត៌មានពលរដ្ឋរបស់ខ្លួនអោយមានលក្ខណៈទូលំទូលាយ និងពេញលេញបានទេ។ ដូចនេះ ពលរដ្ឋអាចធ្វើការស្វែងរកពត៌មានបានដោយខ្លួនឯង តាមរយៈមធ្យោបាយជាច្រើនផ្សេងៗគ្នា ជាពិសេសតាមរយៈប្រព័ន្ធអ៊ីនធើណែតដែលមានការពេញនិយមប្រើប្រាស់។

#### ក. ទូរទស្សន៍ និង វិទ្យុ

មានមុខងារផ្សព្វផ្សាយជាប្រចាំនូវព័តមានថ្មីៗ ដែលមានប្រភពច្បាស់លាស់ ពិតប្រាកដអាចទទួលយកបាន ដែលកើតមានឡើងជាប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជា ដែលទាក់ទងនឹងការអភិវឌ្ឍន៍ប្រទេសជាតិ ការប្រកាសសារាចរណ៍ណែនាំផ្សេងៗរបស់ក្រសួង និងបញ្ហានយោបាយ។ ប្រជាពលរដ្ឋ អាចតាមដាន និងស្វែងយល់ដោយខ្លួនឯង តាមរយៈទូរទស្សន៍ និងវិទ្យុបានដោយងាយស្រួលអំពីពត៌មានខាងលើ។ ប៉ុន្តែជាក់ស្តែងនាពេលបច្ចុប្បន្ន គេឃើញសង្កេតឃើញថា ប្រភពដែលផ្តល់ពត័មានខាងលើ គឺមានការលំអៀងទៅរកខាងរាជរដ្ឋាភិបាល ដោយមិនហ៊ានផ្សព្វផ្សាយពត័មានពិតដែលកើតឡើងនៅក្នុងសង្គម ដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រទេសជាតិ។ ឧទាហរណ៍ អំពីពត៌មានព្រំដែន ដែលជាចំណុចរសើបរបស់រាជរដ្ឋាភិបាលដែលថ្មីៗនេះ គឺនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២០ មានការសម្រេចយកការបោះបង់គោលព្រំដែនដោយតាមផែនទីខ្នាត ១/២៥០០០ ភាគីទាំងពីរ បានឯកភាពគ្នានូវផែនទីភូមិសាស្ត្រព្រំដែនចំនួន ៥០០។[54] ប៉ុន្តែ គ្មានការចាក់ផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុអោយបានទូលំទូលាយ ដើម្បីអោយប្រជាពលរដ្ឋបានដឹងពីពត៌មានមួយនេះទេ។

---

[53] កម្រងទស្សនសង្គម និង នយោបាយ ចងក្រងដោយសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ឆ្នាំ ២០១៦ ។

[54] ការវិវឌ្ឍលើបញ្ហាព្រំដែន កែសម្រួលដោយ ហួន ឌីណា៖ https://www.khmertimeskh.com .

**ខ. កាសែត និង ទស្សនាវដ្តី**

គ្រប់បញ្ហា គ្រប់ហេតុការណ៍ គ្រប់ស្ថានភាព ដែលកើតមានឡើងនៅក្នុងប្រទេសប្រជាពលរដ្ឋអាចស្វែងរកតាមរយៈការអានកាសែត និងទស្សនាវដ្តី ដែលមានចុះផ្សាយជារៀងរាល់ថ្ងៃបាន។ ប៉ុន្តែនៅរយៈពេលចុងក្រោយនេះយើងអាចនិយាយបានថា ការគាបសង្កត់ ការបំបិទសិទ្ធិ ការហាមឃាត់តាមគ្រប់មធ្យោបាយទៅលើស្ថាប័នទាំងពីរនេះ។ ដូច្នេះ ប្រជាពលរដ្ឋពិបាកស្វែងរកពត៌មានពិតប្រាកដ ដែលមានប្រភពច្បាស់លាស់ និង អាចទុកចិត្តបានណាស់។

**គ. សិក្ខាសាលា**

ប្រជាពលរដ្ឋ អង្គការសមាគម ឬអង្គការសង្គមស៊ីវិល មានសិទ្ធិចូលរួមក្នុងសិក្ខាសាលាណា ដែលទាក់ទងនឹងពត៌មានដែលខ្លួនចង់ស្វែងរកដើម្បីធ្វើការចែករំលែក។ ប៉ុន្តែ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះមានការរឹតត្បិតលើការធ្វើសិក្ខាសាលាទាក់ទងនឹងពត៌មានជាសាធារណៈណាស់ ជាពិសេស ពត៌មានអំពីបញ្ហាសង្គម ផលប៉ះពាល់អំពីការអភិវឌ្ឍ និងបញ្ហានយោបាយ។ ដូចនេះ ការស្វែងរកពត៌មានតាមរយៈសិក្ខាសាលា បើគិតជាភាគរយ គឺតិចតួចបំផុតសម្រាប់ការចែករំលែកពីសំណាក់វាគ្មិន។

### ១.១.១.៣. សិទ្ធិផ្សព្វផ្សាយពត៌មាន

ក្រោយពីទទួលបាននូវពត៌មាន និងស្វែងរកបន្ថែមនូវពត៌មានទាំងនោះហើយ ប្រជាពលរដ្ឋគ្រប់រូប នៅមានសិទ្ធិជាមូលដ្ឋានមួយទៀត គឺសិទ្ធិក្នុងការផ្សព្វផ្សាយនៅពត៌មានទាំងនោះ ដើម្បីបញ្ជាក់ពីលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់របស់ពលរដ្ឋ ក្នុងការបញ្ចេញមតិរបស់ពួកគេ។ សិទ្ធិក្នុងការផ្សព្វផ្សាយពត៌មានបានអនុញ្ញាតអោយពលរដ្ឋធ្វើការផ្សព្វផ្សាយនូវគំនិត យោបល់ ឬការយល់ឃើញរបស់ពួកគេ ដោយធ្វើចែករំលែកនូវពត៌មានទាំងនោះទៅអ្នកដទៃយ៉ាងសេរី និងទូលំទូលាយ។ នៅក្នុងទិដ្ឋភាពសង្គមទូទៅ ការផ្សព្វផ្សាយពត៌មាន ត្រូវបានធ្វើឡើងតាមគ្រប់មធ្យោបាយទាំងអស់ ដូចជា ការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ ប្រព័ន្ធអ៊ីនធឺណេតជាដើម។ ជាក់ស្តែងការចែករំលែកពត៌មានរបស់ពលរដ្ឋទាក់ទងនឹងនិន្នាការនយោបាយ ឬទស្សនៈរបស់បុគ្គលម្នាក់ៗ ទាក់ទងនឹងបញ្ហានយោបាយ ត្រូវបានអនុញ្ញាតអោយមានការផ្សព្វផ្សាយយ៉ាងពេញលេញ ដោយហេតុថាការផ្សព្វផ្សាយជាសាធារណៈ អំពីទស្សនៈរបស់បុគ្គលម្នាក់ៗ ស្តែងចេញអោយឃើញពីការចូលរួមក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការបញ្ចេញមតិមានភាពពេញលេញ។ ប៉ុន្តែ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាមើលអោយស៊ីជម្រៅ គឺបានត្រឹមតែល្អមើលប៉ុណ្ណោះខាងផ្នែកសិទ្ធិមនុស្ស ព្រោះថា គ្មានស្ថាប័នពត៌មានណាហ៊ានផ្សព្វផ្សាយពត៌មានពិតទេ។

**ក. ទូរទស្សន៍ និង វិទ្យុ**

វិទ្យុអាស៊ីសេរី បានសម្រេចបិទការិយាល័យរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងមក ដោយថាការសម្រេចចិត្តនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីមានការបង្ក្រាបមកលើសំឡេងឯករាជ្យឥតស្រាកស្រាន្តពីសំណាក់រដ្ឋាភិបាលកម្ពុជា។ វិទ្យុអាស៊ីសេរី បានសម្រេចផ្អាកការផ្សាយបន្ទាប់ពីក្រសួងព័ត៌មាន បានសម្រេចហាមឃាត់វិទ្យុក្នុងស្រុកចំនួនជាង ៣0 ស្ថានីយ៍ មិនឱ្យផ្សាយបន្តផ្ទាល់នូវកម្មវិធីព័ត៌មានរបស់វិទ្យុអាស៊ីសេរី វិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុសំឡេងប្រជាធិបតេយ្យ(VOD)ផងដែរ។ វិទ្យុមួយនេះបានប្រកាសបិទការិយាល័យរបស់ខ្លួនតែមួយសប្តាហ៍ប៉ុណ្ណោះ ក្រោយពីកាសែតឌឺ ខេមបូឌា ដេលី (The Cambodia Daily) ដែលចេញផ្សាយប្រចាំថ្ងៃជាភាសាអង់គ្លេសនោះ បានសម្រេចបញ្ឈប់ការចេញផ្សាយរបស់ខ្លួនផងដែរជុំវិញបញ្ហាពន្ធ ៦.៣ លានដុល្លារ ដែលរដ្ឋាភិបាលកម្ពុជាអះអាងថា កាសែតមួយនេះ មិនបានបង់ពន្ធក្នុងរយៈពេល ១0ឆ្នាំចុងក្រោយ[55]។ នេះគ្រាន់តែជាការយកលេសពីសំណាក់រាជរដ្ឋាភិបាលប៉ុណ្ណោះ មូលហេតុដែលឈានទៅដល់ការបិទវិទ្យុនេះ ដោយសារតែវិទ្យុនេះ ធ្វើការផ្សព្វផ្សាយពត៌មានពិត ដែលធ្វើអោយប៉ះពាល់រាជរដ្ឋាភិបាល។

**ខ. ការសែត និង ទស្សនាវដ្ដី**

សេរីភាពសារព័ត៌មាននៅកម្ពុជា បានធ្លាក់ចុះចាប់តាំងពីពាក់កណ្ដាលឆ្នាំ២០១៧ ដោយសារការបង្ក្រាបរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាពិសេស ទៅលើអ្នកកាសែត និងទស្សនាវដ្ដីដែលនៅសេសសល់បន្តិចបន្តួចក្នុងប្រទេស មុនការបោះឆ្នោតសកលកាលពីខែកក្កដា ឆ្នាំ២០១៨។ នេះបើយោងតាមអង្គការអ្នកសារពត៌មាន គ្មានព្រំដែន ដែលបានទម្លាក់ចំណាត់ថ្នាក់នៃសេរីភាពសារពត៌មានរបស់កម្ពុជារហូតដល់លំដាប់ទី ១៤២ ក្នុងចំណោមប្រទេសចំនួន ១៨0 នៅទូទាំងពិភពលោក។ ចំណាត់ថ្នាក់នេះ មានន័យថា សេរីភាពសារពត៌មាននៅកម្ពុជា បានធ្លាក់ចុះ ១0 កម្រិតថែមទៀត បើធៀបនឹងចំណាត់ថ្នាក់កាលពីឆ្នាំ ២០១៧។ ប៉ុន្តែ រដ្ឋាភិបាលតែងតែឆ្លើយបដិសេធថា ខ្លួនមិនបានបង្ក្រាបទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យណាមួយទេ រដ្ឋាភិបាលគ្រាន់តែអនុវត្តច្បាប់របស់កម្ពុជាប៉ុណ្ណោះ។[56]

**គ. សិក្ខាសាលា**

គោលដៅរបស់ការធ្វើសិក្ខាសាលារបស់វាគ្មិន គឺការចែករំលែកចំណេះដឹងដែលខ្លួនបានមកពីការទទួលបានពត៌មាន ការស្វែងរកព័ត៌មាន យកមកពិភាក្សាជាមួយក្រុមការងារ រួចទើបយកមកធ្វើការចែករំលែក។ ប៉ុន្តែនាពេលបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា គឺធ្វើសិក្ខាសាលាទាក់ទងនឹងការផ្សព្វផ្សាយពត៌មានទាក់ទងនឹងបញ្ហា

[55] https://vodkhmer.news/2019/11/25/local-radios-welcome-the-return-of-u-s-funded-radios/ .
[56] អត្ថបទ៖ សេរីភាពសារព័ត៌នៅកម្ពុជា និងជុំវិញពិភពលោក៖ https://khmer.voanews.com/p/7013.html .

ដែលកើតមាននៅក្នុងសង្គមគឺត្រូវបានរាជរដ្ឋាភិបាលហាមឃាត់។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំមួយស្តីពីការទប់ស្កាត់ការធ្វើសកម្មភាព ឬឃោសនានយោបាយនៅតាមបណ្តាលគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។ សេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងអប់រំ លោក ហង់ ជួនណារ៉ុន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ដោយហាម សមាគម អង្គការ បុគ្គលិកអប់រំ និងគ្រូបង្រៀនជាប់កិច្ចសន្យាមួយចំនួនមិនអោយធ្វើសកម្មភាពផ្សព្វផ្សាយពត៌មានអ្វីទាក់ទងនឹងនយោបាយឡើយ។ ក្រសួងចាត់ទុកទង្វើនេះ ថាជាការជ្រៀតជ្រែកការងារផ្នែកអប់រំ និងប៉ះពាល់ដល់សណ្តាប់ធ្នាប់ក្នុងសាលាដែលផ្ទុយនឹងគោលការណ៍អព្យាក្រឹត្យភាពរបស់គ្រឹះស្ថានសិក្សា។ ប៉ុន្តែផ្ទុយទៅវិញ រដ្ឋាភិបាលគ្រាន់តែចង់បំបិទសិទ្ធិសេរីភាពបញ្ចេញមតិ ដោយតែកុំអោយសិស្សានុសិស្សយល់ដឹង និងចាប់អារម្មណ៍ពីបញ្ហានយោបាយតែប៉ុណ្ណោះ។

### ១.១.១.៤. ការរឹតបន្តឹងចំពោះសិទ្ធិបង្កើតសមាគម

ការបង្កើតសមាគមមួយ គឺជាមធ្យោបាយដ៏មានឥទ្ធិពលបំផុតសម្រាប់មនុស្សទាំងអស់គ្នា ដើម្បីជំរុញប្រយោជន៍រួមរបស់ពួកគេអោយជឿនលឿនទៅមុខ និងដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វប្បធម៌ ឬបញ្ហាផ្សេងៗ ទៀតណាមួយរបស់ពួកគេ។ ឧទាហរណ៍ កម្មករបង្កើតសហជីពកម្មករ ដើម្បីទាមទារសិទ្ធិ និងផលប្រយោជន៍កម្មកររបស់ខ្លួន។ ដើម្បីការពារសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស សម្រាប់ការបង្កើតក្រុមណាមួយ ច្បាប់ធានានូវសិទ្ធិមនុស្សជាមូលដ្ឋានចំពោះសិទ្ធិនៃការបង្កើតសមាគម។ សិទ្ធិនេះ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិនយោបាយ និងសិទ្ធិស៊ីវិលដ៏សំខាន់បំផុតជាច្រើនទៀត ពីព្រោះវាអាចធ្វើអោយប្រជាជនធ្វើសកម្មភាពក្នុងមធ្យោបាយមួយដ៏រឹងមាំ និងមានឥទ្ធិពលដោយឯករាជ្យលើអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ នៅខាងក្រៅរចនាសម្ព័ន្ធចាត់តាំងរបស់រដ្ឋ និងរដ្ឋាភិបាលនៅក្នុងផ្នែកឯកជន។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដើម្បីគូសបញ្ជាក់ថា សេរីភាពនៃការបង្កើតសមាគម គឺជាសិទ្ធិពីកំណើតរបស់មនុស្សគ្រប់រូប ហើយវាមិនមែនគ្រាន់តែជាបុព្វសិទ្ធិដែលរដ្ឋអាច ឬមិនអាចផ្តល់អោយតាមឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ។ ដូច្នេះ ពុំមានការចាំបាច់ណាមួយ ដើម្បីសុំការអនុញ្ញាតបង្កើតសមាគមឡើយ គ្រាន់តែជូនដំណឹងដល់អាជ្ញាធរដល់អាជ្ញាធរអំពីការបង្កើតសមាគម និងការចុះបញ្ជីឈ្មោះតែប៉ុណ្ណោះ[57]។ ប៉ុន្តែសេចក្តីជូនដំណឹងលេខ ០៦១/ ០១/ ២០១៨ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨។ ការធ្វើសេចក្តីព្រាងវិសោធនកម្មលើកទី ៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលមាន មាត្រា ៣៤ ថ្មី មាត្រា ៤២ មាត្រា៥៣ និង មាត្រា ១១៨ ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិមួយចំនួន ដែលតម្រូវអោយគណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ។ ការធ្វើវិសោធនកម្មជាបន្តបន្ទាប់មកនេះ ត្រូវបានច្បាប់លើកឡើងថា ធ្វើអោយរដ្ឋធម្មនុញ្ញចុះទន់ខ្សោយ និង ប៉ះពាល់ប្រព័ន្ធប្រជាធិបតេយ្យ

[57] សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យៈ ឆឹង ស៊ីនាង ទំព័រ ៩០។

និង សិទ្ធិមនុស្សធ្ងន់ធ្ងរ។ បទញ្ញត្តិថ្មីទាំងនេះ មានខ្លឹមសារគួរអោយបារម្ភទាក់ទងនឹងសេរីភាពសមាគម។ មាត្រា ៤២ និងមាត្រា ៤៩ ហាមប្រាមសកម្មភាពណាមួយទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលនាំអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ។ បន្ថែមលើនេះ មាត្រា ៥៣ ចែងថា ព្រះរាជាណាចក្រកម្ពុជា ប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ [58] ។ វិសោធនកម្មទាំងនេះ ត្រូវបានអនុម័តដោយពុំមានការពិគ្រោះយោបល់ពេញលេញ ដែលអ្នកជំនាញអង្គការសហប្រជាតិលើកឡើងថា ធ្វើអោយប៉ះពាល់ដល់លិទ្ធិប្រជាធិបតេយ្យ[59]។ អង្គការសង្គមស៊ីវិលក៏បានលើកឡើងពីក្តីបារម្ភចំពោះការដាក់ទោសទណ្ឌហួសហេតុលើ នីតិបុគ្គលតាមរយៈបញ្ញត្តិប្រមាថព្រះមហាក្សត្រដូចលើកឡើងខាងលើផងដែរ។ បន្ថែមលើការទទួលខុសត្រូវទាំងស្រុង ចំពោះបទល្មើសប្រព្រឹត្តឡើងដោយតំណាងអង្គភាព នីតិបុគ្គលនោះប្រឈមនឹងទោសពិន័យជាប្រាក់ដោយពុំសមាមាត្រ ឬអាចឈានដល់ការរំលាយស្ថាប័ន។ ទាក់ទងនឹងខ្លឹមសារទូលំទូលាយនៃបទប្បញ្ញត្តិនេះ អង្គការសង្គមស៊ីវិល អាចត្រូវបានរារាំងការអនុវត្តនូវសេរីភាពជាមូលដ្ឋានរបស់ពួកគេ [60] ។ មានការលើកឡើងថា មានអង្គការមួយចំនួនស្ថិតក្រោមការឃ្លាំមើល និងបំភិតបំភ័យពីសំណាក់អាជ្ញាធរនៅពេលធ្វើសកម្មភាពនានា[61]។ ដូច្នេះយើង អាចនិយាយបានថាប្រទេសសកម្ពុជាស្ថិតនៅក្នុងប្រទេសដែលរំលោភសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន។

### ១.១.១.៥. ការរឹតបន្តឹងចំពោះសិទ្ធិការជួបប្រជុំជាសាធារណៈ

សិទ្ធិការជួបប្រជុំជាសាធារណៈ ជាសេរីភាពខាងការបញ្ចេញមតិរួមចំណែកក្នុងការធ្វើអោយប្រសើរឡើងនូវការទាក់ទងគ្នារវាងគ្នារវាងប្រជាជន និងប្រជាជន ព្រមទាំងធានាអោយការចូលរួមរបស់ពួកគេនៅក្នុងសង្គមមានភាពងាយស្រួល និងធ្វើអោយប្រសើរឡើងនូវការទទួលខុសត្រូវ និងតម្លាភាពនៃដំណើរការបង្កើតមតិ។ នៅក្នុងសង្គមប្រជាធិបតេយ្យ និងពហុបក្សប្រជាជនអាចអនុវត្តនូវសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេតាមរបៀបផ្សេងៗគ្នាជាច្រើន។ ពេលប្រជាជនប្រមូលផ្តុំគ្នាដើម្បីបញ្ចេញមតិ ពួកគេអនុវត្តនូវសេរីភាពខាងការប្រជុំរបស់គេ វាគឺជាសេរីភាពដែលកើតពីធម្មជាតិ វាមិនមែនជាអភ័យឯកសិទ្ធិដែលអាចត្រូវផ្តល់ ឬមិនត្រូវផ្តល់

---

[58] សេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិល «អង្គការសង្គមស៊ីវិលសូមអំពាវនាវអោយច្រានចោលនូវសេចក្តីព្រាងវិសោធកម្មលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ» ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ http://www.licadho-cambodia.org/preerelease.php?perm=431 .

[59] អ្នកជំនាញអង្គការសហប្រជាជាតិលើកឡើងថា វិសោធកម្មរដ្ឋធម្មនុញ្ញនៅកម្ពុជាប៉ះពាល់ដល់លិទ្ធិប្រជាធិបតេយ្យ ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ https://www.ohchr.org/EN/NewEvets/DisplayNews.aspx?NewsID=22674&LangID=E .

[60] របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន ដែលអនុវត្តរួមគ្នាដោយ ម.ស.ម.ក សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨
https://cchrcambodia.org/admin/media/report/report/english/FFMP_Second%20Annual%Report_EN.pdf .

[61] ដូច ៥៥ ទំព័រ ២០។

អោយដោយរដ្ឋាភិបាលក្នុងនាមឆន្ទានុសិទ្ធិឡើយ ពោលគឺ វាជាសិទ្ធិដែលមិនអាចដកហូត ឬផ្ទេរបា[62]។ ក្រោយមក មុនពេលការបោះការឆ្នោតក្នុងខែកក្កដា ឆ្នាំ ២០១៨ សេរីភាពខាងការជួបប្រជុំ បន្តរងការប៉ះពាល់។ មន្ត្រី និងប្រជាជន បានគំរាមចាត់វិធានការជាបន្តបន្ទាប់ដើម្បីបញ្ឈប់បុគ្គលទាំងឡាយ ដែលអំពាវនាវអោយធ្វើពហិការបោះឆ្នោតដោយអះអាងថា ការអំពាវនាវនេះពុំត្រឹមត្រូវតាមច្បាប់កម្ពុជា។ ការធ្វើបាតុកម្មដោយសន្តិវិធី ជារឿយៗ ត្រូវបានអាជ្ញាធរបំបែក ហើយពេលខ្លះឈានដល់ការប្រើប្រាស់អំពើហិង្សា។ នៅខែមីនា ឆ្នាំ២០១៨ កងកម្លាំងសន្តិសុខ និងមន្ត្រីនគរបាល រារាំងអ្នកសារព័ត៌មាន អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ និងសកម្មជនសិទ្ធិមនុស្សពីការចូលរួមសវនាការឧទ្ធរណ៍លើករណីលោក គឹម សុខា ដោយបានដាក់របាំងបិទផ្លូវឆ្ពោះទៅកាន់តុលាការ។ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ត្រូវបានកម្លាំងសន្តិសុខទះកំផ្លៀង ខណៈកំពុងកាន់សារគាំទ្រលោក គឹម សុខា។ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ និងមន្ត្រីជាច្រើននាក់ទៀត ត្រូវបានរារាំងការផ្តល់សម្ភាសន៍ទៅអ្នកសារព័ត៌មានអំពីព្រឹត្តិការណ៍នេះ។ រដ្ឋាភិបាល នៅតែបន្តអះអាងថា នោះជាការប៉ុនប៉ងធ្វើបដិវត្តន៍ពណ៌នៅពេលធ្វើការរឹតត្បិតលើសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការជួបប្រជុំ។ តាមរយៈរបាយការណ៍មួយ ដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានកត់ត្រាករណីរំលោភសិទ្ធិជួបប្រជុំពីខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ បានបង្ហាញថាមានការហាមប្រាមលើការជួបប្រជុំចំនួន ២៦ ករណី។ ភាគច្រើននៃករណីទាំងនោះពាក់ព័ន្ធនឹងការរំលាយគណបក្សសង្គ្រោះជាតិ និងលោក កឹម សុខា ដែលនេះបង្ហាញពីចលនារបស់រដ្ឋាភិបាលក្នុងការបង្ក្រាបលើអ្នកមាននិន្នាការជំទាស់ផ្នែកនយោបាយ[63]។

## ១.២. បញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបទំនើប

ចំណុចដែលគួរអោយព្រួយបារម្ភបំផុតសម្រាប់អនាគតនៃបណ្តាសារព័ត៌មានទំនើប គឺគោលបំណងរបស់ររដ្ឋាភិបាល ដើម្បីអនុម័តច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេតដំបូងបង្អស់នៅកម្ពុជា។ កំណត់ត្រាទាក់ទងនឹងទិដ្ឋភាពទូទៅនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប នៅក្នុងព្រះរាជាណាចក្រកម្ពុជាការវិវត្តន៍បច្ចុប្បន្ន ឆ្ពោះទៅរកការគាបសង្កត់លើបណ្តាញអ៊ីនធើណេត និងភាពជាប់ពាក់ព័ន្ធចំពោះសេរីភាពនៃការបញ្ចេញមតិក្នុងប្រទេសកម្ពុជា[64]។ ពលរដ្ឋជាច្រើនលាននាក់ ក្នុងចំណោមពលរដ្ឋខ្មែរប្រមាណ១៥លាននាក់ បាននាំគ្នាប្រើប្រាស់អ៊ីនធឺណិតតាមទូរស័ព្ទដៃ កុំព្យូទ័រ និងឧបករណ៍បច្ចេកវិទ្យាផ្សេងៗទៀត ដើម្បីចូលទៅប្រើ

---

[62] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ២១ និង៤១។

[63] សេរីភាពខាងការជួបប្រជុំ៖ https://cchrcambodia.org/index_old.php?url=our_work/our_work.php&id=3&lang=khm .

[64] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ កំណត់ត្រាសង្ខេបសេរីភាពបញ្ចេញមតិ និងការគាបសង្កត់លើបណ្តាយអ៊ីនធឺណេតនៅកម្ពុជា (ខែមេសា ឆ្នាំ២០១៣)។ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.htm .

ប្រាស់បណ្តាញសង្គមនានា ដូចជា Facebook និងTwitterជាដើម។ បណ្តាញអ៊ីនធឺណិតនេះ បានផ្តល់ដល់អ្នកប្រើប្រាស់នូវមធ្យោបាយទំនាក់ទំនង និងជាប្រភពព័ត៌មានឯករាជ្យមួយនៅក្នុងសង្គមដែលក្រីក្រ និងរងការគាបសង្កត់ជាយូរយាណាស់មកហើយនោះ ។

### ១.២.១. ការរឹតបន្តឹងលើប្រព័ន្ធអ៊ីនធឺណេត

ដោយសារតែ ចំនួនអ្នកប្រើប្រាស់បណ្តាញអ៊ីនធឺណេតក្នុងប្រទេសកម្ពុជា មានការកើនឡើងគួរអោយកត់សម្គាល់ និងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយរដ្ឋាភិបាលធ្វើការវាយតម្លៃពីតួលេខអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតមានចំនួន ២,៧ លាននាក់កាលពីឆ្នាំ២០០៩។ មិនយូរប៉ុន្មាន នៅក្នុងខែធ្នូ ឆ្នាំ២០១២ មានការរាយកាណ៍ថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា បានចេញនូវសារាចរណ៍មួយចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ ដោយអំពាវអោយមានការរើទីតាំងអ៊ីនធឺណេតកាហ្វេទាំងអស់ ដែលមានទីតាំងក្នុងរយៈចំងាយ ៥០០ ម៉ែត្រពីសាលារៀន និងគ្រឹះស្ថានអប់រំនៅក្នុងរាជធានីភ្នំពេញ។ សារាចរណ៍នេះ មានការបង្ខំអោយបិទហាងអ៊ីធឺណេត ការរឹបអូសឧបករណ៍ និងការចាប់ខ្លួន ដោយសារសារាចរណ៍នេះ យកលំនាំតាមច្បាប់គ្រប់គ្រងអ៊ីនធឺណេតដែលមានលក្ខណៈរឹតត្បឹតនៅក្នុងប្រទេសចិន និងវៀតណាម ហើយបានបង្ហាញថាជាដំណាក់កាលមួយទៀត ដើម្បីត្រួសត្រាយផ្លូវអោយច្បាប់ប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណេតរបស់រដ្ឋាភិបាលដែលនឹងប្រកាសអោយអនុវត្ត។ ប៉ុន្តែ ក្នុងអំឡុងពេលប្រមាណ១ឆ្នាំចុងក្រោយនេះ សុទិដ្ឋិនិយមរបស់ក្រុមសកម្មជនអំពីផលវិជ្ជមាននៃការមានអ៊ីនធឺណិត ប្រើប្រាស់កាន់តែច្រើនឡើងនេះ បានប្រែក្លាយទៅការភ័យខ្លាចកាន់តែខ្លាំងឡើងទៅវិញ នៅពេលដែលរដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយសេរីភាពនៃការបញ្ចេញមតិតាមបណ្តាញអ៊ីនធឺណិត និងកាត់បន្ថយការប្រឆាំងផ្នែកនយោបាយ។ លោក ង៉ែត ម៉ូសេ បានថ្លែងថា ទាំងរូបលោក ទាំងអ្នកប្រើប្រាស់បណ្តាញអ៊ីនធឺណិតជាច្រើនទៀត ហាក់មានការប្រយ័ត្នប្រយែងជាងមុន ក្នុងការធ្វើអត្ថាធិប្បាយ ឬបង្ហោះសារទាក់ទងនឹងនយោបាយ ដោយសារតែមានការកើនឡើងនូវសកម្មភាពឃ្លាំមើលខ្លឹមសារតាមបណ្តាញអ៊ីនធឺណិត និងការព្រមាន ឬការចាប់ខ្លួនអ្នកប្រើប្រាស់អ៊ីនធឺណិតជាបន្តបន្ទាប់។ សេរីភាពក្នុងការប្រើប្រាស់អ៊ីនធឺណិតក្នុងប្រទេសកម្ពុជា បើយើងមើលនៅលើ គឺថាបើកទូលំទូលាយច្រើន។ ប៉ុន្តែ នៅពេលដែលយើងមើលទៅលើការអនុវត្តខាងក្នុងវិញ ថាតើប្រជាពលរដ្ឋភ័យខ្លាចក្នុងការនិយាយស្តី ប្រជាពលរដ្ឋភ័យខ្លាចក្នុងការបញ្ចេញមតិខ្លួនឯងអត់នោះ ជាទូទៅរបាយការណ៍យើងមើលឃើញហើយថា ប្រជាពលរដ្ឋនៅតែមានការភ័យខ្លាចដដែលទេ។ ហើយប្រព័ន្ធផ្សព្វផ្សាយដែលជាឧបករណ៍ទំនាក់ទំនងនៅក្នុងប្រទេសកម្ពុជា មិនមែនតែសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជននានា ប្រើប្រាស់ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងបង្ហាញគំនិតនានាដែលមានវែបសាយជាច្រើន ដូចជា ហ្វេសប៊ុក ទូរស័ព្ទដៃ។

### ១.២.១.១. ទូរស័ព្ទដៃ

ប្រទេសកម្ពុជា គឺជាប្រទេសដំបូងក្នុងពិភពលោក ដែលមានទូរស័ព្ទដៃច្រើនជាងទូរស័ព្ទខ្សែ។ ទូរស័ព្ទដៃបានក្លាយជាវិធីដ៏ងាយស្រួល និងមានតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋនៅកម្ពុជាដើម្បីធ្វើការទំនាក់ទំនង។ ដល់ចុងឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរាយការណ៍ថាចំនួនចុះឈ្មោះប្រើប្រាស់ទូរស័ព្ទដៃបានកើនឡើងច្រើនជាង ២០ លាន។ ដោយសារតែ ចំនួនប្រជាពលរដ្ឋមានត្រឹមតែ ១៥ លាននាក់ ចំនួនការប្រើប្រាស់ទូរស័ព្ទដៃជាមធ្យម គឺមនុស្សម្នាក់ប្រើ ១ ទៅ ៣ ទូរស័ព្ទ។ ដូចនេះ ស្ទើរតែ ១០០ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុបត្រូវបានគេជឿជាក់ថា មានទូរស័ព្ទដៃប្រើ ហើយមានចំនួន ៤០ ភាគរយ នៃអ្នកប្រើប្រាស់ទូរស័ព្ទដៃទំនើប្រើ។ ទូរស័ព្ទដៃ គឺមធ្យោបាយមួយក្នុងការប្រើប្រាស់បណ្តាញសារពត៌មានទំនើប បានក្លាយជាវិធីដ៏មានតម្លៃជាខ្លាំងក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។ ទូរស័ព្ទដៃ និងបច្ចេកវិទ្យាអ៊ីនធឺណេតបានបង្កើតលំហថ្មីមួយសម្រាប់រាល់ការពិភាក្សា និងរិះគន់លើរដ្ឋាភិបាល និងស្ថានភាពដដែលៗណា ដែលការធ្វើបែបនេះនឹងមិនអាចធ្វើទៅបានទេក្នុងទម្រង់សារពត៌មានបោះពុម្ពផ្សាយ វិទ្យុ និងទូរទស្សន៍។ ហើយសេវាផ្ញើសារជាអក្សរ បានក្លាយជាវិធីដ៏មានប្រជាប្រិយមួយក្នុងវិស័យទំនាក់ទំនងនៅកម្ពុជា។ ដោយសារតែ លទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃ មានច្រើន បច្ចេកវិទ្យាសារជាអក្សរ ក៏ថែមទាំងត្រូវបានប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាលបំផុតនៅកម្ពុជាប្រើប្រាស់ផងដែរ។ ដូចនេះ ការប្រើសារជាអក្សរ ជាឧបករណ៍តស៊ូមតិផ្នែកសិទ្ធិមនុស្ស ដែលមិនអាចខ្វះបានហើយវាក៏អាចលើកកម្ពស់ និងការពារសិទ្ធិមនុស្សតាមរយៈការថតរូប និងវិឌីអូ[65]។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងប្រៃសណីយ៍ ទូរគមនាគមន៍ និងនាយកដ្ឋាននគរបាលជាតិ បានប្រកាសរួមគ្នាថា នៅត្រឹមថ្ងៃទី២៣ ខែកញ្ញា បទប្បញ្ញត្តិនឹងត្រូវបានចាប់បង្ខំអនុវត្ត ដែលតាមរយៈនេះអ្នកផ្គត់ផ្គង់សេវាកម្មទូរស័ព្ទចល័ត មានកាតព្វកិច្ចក្នុងការផ្គត់ផ្គង់ជូនដល់នគរបាលនូវពត៌មានអត្តសញ្ញាណពិស្តាររបស់អ្នកកាន់កាប់ស៊ីមទូរស័ព្ទទាំងអស់ក្នុងប្រទេសកម្ពុជា [66] ។ ច្បាប់ទូរគមនាគមន៍ថ្មី បានបង្កើនសិទ្ធិអំណាចរបស់រដ្ឋាភិបាលលើឧស្សាហកម្មទូរគមនាគមន៍ ដោយផ្តល់អំណាចដល់រដ្ឋក្នុងការ «ឈ្លបយកការណ៍ ឬឃ្លាំមើលសកម្មភាពនានា» ដែលការណ៍នេះបង្ក «ការគំរាមកំហែងដល់ឯកជនភាពរបស់អ្នកប្រើប្រាស់អ៊ីនធឺណិតម្នាក់ៗ»។ នេះបើយោងតាមអង្គការ Freedom House ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ ឧទាហរណ៍ ក្នុងករណីបង្ហោះខ្សែអាត់សំឡេងរបស់លោក កឹម សុខា ដោយគ្មានការអនុញ្ញាត។ ពាក់ព័ន្ធ

[65] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ កំណត់ត្រាសង្ខេបសេរីភាពបញ្ចេញមតិ និងការគាបសង្កត់លើបណ្តាញអ៊ីនធឺណេតនៅកម្ពុជា (ខែមេសា ឆ្នាំ២០១៣)។ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.htm .

[66] កំណត់ត្រាសង្ខេបទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (កុម្ភៈ ២០១៦)។

នឹងភាពប្រថុយប្រថានជុំវិញការលួចស្តាប់ ឬលួចថតសំឡេងតាមទូរស័ព្ទនេះ វាជាការរំលោភសិទ្ធិមនុស្សដែលផ្ទុយច្បាប់។ ក្រុមអង្គការសិទ្ធិមនុស្សក្នុងស្រុក គឺមានភាពព្រួយបារម្មណ៍លើច្បាប់ថ្មី ដែលមានលក្ខណៈស្រពិចស្រពិល និងផ្តល់លទ្ធភាពឲ្យមានការរំលោភបំពានផ្នែកនយោបាយ និងផ្នែកសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា ។

### ១.២.១.២. គេហទំព័រប្លុក (ប្លុក)

ប្លុក ប្រៀបដូចជាកំណត់ហេតុលើប្រព័ន្ធអ៊ីនធឺណេត ដែលបុគ្គលម្នាក់ៗអាចសរសេរពីអ្វីក៏ដោយដែលខ្លួនអាចសរសេរដូចជា បទពិសោធន៍ផ្ទាល់ខ្លួន នយោបាយ ឬមតិយោបល់បែបអ្នកប្រាជ្ញាលើប្រធានបទ និងបញ្ហាផ្សេងៗជាច្រើន។ ប្លុក អាចមានច្រើនរូបរាង និងទម្រង់ ប៉ុន្តែ ជាធម្មតា គឺគ្រាន់តែជាវែបសាយដែលអ្នកសរសេរប្លុកនីមួយៗធ្វើអោយទាន់សម័យកាលរបស់សង្គម។ ចំនួនគេហទំព័រ និងប្លុកជាច្រើនត្រូវបានបង្កើតឡើងចែករំលែកពត៌មាន និងដំណឹងនានាស្តីពីបញ្ហាសង្គមសំខាន់ៗ និងដោយសារអាចផ្តល់មតិយោបល់បាននោះ គឺជាមធ្យោបាយសម្រាប់ប្រជាជនសាមញ្ញ អាចចែករំលែកនូវគំនិតទស្សនៈនានាស្តីពីបញ្ហាទាំងនោះ។ ការកើនឡើងនៃចំនួនយុវជនក្នុងប្រទេសកម្ពុជាទាំងបុរស និងនារីដែលកំពុងតែប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត ក៏កំពុងតែរីកសុះសាយជាមួយនឹងការកើតឡើងនៃចំនួនអ្នកសរសេរប្លុក បានផ្សព្វផ្សាយនូវទស្សនៈនានាស្តីពីបញ្ហាសង្គម និងនយោបាយសំខាន់ៗ។ ឧទាហរណ៍ រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ដើម្បីគាបសង្កត់លើមាតិកានៅតាមប្រព័ន្ធអ៊ីនធឺណេតនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ គេហទំព័រប្លុកស្តតនៅក្នុងប្រទេសកម្ពុជា ត្រូវបានបិទតាមបញ្ជារបស់ក្រសួងមហាផ្ទៃទៅកាន់ក្រុមហ៊ុន ផ្គត់ផ្គង់សេវាអ៊ីនធឺណេតនៅកម្ពុជាទាំងអស់[67]។ អស់រយៈពេលជាច្រើនសប្តាហ៍ អចិជនរបស់ អ៊ីស៊ីខម ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេតដែលកំពុងកើនឡើង បានត្អូញត្អែរថា ពួកគេពុំអាចចូលទៅកាន់គេហទំព័រជាច្រើនរួមទាំងគេហទំព័រ ខេអាយមេឌៀផងដែរ។ នៅថ្ងៃដាច់សេវាអ៊ីនធឺណេតនោះ អ្នកតំណាងបម្រើសេវាអតិថិជននៅក្រុមហ៊ុន អ៊ីស៊ីខម បានប្រាប់អតិថិជនជាច្រើនថា គេហទំព័រត្រូវបានបិទតាមសំណើររបស់ក្រសួងមហាផ្ទៃ[68]។ គណៈគ្រប់គ្រងរបស់អ៊ីស៊ីខម បានបដិសេធនាពេលក្រោយជាលាយលក្ខអក្សរថា ខ្លួនមិនបានទទួលសេចក្តីបង្គាប់បញ្ជាពីសំណាក់រដ្ឋាភិបាលនោះទេ ។

### ១.២.១.៣. ហ្វេសប៊ុក

គិតត្រឹមខែមេសា ឆ្នាំ២០១៣ កម្ពុជាមានចំនួនអ្នកប្រើប្រាស់ហ្វេសប៊ុកចំនួន ៧៥២,៨២០នាក់ ដែលមានសកម្មប្រចាំខែ។ យោងតាមការប៉ាន់ស្មានរបស់ភ្នាក់ងារផ្សាយពាណិជ្ជកម្ម និងទីផ្សារផ្នែកបណ្តាញសង្គម

[67] ដូចលេខ ៥៩។

[68] ធីមីលើ 'ក្រសួងបដិសេធការបិទគេហទំព័រ' ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១)។

មីឌៀប្លាស់ កម្ពុជាមានចំនួនអ្នកប្រើប្រាស់ហ្វេសប៊ុកថ្មីចំនួនប្រហែលជា ១,១០០ ក្នុងមួយថ្ងៃ។ ប៉ុន្តែ តួលេខទាំងនេះរួមបញ្ចូលទាំងជនជាតិបរទេសរស់នៅកម្ពុជា ប្រជាពលរដ្ឋរស់នៅបរទេស ប្រជាពលរដ្ឋកម្ពុជាដែលមានគណនីហ្វេសប៊ុកច្រើន និងក្រុមអង្គការដែលបានបង្កើតគណនីហ្វេសប៊ុកផងដែរ។ ស្របពេលដែលហ្វេសប៊ុកត្រូវបានប្រើប្រាស់ដើម្បីធ្វើទំនាក់ទំនង ប៉ុន្តែហ្វេសប៊ុកក៏បានក្លាយជាមធ្យោបាយដ៏មានប្រជាប្រិយ ដើម្បីធ្វើការតស៊ូមតិក្នុងសង្គមផងដែរ។ អង្គការសិទ្ធិមនុស្សនិងភ្នាក់ព័ត៌មានប្រើប្រាស់ហ្វេសប៊ុកដើម្បីជាវិធីចែកចាយព័ត៌មានដោយសេរី ហើយមនុស្សជាច្រើនបានបង្កើតទំព័រហ្វេសប៊ុកសម្រាប់ខ្លួនគេផ្ទាល់[69]។

នៅឆ្នាំ២០១៦ តុលាការបានប្រើប្រាស់ច្បាប់ចំណាស់មួយ ដើម្បីដាក់ទោសអ្នកប្រឆាំងរដ្ឋាភិបាលតាមបណ្តាញអ៊ីនធឺណិត ដោយបានកាត់ទោសនិស្សិតម្នាក់ឲ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ ពីបទញុះញង់ ដោយសារតែគាត់បង្ហោះសារមួយនៅបណ្តាញសង្គម Facebook ដែលមានលក្ខណៈរិះគន់គណបក្សកាន់អំណាច។ ជាមួយគ្នានេះ គណបក្សសង្គ្រោះជាតិដែលជាបក្សប្រឆាំង បានក្លាយជាគោលដៅនៃការវាយប្រហារកាន់តែខ្លាំងឡើងប្រឆាំងនឹងសេចក្តីថ្លែងការណ៍តាមបណ្តាញអ៊ីនធឺណិតរបស់ខ្លួន។ ក្នុងនោះសមាជិកព្រឹទ្ធសភាគឺលោក ហុង សុខហួរ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ៧ឆ្នាំ ពីបទចោទដែលថា លោកបានបង្ហោះឯកសារផែនទីក្លែងក្លាយនៅលើបណ្តាញសង្គម Facebook ទាក់ទងនឹងព្រំដែនកម្ពុជា-វៀតណាម។ សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រឆាំងរូបនេះ ត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញក្រោយពីមានព្រះរាជក្រឹត្យបង្គាប់ឲ្យដោះលែងលោក តាមសំណើរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ កាលពីខែវិច្ឆិកាកន្លងទៅនេះ អ្នកលក់ផ្លែឈើម្នាក់ ត្រូវបានចាប់ខ្លួននៅប៉ែកខាងលិចប្រទេសកម្ពុជា ហើយស្ត្រីវ័យ២០ឆ្នាំរូបនេះ ក៏ត្រូវបានរាយការណ៍ថា ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងជេរប្រមាថលោក ហ៊ុន សែន និងមហាក្សត្រិយានី នរោត្តម មុនីនាថ សីហនុ នៅលើបណ្តាញសង្គម Facebook[70]។

### ១.២.១.៤. ធ្វីតធ័រ

នៅក្នុងសម័យនេះប្រព័ន្ធអ៊ីណធឺណេត បានធ្វើអោយមានការប្រែប្រួលយ៉ាងខ្លាំងទៅ លើស្ថាប័ននយោបាយ សកម្មភាព និងទំនាក់ទំនងទូទៅ។ នេះជាការផ្តល់ឱកាសអោយប្រជាជនធ្វើការប្រាស្រ័យទាក់ទងទទួលព័ត៌មានថ្មីៗ និងបញ្ចេញគំនិតរបស់ពួកគេតាមរយៈធ្វីតទ័រក៏ដូចជាហ្វេសប៊ុកដែរ ជាបណ្តាញសារព័ត៌មានសង្គមដែលប្រើប្រាស់ដោយបុគ្គលដើម្បីចែករំលែកព័ត៌មាន និងពិភាក្សាពីគំនិត។ ទំនាក់ទំនងកើតមានឡើងតាមរយៈការដោះដូរសារខ្លីៗ និងរហ័សត្រូវបានគេស្គាល់ថាជាធ្វីតទ័រមាន ១៤០ តួអក្សរ ឬតិចជាងនេះ។

[69] សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យ ឆឹង ស៊ីនាង ទំព័រ ៥៦។

[70] វីអូអេ, https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.html .

ក្នុងប្រទេសដែលសម្បូរទូរស័ព្ទដៃដូចជាកម្ពុជា ធ្វីតទ័រគឺជាវិធីសម្រាប់ធ្វើទំនាក់ទំនង ហើយការកើនឡើងនៃការប្រើប្រាស់របស់វា គឺអាចនឹងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត។ ធ្វីតទ័រ ក៏រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិពីច្បាប់ទូរគមនាគមន៍ដូចហ្វេសប៊ុក គេហទិនានុលេខន៍ (ប្លុក) ដែរ។

## ១.៣ បញ្ហាប្រឈមទាក់ទងនឹងច្បាប់

### ១.៣.១. ច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគិតច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី ៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៦/00៤/ ២០១៥ កបធ.ច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥[71]។ បញ្ហាប្រឈមចំពោះច្បាប់នេះ គឺមិនចែងពីអង្គការសមាគមន៍មូលដ្ឋាន (មាត្រា៤) ច្បាប់នេះមិនបានបញ្ចូល ឬលើកឡើងពីអង្គការសហគមន៍មូលដ្ឋាននោះទេ ដែលទុកចន្លោះអោយអាជ្ញាធរអាចធ្វើការបកស្រាយបានថា គួរបញ្ចូលអង្គការទាំងក្នុងប្រភេទសមាគម ឬក៏អត់។ បញ្ហានេះ អាចនឹងធ្វើទៅបាន ហើយអាចនឹងប្រឈមនឹងហានិភ័យ ប្រសិនបើអាជ្ញាធរបកស្រាយបទបញ្ញត្តិនេះថា ក្តោបទៅលើសមាគមទាំងមូលដ្ឋាន និងប្រើប្រាស់ដោយខុស ឬពន្លើស ដើម្បីកំហិតចលនាតាមមូលដ្ឋានហើយការសន្ទតអាជ្ញាធរនេះ នឹងមិនត្រឹមតែប៉ះពាល់ដល់សិទ្ធសេរីភាពខាងសមាគមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដលសិទ្ធខាងជួបប្រជុំ និងសិទ្ធផ្សេងៗទៀតដូចជា សិទ្ធិសេរីភាពខាងបញ្ចេញមតិ និងសិទ្ធចូលរួមក្នុងជីវភាពនយោបាយ សង្គម និងសេដ្ឋកិច្ចជាតិផងដែរ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកការចុះបញ្ជីជាចាំបាច់ និងតម្រូវការដ៏ច្រើនលើសលប់។ ការចុះបញ្ជី (មាត្រា៩ កថាខណ្ឌទី២) ជាលក្ខខណ្ឌចាំបាច់ខានមិនបានសម្រាប់សមាគម និងអង្គការក្នុងស្រុកដែលត្រូវបំពេញដើម្បីសកម្មភាពណាមួយ។ ការបដិសេធការចុះបញ្ជីការអង្គការសមគម និងការហាមឃាត់រាល់សកម្មភាពនានា គឺមិនអនុលោមទៅនឹងសិទ្ធសេរីភាពខាងសមាគមដូចដែលបានចែងក្នុងច្បាប់សិទ្ធមនុស្សអន្តរជាតិនោះទេ។ បន្ថែមពីលើមាត្រា៥ មាត្រា៦ និងមាត្រា១០ បានចែងពីលក្ខខណ្ឌតម្រូវជាច្រើនក្នុងការចុះឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដោយមិនគិតពីទំហំ និងវិសាលភាពនៃស្ថាប័ននោះទេ។ បញ្ញត្តិដែលចែងក្នុងមាត្រា៥ កថាខណ្ឌទី២ តម្រូវអោយមានសមាជិកស្ថាបនិកយ៉ាងតិច ៥រូប ដែលមិនធ្លាប់បំពេញតួនាទីជាថ្នាក់ដឹកនាំនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានលុបចេញពីបញ្ជី គឺជាការរឹងបន្តឹងហួសប្រមាណទៅលើការអនុវត្ត

[71] ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

សិទ្ធិសេរីភាពខាងសមាគម។ ការលុបឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មិនអាចជាអំណះអំណាងក្នុងការហាមប្រាមហួសហេតុ ដល់សមត្ថភាពថ្នាក់ដឹកនាំក្នុងការបង្កើតអង្គការថ្មីនោះទេ។ ការចុះបញ្ជីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស បានបង្ហាញពីបញ្ហាធ្ងន់ធ្ងរមួយចំនួន សម្រាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងធ្វើសកម្មភាពនៅកម្ពុជាផងដែរ។ មាត្រា ១២ បានដាក់កំហិតការចុះបញ្ជីជាចាំបាច់ ក្នុងទម្រង់ជាអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងករណីដែលជាគម្រោងមានរយៈពេលខ្លី តម្រូវអោយមានការសុំអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមរយៈដៃគូក្នុងស្រុក ហើយពុំមានការពន្យល់អត្ថន័យពាក្យថា "រយៈពេលខ្លី" នោះទេ។ មាត្រា ១៣ កំណត់តម្រូវការដ៏សាំញ៉ាំរួមមាន លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស អនុញ្ញាតអោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការ ដោយមិនគិតពីច្បាប់អនុវត្តនៅក្នុងប្រទេសប្រភពដើមនោះទេ និងរួមជាមួយនឹងលិខិតគាំទ្រគម្រោងនានារបស់សមាគមដែលចេញដោយក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល។ យោងតាមមាត្រា១៥ ចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវតែពិភាក្សាឯកភាពជាមួយក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលជាដៃគូដែលមិនបានបញ្ជាក់ច្បាស់ពីឈ្មោះរបស់ស្ថាប័នទាំងនេះលើគម្រោងនានាមុននឹងដាក់ពាក្យសុំចុះអនុស្សារណៈ ដែលនេះទុកចន្លោះអោយអាជ្ញាធរប្រើអំណាចជ្រៀតជ្រែកទៅលើសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ ការប្រឈមនឹងការបដិសេធការចុះឈ្មោះដោយអំពើចិត្ត។ ច្បាប់នេះ មិនបានកំណត់លក្ខខណ្ឌអោយច្បាស់លាស់ថា ឯកសារដាក់ពាក្យសុំចុះបញ្ជីបែបណាខ្លះនឹងត្រូវបដិសេធ។ មាត្រា ៨ ផ្តល់អំណាចអោយក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យរាល់ឯកសារស្នើសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងភាពស្របច្បាប់របស់លក្ខន្តិកៈ ហើយធ្វើការសម្រេចទៅលើពាក្យស្នើសុំទាំងនោះ។ ច្បាប់នេះ មិនបានស្នើអោយក្រសួងមហាផ្ទៃលើកទឹកចិត្ត ឬផ្តល់ដំណឹងពីសម្រេចចិត្តចុងក្រោយតាមរយៈលាយលក្ខណ៍អក្សរនោះទេ។ ដូច្នេះ ការស្នើសុំផ្សេងៗ បើកចំហអោយមានលទ្ធភាពក្នុងការបដិសេធ យោងលើហេតុផលដ៏ស្មុគស្មាញ។ មាត្រា៨ កថាខណ្ឌទី៣ បានចែងថា ក្នុងករណីដែលមានការសម្រេចចិត្តយឺតយ៉ាវ (លើសពី ៤៥ ថ្ងៃនៃថ្ងៃធ្វើការ) សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានចាត់ទុកថា បានចុះបញ្ជីស្របតាមច្បាប់នេះ ហើយក្រសួងមហាផ្ទៃ ត្រូវធ្វើនិយ័តកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ថ្វីបើនេះ ជាការវិវត្តវិជ្ជមានមួយក៏នៅមានការព្រួយបារម្ភពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងស្តីពីបទប្បញ្ញត្តិនេះផងដែរ។ ជាពិសេស ការបញ្ជាក់ថាបានទទួលឯកសារគួរតែត្រូវបានផ្តល់ជូនពេលដាក់ពាក្យស្នើសុំ និងក្លាយជាការបញ្ជាក់ស្របច្បាប់ក្នុងការធ្វើប្រតិបត្តិការ ក្នុងករណីបើមានការចុះបញ្ជីដោយស្វ័យប្រវត្តិបែបនេះ។ ច្បាប់នេះ គឺមានលក្ខខណ្ឌអាក្រក់ខ្លាំង

សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដូចក្នុងមាត្រា១៤ ដែលមិនបានកំណត់នូវមូលដ្ឋានក្នុងការបដិសេធសំណើក្នុងការចុះអនុស្សារណៈ ឬក៏តម្រូវអោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានកាតព្វកិច្ចពន្យល់បន្ថែមពីការសម្រេចចិត្តបដិសេធនោះទេ។ តម្រូវការហួសប្រមាណមិនច្បាស់លាស់ និងជ្រៀតជ្រែក។ មាត្រា២៤ តម្រូវអោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងក្នុងស្រុក និងបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត្យចំពោះគ្រប់គណបក្សនយោបាយទាំងអស់ បើមិនដូច្នោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជី។ បញ្ញតិស្រពេចស្រពិលបែបនេះ (តែមិនបានអនុវត្តចំពោះសមាគមក្នុងស្រុកនោះទេ) ដែលនេះទុកចន្លោះអោយមានការរំលោភបំពានលើសេរីភាពខាងបញ្ចេញមតិយ៉ាងធ្ងន់ធ្ងរ និងអាចមានការបំពានពីសំណាក់អាជ្ញាធរដើម្បីបំបិទសម្លេងប្រឆាំង និងរិះគន់ទៀតផង។ បន្ថែមពីលើនោះមាត្រា២៥ បានដាក់កំហិតអោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្តល់នូវច្បាប់ចម្លងរបាយការណ៍ដែលផ្ញើទៅម្ចាស់ជំនួយ ដែលនេះបង្កើតលក្ខខណ្ឌមិនចាំបាច់អោយរដ្ឋាភិបាលអាចទទួលបានពត៌មានរសើបមួយចំនួន។ បន្ថែមពីលើនោះ បញ្ញត្តិនេះក៏បញ្ជាក់ដែលថា សមាគមក្នុងស្រុកអាចស្នើសុំអោយមានការផ្តល់របាយការណ៍ប្រចាំឆ្នាំ " ក្នុងករណីចាំបាច់ " ជាបញ្ញត្តិមិនច្បាស់លាស់ ហើយអាចងាយស្រួលក្នុងការបំពានបាន។ ការលុបឈ្មោះចេញពីបញ្ជី និងទោសប្បញ្ញត្តិ ច្បាប់នេះ ផ្តល់អំណាចយ៉ាងទូលាយដល់ក្រសួងមហាផ្ទៃក្នុងការលុបឈ្មោះចេញពីបញ្ជី។ ចំណុចដែលគួរអោយព្រួយបារម្ភជាពិសេស គឺបញ្ញត្តិដែលកំណត់ក្នុងមាត្រា៣០។ ការផ្អាកសកម្មភាពបណ្តោះអាសន្ន និងការលុបឈ្មោះពីបញ្ជីដោយសារតែមិនបានគោរពតាមគោលការណ៍អព្យាក្រឹត្យ និងតម្រូវការផ្តល់របាយការណ៍ផ្សេងៗទៀតដូចមានចែងក្នុងមាត្រា១០ មាត្រា២៤ និងមាត្រា២៥ កថាខណ្ឌទី២ និងទី៣ បង្កហានិភ័យខ្ពស់ក្នុងការរំលោភបំពាន។ ការផ្អាកសកម្មភាព ឬក៏លុបឈ្មោះចេញពីបញ្ជី ចំពោះសកម្មភាពដែលផ្ទុយនឹងលក្ខន្តិកៈ គឺជាបញ្ញត្តិដែលជ្រៀតជ្រែកហើយគ្មានអ្វីខុសប្លែករវាងបញ្ញត្តិក្នុងលក្ខន្តិកៈ និងនាំអោយមានការជ្រៀតជ្រែកមិនចាំបាច់លើបញ្ហាផ្ទៃក្នុង។ ចុងក្រោយ បញ្ញត្តិដែលចែងយ៉ាងស្រពិចស្រពិលមានមាត្រា៣០ ចែងថា ក្រសួងមហាផ្ទៃត្រូវតែលុបឈ្មោះចេញពីបញ្ជីនូវសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា ដែលនេះទុកចន្លោះក្នុងការដាក់កំហិតដោយអំពើចិត្តទៅលើសិទ្ធិខាងសមាគម។ ការដាក់កំហិតនេះ ដូចគ្នានឹងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស យោងតាមបញ្ញត្តិដែលចែងក្នុងមាត្រា៣៤ និងមាត្រា៣៥។ ទោសទណ្ឌផ្នែករដ្ឋបាលដ៏ធ្ងន់ធ្ងរក៏ត្រូវបានដាក់ទៅលើសមាគម និងអង្គការដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬបន្តសកម្មភាពរបស់ពួកគេបន្ទាប់ពីត្រូវបានផ្អាកសកម្មភាព ឬលុបឈ្មោះចេញពីបញ្ជីហើយ។ សរុបមក ច្បាប់ស្តីពីអង្គការសមាគមលើកទី៥ មានចំណុចជាច្រើនដែលបង្កអោយមានការព្រួយបារម្ភយ៉ាងខ្លាំងដូចដែលបានរៀបរាប់ខាងលើ។ ច្បាប់នេះ

នៅតែទុកចន្លោះអោយមានការរំលោភបំពាន ជាពិសេស ពាក់ព័ន្ធនឹងអង្គការមូលដ្ឋាន ការបដិសេធយ៉ាងអត្តនោម័តទៅលើសំណើសុំចុះបញ្ជី និងអំណាចគ្រប់គ្រងយ៉ាងខ្លាំងក្លាទៅលើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ថ្វីបើគោលបំណងនៃច្បាប់នេះ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់នេះ គឺដើម្បីធានានូវសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាង អង្គការសង្គមស៊ីវិល និងអាជ្ញាធរ ក៏មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅតែព្រួយបារម្ភយ៉ាងខ្លាំងថាច្បាប់នេះ នឹងបន្តប្រើប្រាស់ដើម្បីបង្រួមលំហសង្គមស៊ីវិលក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជា និងដើម្បីបំបិទការរិះគន់នៅកម្ពុជា[72]។

### ១.៣.២. ច្បាប់ស្តីពីសហជីព

ច្បាប់ស្តីពីសហជីព ដែលត្រូវបានអនុម័តថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ក៏មានចែងអំពីលក្ខខណ្ឌចុះបញ្ជីដែលមានកាតព្វកិច្ចត្រូវតែធ្វើយ៉ាងស្មុគស្មាញផងដែរ ដែលរឹតត្បិតលទ្ធភាពរបស់សហជីពក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ។ មាត្រា ១៥ នៃច្បាប់ស្តីពីសហជីពចែងថា នីតិវិធីសម្រាប់ការដាក់ពាក្យសុំចុះបញ្ជីនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប្រកាសលេខ ២៤៩ ស្តីពីការចុះបញ្ជីអង្គការនិយោជិត សហជីព និងសាមាគមនិយោជក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ និងចែងពីរបៀបដែលសហជីពដាក់ចុះបញ្ជី។ ប្រកាសនេះកំណត់នូវហេតុហេតុផលចំនួន ៧ យ៉ាងក្នុងការបដិសេធការស្នើសុំចុះបញ្ជីរបស់សហជីព។ ហេតុផលជាច្រើនក្នុងចំណោហេតុផលទាំង ៧ នេះមានលក្ខណៈមិនច្បាស់លាស់ និងអាចត្រូវបានប្រើប្រាស់ដើម្បីបដិសេធការសុំចុះបញ្ជីរបស់សហជីពតាមអំពើចិត្ត ដូចជា ប្រសិនបើគោលដៅ ឬគោលបំណងរបស់សហជីព សមាគម " មិនការពារ ឬលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់បុគ្គលទេនោះ" ឬ "វិសាលភាព ឬកម្មវត្ថុរបស់សហជីព ឬសមាគមនិយោជកមានភាពមិនច្បាស់លាស់ដែលអាចធ្វើអោយសាធារណជនភ័ន្តច្រឡំ" ជាដើម។ ហេតុផលទាំងនេះមានលក្ខណៈទូលំទូលាយហួសហេតុពេក និងងាយបើកចំហដល់ការបកស្រាយជាអត្តនោម័តដោយមន្ត្រីដែលពាក់ពាន់ ដែលបង្កើតបានជាហានិភ័យដែលនីតិវិធីនេះអាចនឹងត្រូវបានអនុវត្តមិនស៊ីសង្វាក់គ្នា។ ប្រកាសលេខ ២៤៩ ក៏តម្រូវអោយថ្នាក់ដឹកនាំសហជីព ឬសមាគមនិយោជកផ្តល់នូវលិខិតប្រកាសដោយមានផ្តិតស្នាមមេដៃថាពួកគេអាចអាន និងសរសេរភាសាខ្មែរ ហើយពួកគេមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋនោះឡើយ ហេតុដូច្នេះ ករណីនេះផាត់ចេញនូវបុគ្គលដែលមិនចេះអក្សរ ឬអ្នកដែលធ្លាប់មានទោសពីបទល្មើសណាមួយពីមុនមក ឧទាហរណ៍ដូចជាការបិទផ្លូវសាធារណៈជាដើម។ ករណីបែបនេះ ជាការព្រួយបារម្ភជាពិសេសនៅក្នុងកម្ពុជា ដោយហេតុថាថ្នាក់ដឹកនាំសហជីព និងសមាជិកនៃសង្គមស៊ីវិល គឺតែងតែទទួលរងនូវការចោទប្រកាន់ពីបទចោទព្រហ្មទណ្ឌមិនត្រឹមត្រូវ ដោយសារតែ

[72] ការវិភាគរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (លើកទី៥ ខែមិថុនា ឆ្នាំ២០១៥)។

ភាពសកម្មរបស់ពួកគេ។ ក្នុងហេតុផលទាំងនេះ លក្ខខណ្ឌនៃការចុះបញ្ជីការនៅក្រោមច្បាប់ស្តីពីសហជីពមិនអាចនិយាយបានថា សមស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិបានទេ។ ពីព្រោះការត្រួតពិនិត្យទៅលើសកម្មភាពរបស់អង្គការសង្គមស៊ីវិល និងសហជីព នៅក្នុងច្បាប់ស្តីពីសហជីពមានលក្ខណៈច្រើនហួសហេតុ និងមិនស្របតាមបទដ្ឋានអន្តរជាតិ។ រឹតត្បិតសិទ្ធិរបស់កម្មករនិយោជិតមិនអោយធ្វើកូដកម្មដោយមិនមានហេតុផលសម្អាងច្បាស់លាស់[73]។ មាត្រា ៦៥ (ច) បានចែងថា ការធ្វើសកម្មភាពខុសច្បាប់សម្រាប់សហជីពក្នុងករណី "បង្ករឿងសម្រាប់តែគោលបំណងបម្រើអោយនិន្នាការនយោបាយ ឬមហិច្ឆតាផ្ទាល់ខ្លួន ឬប្រព្រឹត្តអំពើហិង្សានៅកន្លែងការងារ និងកន្លែងដទៃទៀត"។ ភាសាដ៏ទូលំទូលាយបែបនេះអាចនឹងត្រូវបានប្រើប្រាស់ ដើម្បីចាត់ទុកថាសកម្មភាពស្របច្បាប់របស់សហជីពជាសកម្មភាពមិនស្រប់ច្បាប់។[74]

### ១.៣.៣. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានអនុម័តនៅខែមីនា ឆ្នាំ២០១៥ មានភាពរឹតត្បិតយ៉ាងខ្លាំងលើសេរីភាពនៃការបញ្ចេញមតិ ជាពិសេសក្នុងអំឡុងពេលនៃការធ្វើយុទ្ធការផ្លូវការ។ មាត្រា៨៤ និងមាត្រា១៣៧ នៃច្បាប់ស្តីពីការឆ្នោតជ្រើសតាំងតំណាងរាស្ត្រតម្រូវអោយអង្គការ និងសមាគមក្នុងស្រុក និងអន្តរជាតិទាំងអស់ត្រូវប្រកាន់ជំហរ "អព្យាក្រឹតឥតលម្អៀង" ពាក់ពន្ធនឹងកិច្ចការបោះឆ្នោត។ បញ្ញត្តិដែលប្រើពាក្យពេជន៍មិនច្បាស់លាស់នេះអាចកាត់បន្ថយច្រើនដល់ការបំពេញតួនាទីរបស់សង្គមស៊ីវិលក្នុងនាមជាអ្នកឃ្លាំមើលសាធារណៈ។ មាត្រា ១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា "ជនណាដែលធ្វើការប្រមាថ តាមគ្រប់មធ្យោបាយ ជាសាធារណៈចំពោះគណបក្សនយោបាយណាំមួយ" នឹងត្រូវផាកពិន័យ។[75]

### ១.៣.៤. ច្បាប់ស្តីពីគណបក្សនយោបាយ

ច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវបានធ្វើវិសោធកម្មក្នុងខែមីនា ឆ្នាំ២០១៧ និងបានបញ្ចូលនូវបទប្បញ្ញត្តិថ្មីៗ មួយចំនួន ដែលមិនស្របគ្នានឹងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម។ មាត្រា ១៨ តម្រូវអោយថ្នាក់ដឹកនាំគណបក្សនយោបាយមិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីពទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ។ ការតម្រូវអោយថ្នាក់ដឹកនាំគណបក្សនយោបាយបំពេញតាមលក្ខខណ្ឌទាំងនេះបង្កើតបានជាការរឹតត្បឹតដ៏តឹងតែងទៅលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមពួគេ។ ប្រការនេះគួរអោយមានការព្រួយបារម្ភខ្លាំង ដោយសារមានមេដឹកនាំនយោនបាយជាច្រើននៅក្នុងប្រទេសកម្ពុជាទទួលរងនូវការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌនៅក្នុងសំណុំរឿង ដែលមានចរិកលក្ខណៈ

---

[73] ច្បាប់ស្តីពីសហជីព មាត្រា៩២។

[74] គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទំព័រ ៦, ៧ (ខែមេសា ឆ្នាំ២០១២-ខែមីនា ឆ្នាំ២០១៧) ។

[75] ដូចលេខ ៧៤ ទំព័រ ១៣។

នយោបាយ។ មាត្រា ៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយចែងអំពីសកម្មភាពដែលត្រូវហាមឃាត់ ដែលគណបក្សនយោបាយណាមួយអាចត្រូវផ្អាក ឬត្រូវរំលាយចោល រួមទាំងការ "ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" "ធ្វើអោយប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ" និង "ធ្វើការញុះញង់ដែលអាចនាំអោយមានការបែកបាក់ជាតិ"។ ការប្រើប្រាស់ភាសាទាំងនេះមានភាពមិនច្បាស់លាស់ និងមានលក្ខណៈអត្តនោម័ត្ត ដែលបង្កើនហានិភ័យដែលថា ច្បាប់នេះអាចយកទៅអនុវត្តតាមអំពើចិត្ត និងអាចគំរាមកំហែងដល់វត្តមានរបស់គណបក្សនយោបាយទៀតផង។ លើសពីនេះ ច្បាប់នេះមិនបានចែងអំពីរយៈពេលកម្រិតជាក់លាក់សម្រាប់ការផ្អាកសកម្មភាពគណបក្សនយោបាយណាមួយនោះទេដែលអាចទុកអោយក្រសួងមហាផ្ទៃធ្វើការផ្អាកគណបក្សនយោបាយនោះដោយមិនមានរយៈពេលកំណត់ ហើយដែលនេះ គឺជាការប្រគល់នូវសិទ្ធិអំណាចដល់រដ្ឋាភិបាលក្នុងការផ្អាកគណបក្សជាគូប្រគួតប្រជែងនយោបាយរបស់ខ្លួនជាអចិន្ត្រៃយ៍យ៉ាងមានប្រសិទ្ធភាព[76]។

### **១.៣.៥. ច្បាប់ស្តីពីការអប់រំ**

ច្បាប់ស្តីពីការអប់រំឆ្នាំ ២០០៧ ក៏មានចែងអំពីការដាក់ទណ្ឌកម្មធ្ងន់ធ្ងរមួយចំនួនចំពោះការរំលោភបំពានលើបទប្បញ្ញត្តិនៃច្បាប់នេះផងដែរ។ មាត្រា ៥២ ចែងថា ប្រសិនបើនីតិបុគ្គលណារំលោភបំពានលើមាត្រា ៣៤ នឹងត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០ ទៅ ២០ លានរៀល។ ចំនួនពិន័យនេះនឹងកើន ២ដងក្នុងករណីមិនរាងចាល។ ការពិន័យចុងក្រោយនេះនឹងត្រូវអនុវត្ត "ក្នុងករណីមិនរាងចាល" ដែលប្រព្រឹត្តដោយនីតិបុគ្គលដែលជាគ្រឹះស្ថានសិក្សា។ ក្នុងកាលៈទេសៈនេះ នឹងព្យួរជាបណ្តោះអសន្ន ឬដលហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់គ្រឹះស្ថានសិក្សានោះ ដែលករណីនេះមិនអាចនិយាយថាមានសមាមាត្រឡើយ។ បន្ថែមពីលើនេះ សេចក្តីណែនាំដល់ស្ថាប័នអប់រំ កំណត់ថា ទណ្ឌកម្មដែលមានចែងចំពោះការរំលោភបំពានលើមាត្រា ៣៤ នៃច្បាប់នេះក៏អនុវត្តផងដែរចំពោះបុគ្គលិកអប់រំ ដែលបន្ថែមការរឹតត្បិតថែមទៀតទៅលើសេរីភាពខាងការបញ្ចេញមតិរបស់បុគ្គល។ ពីព្រោះ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ មានសេចក្តីណែនាំដល់ស្ថាប័នអប់រំ ស្តីពីការទប់ស្កាត់ការធ្វើសកម្មភាព ឬឃោសនានយោបាយនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជន។ បានហាមឃាត់ច្រើនចំពោះសកម្មភាពនយោបាយនៅគ្រឹះស្ថាន និងស្ថាប័នសិក្សា។ មាត្រា ៣៤ នៃច្បាប់ស្តីពីការអប់រំចែងថា "ការធ្វើសកម្មភាពនយោបាយ និង/ឬការឃោសនានយោបាយអោយគណបក្សនយោបាយណាមួយក្នុងគ្រឹះស្ថាប័នអប់រំ គ្រឹះស្ថាប័នសិក្សាត្រូវហាមឃាត"។ មាត្រា ៣៤ នេះមិនមានភាពស៊ីសង្វាក់ជាមួយនឹងការធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការប្រើប្រាស់ខ្លឹមសារដ៏ទូលាយនៅក្នុងមាត្រានេះ

[76] ដូចលេខ ៧៤ ទំព័រ ១០។

បង្កជាហានិភ័យដែលថាការហាមប្រាមបែបនេះអាចត្រូវយកមកអនុវត្តតាមអំពើចិត្តនិងប្រើប្រាស់សម្រាប់រឹតត្បិតដល់ការពិភាក្សា ឬការបង្រៀនប្រធានបទដែលមានភាពចម្រូងចម្រាស។ នេះគឺជាឧទាហរណ៍ មួយនៃច្បាប់ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់សេរីភាពមូលដ្ឋានទោះបីជាច្បាប់នេះហាក់ដូចជាមិនពាក់ព័ន្ធទៅនឹងការអនុវត្តសេរីភាពមូលដ្ឋានក៏ដោយ។[77]

### ១.៣.៦. ច្បាប់ថ្មីស្តីពីទូរគមនាគមន៍

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋសភាបានអនុម័តជាផ្លូវការនូវសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ដែលក្រោយមកត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខានៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។ រដ្ឋាភិបាលបង្កើតច្បាប់នេះឡើងក្នុងគោលបំណង ការពារផលប្រយោជន៍ស្របច្បាប់ដល់ភាគីទាំងអស់ដែលពាក់ព័ន្ធរួមមាន ប្រតិបត្តិករទូរគមនាគមន៍អ្នកប្រើប្រាស់រួមមានរូបវន្តបុគ្គល ស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន និងរដ្ឋាភិបាល។[78] ច្បាប់ទូរគមនាគមន៍ បង្កើនការងគ្រប់គ្រងរបស់រដ្ឋាភិបាលលើវិស័យនេះ ហើយមានការគម្រាមកំហែងមួយដល់សេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា ដោយមិនត្រឹមតែផ្តោតទៅលើការបញ្ចេញមតិជាសាធារណៈលើប្រព័ន្ធអ៊ិនធើណេតប៉ុណ្ណោះទេ ហើយថែមទាំងទៅលើទំនាក់ទំនងឯកជន ដែលត្រូវបានធ្វើឡើងតាមរយៈការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍នានា។ នៅក្នុងរបាយការណ៍សង្ខេបមួយ ដែលត្រូវបានចេញផ្សាយដោយអង្គការ លីកាដូ បានវិភាគទៅលើមាត្រាជាច្រើននៃច្បាប់នេះថា មានការរិតត្បិតយ៉ាងខ្លាំងផ្តល់សិទ្ធិឲ្យអាជ្ញាធររដ្ឋជ្រៀតជ្រែកចូលទៅក្នុងជីវិតឯកជនរបស់បុគ្គលម្នាក់ៗ អាចបំផ្លាញភស្តុតាងនៅមុនពេលមានសវនាការលើរឿងក្តីព្រហ្មទណ្ឌ ឬគ្រប់គ្រងលើឧស្សាហកម្មទូរគមនាគមន៍ទាំងស្រុង ប្រសិនបើមានការសម្រេចចិត្តថាត្រូវតែធ្វើ។ វិធានការដ៏លើសលុបរបស់ច្បាប់នេះ ជាពិសេសមាត្រាដែលចែងពីបទល្មើសព្រហ្មទណ្ឌថ្មីៗ បង្ហាញនូវគោលបំណងពិតរបស់ច្បាប់នេះ គឺដើម្បីបំភិតបំភ័យបុគ្គលម្នាក់ៗ ដាក់ទណ្ឌកម្មដល់ការអនុវត្តសិទ្ធិ សេរីភាពជាមូលដ្ឋាន និងកាត់បន្ថយបុគ្គល ឬក្រុមជំទាស់។ ច្បាប់ស្តីពីទូរគមនាគមន៍ បានផ្តល់សិទ្ធិអំណាចដល់អាជ្ញាធររដ្ឋដោយសម្ងាត់ក្នុងការចូលស្តាប់គ្រប់ប្រព័ន្ធទូរគមនាគមន៍ និងដាក់ទណ្ឌកម្មចំពោះការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍អេឡិចត្រូនិចរវាងបុគ្គល និងបុគ្គល ដែលផ្តល់ផលអវិជ្ជមានយ៉ាងខ្លាំងដល់សេរីភាពនៃការបញ្ចេញមតិ។ រាល់ការសន្ទនាតាមរយៈទូរស័ព្ទ ការផ្ញើរសារជាអក្សរ អ៊ីមែល ឬសកម្មភាពរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម នឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មគ្រប់ពេលវេលា ហើយបុគ្គលដែលពាក់ព័ន្ធនិងរឿងនោះមិនបានដឹងខ្លួនទាល់តែសោះ។ បុគ្គលនានា អាចនឹងប្រឈមមុខនឹង

[77] ដូចលេខ ៧៤ ទំព័រ ៩។

[78] កំណត់ត្រាសង្ខេបទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (កុម្ភៈ ២០១៦)។

ទោសពន្ធនាគាររហូតដល់ ១៥ឆ្នាំ ដោយគ្រាន់តែបញ្ចេញមតិតាមប្រព័ន្ធហ្វេសប៊ុក ប្រសិនបើគេចាត់ទុកថាបុគ្គលនោះប៉ះពាល់ដល់ "សន្តិសុខជាតិ" ដែលត្រូវបានចែងមិនច្បាស់លាស់នៅក្នុងច្បាប់នេះ។ មិនត្រឹមតែឃ្លាដែលមិនច្បាស់លាស់ទាំងនេះតែប៉ុណ្ណោះទេ ដែលងាយស្រួលយ៉ាងខ្លាំងក្នុងការយកទៅប្រើប្រាស់ដើម្បីគោលបំណងនយោបាយសូម្បីតែការអនុវត្តអំណាចទាំងនេះ ក៏អាចជាការរំលោភលើសិទ្ធិ និងសេរីភាពរបស់បុគ្គលផងដែរ។ កង្វះខាតនៃភាពមិនច្បាស់លាស់នៅក្នុងច្បាប់នេះ ក៏ជាអាចមានន័យថាគ្រប់ការបញ្ចេញមតិ ក្រោយមកក៏នឹងអាចត្រូវបានអាជ្ញាធរបកប្រែថា ជាបទល្មើសព្រហ្មទណ្ឌផងដែរ។ ដោយផ្អែកលើគំនិតរបស់អាជ្ញាធរទាំងនោះចំពោះផលវិបាករបស់សកម្មភាពនោះ។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ ការរីកចម្រើននៃប្រព័ន្ធអ៊ិនធើណេតនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យមានការកើនឡើងយ៉ាងលឿននូវចំនួនមនុស្សដែលបានបញ្ចេញមតិយោបល់របស់អ្នកទាំងនោះនៅតាមប្រព័ន្ធអ៊ិនធើណេត ប៉ុន្តែដោយការខ្វះខាតភាពច្បាស់លាស់ និងភាពងាយនឹងត្រូវបានគេយកទៅប្រើប្រាស់មិនត្រឹមត្រូវនៃច្បាប់នេះ គឺហាក់ដូចជានឹងធ្វើឲ្យកើតមានការធ្លាក់ចុះនៃឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការទំនាក់ទំនង និងការបញ្ចេញមតិយោបល់របស់អ្នកទាំងនោះ។

លោក ណាលី ពីឡូក នាយិកាអង្គការលីកាដូ បានមានប្រសាសន៍ថា ៖ ការផ្តន្ទាទោស និងការដាក់ទោសពន្ធនាគារមិនត្រឹមត្រូវទៅលើនិស្សិតឈ្មោះ គង់ រ៉ៃយ៉ា ដោយសារការបង្ហោះសារនៅលើគេហទំព័រហ្វេសប៊ុកនោះ បានបង្ហាញថាអាជ្ញាធររដ្ឋមានឆន្ទៈរួចជាស្រេច និងមានលទ្ធភាពក្នុងការដាក់ទណ្ឌកម្មទៅលើការបញ្ចេញមតិលើប្រព័ន្ធអ៊ិនធើណេត និងការគាបសង្កត់ទៅលើអត្ថបទដែលរិះគន់ ដោយការប្រើប្រាស់មិនត្រឹមត្រូវលើច្បាប់ជាច្រើនដែលមានស្រាប់។ ដោយការផ្អែកលើច្បាប់ស្តីពីប្រព័ន្ធទូរគមនាគមន៍ ដែលអនុញ្ញាតឲ្យមានការស្តាប់ដោយសម្ងាត់ និងដាក់ទណ្ឌកម្មទៅលើការបញ្ចេញមតិនានានៅលើប្រព័ន្ធអ៊ិនធើណេត ទោះជាលក្ខណៈឯកជនក្តី ជាលក្ខណៈសាធារណៈក្តីរាជរដ្ឋាភិបាល បានបង្ហាញយ៉ាងរឹតតែច្បាស់នូវបំណងរបស់រាជរដ្ឋាភិបាលក្នុងការរំលោភបំពានលើសេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ិនធើណេត។ ជាមួយការបង្កើតនូវ "មន្ត្រីអធិការកិច្ចទូរគមនាគមន៍" ដែលមានអំណាចពេញលេញជាមន្ត្រីនគរបាលយុត្តិធម៌ និងមានសមត្ថភាពស្មើទៅកងយុទ្ធពលខេមរភូមិន្ទ ក្នុងការពង្រឹងការអនុវត្តមាត្រានានា។ ច្បាប់នេះក៏បានបង្កើតនូវអង្គភាពទីបី (អាចជាកងកម្លាំងប្រដាប់អាវុធ) បន្ថែមលើភ្នាក់ងារត្រួតពិនិត្យអត្ថបទនៅលើអ៊ិនធើណេតរបស់ក្រសួងមហាផ្ទៃ "អង្គភាពប្រឆាំងបទល្មើសព័ត៌មានវិទ្យា" និង "ក្រុមអ្នកជំនាញលើប្រព័ន្ធអ៊ិនធើណេត (Cyber War Team)" នៃទីស្តីការគណៈរដ្ឋមន្ត្រី។ ការប្រមូលផ្តុំកងកម្លាំងពិសេសដែលមានការគាំទ្រពីកងយោធាទប់ទល់នឹងអត្ថបទ និងទំនាក់ទំនងរវាងបុគ្គលលើប្រព័ន្ធអ៊ិនធើណេត គឺមិនសមហេតុផលមិនមានភាពសមាមាត្រ និងមិនចាំបាច់នោះទេ។ ច្បាប់នេះ អនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចបញ្ជាឲ្យបំផ្លាញភស្តុតាងដែល "ហាមឃាត់ ឬមានគ្រោះថ្នាក់" មុនពេល

មានការជំនុំជម្រះក្តី។ នេះអាចអនុញ្ញាតឲ្យមានការបំផ្លាញដោយមិនត្រឹមត្រូវនូវភស្តុតាង ដែលបង្ហាញពីភាពគ្មានកំហុសរបស់បុគ្គលដែលប្រឈមមុខនឹងការចោទប្រកាន់ (ជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា)។ មាត្រាទាំងនេះ អាចក្លាយជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានអនុញ្ញាតដោយអាជ្ញាធររដ្ឋ ដែលនឹងបង្កឲ្យមានការរំលោភបំពានកាន់តែខ្លាំងលើសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ គោលការណ៍សន្មតជាមុនថាគ្មានទោស និងគោលការណ៍នីតិរដ្ឋរបស់កម្ពុជាដែលកំពុងមានកំណត់ត្រាមិនល្អស្រាប់។ អាជ្ញាធររដ្ឋ នៅតែក្តោបក្តាប់យ៉ាងណែននូវប្រព័ន្ធផ្សព្វផ្សាយប្រពៃណីនៅកម្ពុជា ហើយបច្ចុប្បន្ន (ដូចដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍របស់អង្គការលីកាដូនៃដំណើរឃ្លាតចេញពីអ៊ីនធឺណិតលើការគម្រាមកំហែងចំពោះសេរីភាពលើប្រព័ន្ធអ៊ីនធឺណិតដែលទើបរកឃើញថ្មីនៅកម្ពុជាច្បាប់ស្តីពីទូរគមនាគមន៍ ក៏បានការពារអំណាចរបស់អាជ្ញាធររដ្ឋក្នុងការគ្រប់គ្រងស្ទើរតែទាំងស្រុងនូវប្រព័ន្ធអ៊ិនធើណេត ក៏ដូចជាប្រតិបត្តិករទូរគមនាគមន៍។ ឧទាហរណ៍ ច្បាប់នេះ អនុញ្ញាតឲ្យក្រសួងជាច្រើនរបស់រដ្ឋ ធ្វើជាតួបនីយកម្មលើក្រុមហ៊ុនទូរគមនាគមន៍នានា ប្រសិនបើស្ថិតនៅក្នុងករណី "ប្រធានសក្តិ" ដែលមិនត្រូវបានគេឲ្យនិយមន័យច្បាស់លាស់។ អាជ្ញាធររដ្ឋក៏អាចបញ្ឈប់ ឬជំនួសបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់ ប្រសិនបើក្រុមហ៊ុនណាមួយត្រូវបានរកឃើញថា បានរំលោភលើច្បាប់នេះ។ គ្រប់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ក៏នឹងតម្រូវឲ្យស្នើសុំអាជ្ញាប័ណ្ណថ្មីនៅក្នុងរយៈពេលមួយឆ្នាំ ដែលនេះមានន័យថាអាជ្ញាធររដ្ឋ នឹងសម្រេចថាតើគួរបន្តឲ្យស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងអ្នកផ្តល់សេវាអ៊ិនធើណេតប្រតិបត្តិការដែរឬទេនៅមុនពេលមានការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០១៧។

លោក ណាលី ពីឡុក នាយិកាអង្គការ លីកាដូ បានមានប្រសាសន៍ថា៖ ដោយសារការបោះឆ្នោតកាលពីឆ្នាំ ២០១៧ និង២០១៨ យើងអាចនិយាយថាឃ្លាទាំងនេះដែលនឹងអនុញ្ញាតឲ្យអាជ្ញាធររដ្ឋគ្រប់គ្រងលើប្រព័ន្ធអ៊ិនធើណេតនៅក្នុងស្ថានភាពមិនច្បាស់លាស់ នឹងអាចត្រូវបានគេប្រើប្រាស់មិនត្រឹមត្រូវដើម្បីបិទប្រព័ន្ធទំនាក់ទំនងសង្គមដើម្បីការពារបុគ្គលនានានិងគណបក្សជំទាស់ពីការប្រមូលផ្តុំគ្នា។ ការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ បានបង្ហាញពីអំណាចនៃប្រព័ន្ធទំនាក់ទំនងសង្គម គឺជាប្រព័ន្ធមួយយ៉ាងសំខាន់។ ដូចនេះ គឺមិនមានការភ្ញាក់ផ្អើលនោះទេ ដែលគណបក្សកាន់អំណាចអាចចង់បិទ និងគ្រប់គ្រងសេរីភាពលើប្រព័ន្ធអ៊ិនធើណេតនៅកម្ពុជា។ ច្បាប់ស្តីពីទូរគមនាគមន៍ គ្រប់តំណាក់កាលតាំងពីការធ្វើសេចក្តីព្រាងរហូតដល់ការអនុម័ត គឺពោរពេញដោយកង្វះខាតតម្លាភាព និងការពិភាក្សាដ៏មានអត្ថន័យ។ ច្បាប់នេះ គឺជាផ្នែកមួយដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពជាមូលដ្ឋាននានា។ ដោយការអនុម័តច្បាប់នេះនៅខែធ្នូ ច្បាប់នេះឥឡូវក្លាយជាឧបករណ៍ផ្នែកច្បាប់របស់អាជ្ញាធររដ្ឋជាមួយនឹងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)។ ហើយច្បាប់នេះ នឹងត្រូវបានចូលរួមជាមួយនឹងច្បាប់ដទៃទៀតនាពេលឆាប់ៗនេះ នៅពេលដែលអាជ្ញាធររដ្ឋព្យាយាមគ្រប់គ្រងយ៉ាង

តឹងរឹងនៅមុនពេលដែលមានការបោះឆ្នោតលើកក្រោយ។ អង្គការលីកាដូ មានការសោកស្តាយជាខ្លាំង នៅពេលដែលច្បាប់ស្តីពីទូរគមនាគមន៍បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិ និងឯកជនភាពរបស់បុគ្គលគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។ ការប៉ះពាល់របស់ច្បាប់ដែលមានលក្ខណៈធ្ងន់ធ្ងរ និងមិនសមាមាត្រនេះក៏ជាការរំលោភផងដែរលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ហើយច្បាប់នេះគួរតែមិនអាចអនុវត្តបាននោះទេ[79]។

## ១.៣.៧. សេចក្តីព្រាងច្បាប់អំពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត

ផែនការដើម្បីអនុវត្តច្បាប់នេះ ត្រូវបានប្រកាសក្នុងខែឧសភា ឆ្នាំ២០១២ ហើយច្បាប់នេះកំពុងស្ថិតក្នុងដំណាក់រៀបចំច្បាប់ប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងគមនាគមន៍។ ឯអង្គការមិនមែនរដ្ឋាភិបាល ភ័យនឹងសេចក្តីព្រាងច្បាប់ដែលអាចគាបសង្កត់សេរីភាពខាងការបញ្ចេញមតិកាន់តែខ្លាំងនោះ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលជាអ្នកតែងសេចក្តីព្រាងច្បាប់នោះខំលាក់ ឯសង្គមស៊ីវិលប្រឹងលាតត្រដាង។ នេះជាកង្វល់ថ្មី នៅសតវត្សទី២១ នៃសការាជព័ត៌មានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាព្រួយបារម្ភអំពីសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបឧក្រិដ្ឋកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ហើយជម្រុញឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផ្សាយសេចក្តីព្រាងនោះជាបន្ទាន់ ដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់ អាចផ្តល់យោបល់កែលម្អ។ មាត្រា៦, ២៨ និងមាត្រា ៣៥ នៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រពន្ធអ៊ីនធឺណេតតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងគមនាគមន៍ ជាប្រភពនៃក្តីព្រួយបារម្ភរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ ដោយបានទទួលសំណៅចម្លងក្រៅផ្លូវការ កាលពីដើមខែមេសា ឆ្នាំ២០១៤ អង្គការនេះ យល់ថាការចាត់តាំងសមាជិកជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល ឱ្យធ្វើជាសមាសភាពនៃគណៈកម្មាធិការជាតិប្រឆាំង នឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដូចមាន ចែងក្នុងមាត្រ៦ នៃសេចក្តីព្រាងនោះនឹងមិនអាចបង្កើតស្ថាប័នឯករាជ្យមួយសម្រាប់ត្រួតពិនិត្យការប្រើប្រាស់អ៊ិនធើណិតទេ។ ស្ថាប័នសិទ្ធិមនុស្សនេះ លើកឡើងទៀតថា ខ្លឹមសារមិនច្បាស់លាស់នៃមាត្រា២៨ នៃឯកសារនោះ ផ្តល់សេរីភាពហួសហេតុឱ្យរដ្ឋាភិបាលបកស្រាយអំពីពត៌មាន ដែលត្រូវចាត់ទុកថាបង្កអសន្តិសុខ អស្ថិរភាព និងធ្វើឱ្យខូចរបៀបរៀបរយខាងនយោបាយ ឬដែលត្រូវចាត់ទុកថាជាការមួលបង្កាច់ ការបោកបញ្ឆោត និងការបរិហាកេរ្តិ៍។ ជាងនេះទៅទៀត មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាភ័យខ្លាចថា រដ្ឋាភិបាលប្រើមាត្រា៣៥ នៃគម្រោងច្បាប់នោះ មករំលាយអង្គការសង្គមស៊ីវិលណា ដែលប្រព្រឹត្តិបទល្មើស ដែលមានចែងចាប់ពីមាត្រា២១ ដល់មាត្រា៣២ នៃសេចក្តីព្រាងច្បាប់នោះ។ សេចក្តីព្រាងច្បាប់ ដែលលេចធ្លាយមក

[79] ច្បាប់ថ្មីស្តីពីទូរគមនាគមន៍ប៉ះពាល់ដល់សិទ្ធិ និងសេរីភាពបុគ្គល (ចេញផ្សាយខែមិនា ឆ្នាំ២០១៦) ៖ https://www.licadho-cambodia.org/reports.php?perm=214&khmer.

នោះមានគោលបំណងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃបទល្មើសទាំងឡាយ ដែលប្រព្រឹត្តិឡើងតាមប្រព័ន្ធកុំព្យូទ័រ ព្រមទាំងធានាសុវត្ថិភាព និងការពារផលប្រយោជន៍ស្របច្បាប់នៃការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យា។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានផ្តួចផ្តើមឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីចំណាយពេលអស់យ៉ាងតិច២ឆ្នាំក្នុងការតាក់តែង។ ការអនុម័តវាឱ្យទៅជាច្បាប់ គឺជាអាទិភាពរបស់រដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥ នេះ[80]។ អង្គការសេរីភាពពត៌មានឈ្មោះ Article 19 ដែលមានមូលដ្ឋាននៅប្រទេសអង់គ្លេស បានចេញផ្សាយការវាយតម្លៃរិះគន់យ៉ាងខ្លាំងចំពោះសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតរបស់កម្ពុជា។ អង្គការនេះនិយាយថាវិធានការដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់នេះ មិនស្របនឹងបទដ្ឋានអន្តរជាតិទេ ដែលនឹងគំរាមកំហែងដល់សិទ្ធិបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងច្បាប់នេះ ដែលត្រូវបានគេចាប់ផ្តើមរៀបរៀងកាលមុនពេលបោះឆ្នោត កាន់តែមានសារៈសំខាន់ឡើងនៅក្រោយការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំមុន។ រដ្ឋាភិបាលកំពុងពិនិត្យលទ្ធភាពនៃការប្រើ ច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនេះជាឧបករណ៍ក្នុងរឿងនយោបាយ គឺដោយសារពួកគេមិនដឹងថាត្រូវធ្វើអ្វីទៀត។ សេចក្តីព្រាងច្បាប់ទី ២ នេះដែលជាសេចក្តីព្រាងច្បាប់ចុងក្រោយរបស់រដ្ឋាភិបាល ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យានេះត្រូវបានតាក់តែងឡើងកាលពីខែកក្កដា ឆ្នាំ២០១៥ នេះបើយោងតាមប្រភពស្និទរបស់ VOA នឹងរដ្ឋាភិបាល។ សេចក្តីព្រាងច្បាប់នេះមាន ៦ជំពូក និង៣៣មាត្រា។ សេចក្តីព្រាងច្បាប់នោះបានបញ្ជាក់ថា ច្បាប់នេះ នឹងផ្តល់សិទ្ធិដល់មន្ត្រីមានសមត្ថកិច្ចធ្វើការស៊ើបអង្កេតបទល្មើសខាងបច្ចេកវិទ្យារក្សាទុកទិន្នន័យ កុំព្យូទ័រ និងចរាចរណ៍ទិន្នន័យចាប់យកទិន្នន័យដោយស្របច្បាប់ ថតចម្លងទិន្នន័យ និងធ្វើការរឹបអូសទិន្នន័យកុំព្យូទ័រជាដើម។ ក្រុមអ្នកតស៊ូមតិបានគាំទ្រមាត្រាខ្លះ ដែលនិយាយអំពីការហាមប្រាមមិនឲ្យផ្សព្វផ្សាយរូបអាអាសអាភាស ទប់ស្កាត់ការលួចចូលកុងធនាគារ លួចព័ត៌មានក្រុមហ៊ុន បោកប្រាស់ និងបញ្ហាជាច្រើនទៀតផងដែរ។ គណៈរដ្ឋមន្ត្រីកម្ពុជា បានអនុម័តសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍កាលពីថ្ងៃសុក្រ ក្នុងកិច្ចប្រជុំពេញអង្គប្រចាំសប្តាហ៍របស់ខ្លួន ក្នុងគោលដៅកំណត់សមត្ថកិច្ចគ្រប់គ្រង ការចេញបទបញ្ញត្តិ និងការត្រួតពិនិត្យតាមដានប្រតិបត្តិការលើវិស័យទូរគមនាគមន៍ និងបែបបទនៃអភិបាលកិច្ចនៃវិស័យនេះ។ បន្ថែមពីលើនេះ ថ្មីៗ នេះរដ្ឋាភិបាលបានសម្រេចបង្កើតនាយកដ្ឋានមួយក្នុងក្រសួងមហាផ្ទៃទាក់ទងនឹងការប្រឆាំងនឹងបទឧក្រិដ្ឋកម្មតាមបច្ចេកវិទ្យា ឬឧក្រិដ្ឋកម្មលើប្រព័ន្ធអ៊ីនធើណិត[81]។ ច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនេះ ក៏អាចប៉ះពាល់ជនបរទេសដែលជាក្រុមហេគឃឺ (hackers) ឬអ្នកលួចចូលប្រព័ន្ធអ៊ីនធឺណិតហើយដែល

---

[80] ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជាកង្វល់ថ្មី៖ http://www.rfi.fr/km/cambodia-offense-crime-of-technology-is-new-matter-02-05-2014 .

[81] វីអូអេ (12 តុលា 2015)៖ https://khmer.voanews.com/a/media-experts-warn-against-a-cyber-crime-law-that-hurts-online-freedom/3002585.html .

ប្រើប្រទេសកម្ពុជា ជាមូលដ្ឋានដើម្បីធ្វើប្រតិបត្តិការវាយប្រហារតាមអ៊ីនធឺណិតនៅក្រៅប្រទេស។ បទបញ្ញត្តិជាច្រើននៅក្នុងសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនេះ មានចែងអំពីទណ្ឌកម្មធ្ងន់ធ្ងរ។ ជាឧទាហរណ៍ ការផ្សាយ ឬបង្ហោះព័ត៌មាននៅក្នុងបណ្តាញអ៊ីនធឺណេត ដែលគណៈកម្មាធិការមួយតែងតាំងដោយរដ្ឋាភិបាលកំណត់ថាប៉ះពាល់ដល់អធិបតេយ្យភាពនិងបូរណភាពរបស់ប្រទេស អាចត្រូវទទួលទោសជាប់ពន្ធនាគាររយៈពេល ៣ឆ្នាំ។ ច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណេតមិនច្បាស់លាស់មួយចំនួនទៀតរួមមាន សកម្មភាពដែលប៉ះពាល់សេចក្តីថ្លៃថ្នូររបស់ស្ថាប័នរដ្ឋាភិបាល ក្រសួង ឬមន្ត្រីណារដ្ឋាភិបាលណាមួយ ញុះញង់ឲ្យមានអនាធិបតេយ្យ ឬបង្កឲ្យមានអស្ថិរភាព។ ម៉្យាងទៀត បុគ្គលដែលត្រូវរកឃើញថាមានទោសក៏ត្រូវគេដកហូតសិទ្ធិពលរដ្ឋ ហើយត្រូវរារាំងពីវិជ្ជាជីវៈរបស់ពួកគេអស់មួយជីវិត។ នៅពេលត្រូវសុំអត្ថាធិប្បាយចំពោះសេចក្តីព្រាងច្បាប់នេះ ស្ថានទូតសហរដ្ឋអាមេរិកនិយាយថា ខ្លួនបានដឹងថាអ្នកវិភាគឯករាជ្យមួយចំនួនបានសម្តែងការបារម្ភអំពីសេចក្តីព្រាងច្បាប់នេះ ដោយហេតុថាច្បាប់នេះមានភាពទូលំទូលាយពេក ហើយអាចត្រូវគេប្រើដើម្បីរឹតត្បិតសេរីភាពនៃការបញ្ចេញមតិលើអ៊ីនធឺណេត។

### ១.៣.៨. ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលរដ្ឋសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់នឹងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។ នាសម័យ៧ ប្រជុំជាវិសាមញ្ញនីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២០២/០០២/២០២០ កបធ.ច ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នមាន ៥ជំពូក និង១២ មាត្រា ច្បាប់នេះនឹងផ្តល់អំណាចយ៉ាងទូលាយ និងគ្មានដែនកំណត់ដល់រាជរដ្ឋាភិបាលកម្ពុជា ដោយមិនមានយន្តការត្រួតពិនិត្យណាមួយនោះទេ។ សិទ្ធិអំណាចទាំង ១២យ៉ាង របស់រាជរដ្ឋាភិបាល ដែលគេឃើញនៅក្នុងមាត្រា៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រួមមាន៖

- ហាមឃាត់ ឬកម្រិតសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ។
- ហាមឃាត់ ឬកម្រិតសិទ្ធិសេរីភាពក្នុងការជួបជុំ ឬការប្រមូលផ្តុំមនុស្ស។
- ហាមឃាត់ ឬកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរ។
- ហាមឃាត់ ឬកម្រិតមិនឲ្យបុគ្គលចេញពីលំនៅឋាន ឬទីសំណាក់ណាមួយ។

➢ ដាក់ចេញវិធានការចត្តាឡីស័ក ឬដាក់ឲ្យនៅដាច់ដោយឡែក ក្នុងករណីគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈ បណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ។

➢ ដាក់ចេញវិធានការទាក់ទងនឹងកំណែននិងជម្លៀសពលរដ្ឋដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

➢ ដាក់ចេញវិធានការទាក់ទងនឹងកំណែន ដកហូត គ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិ និងសេវា ដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។ នីតិវិធីនៃការធ្វើកំណែន និងសំណងត្រូវកំណត់ដោយរាជរដ្ឋាភិបាល។ ( ចំណុចនេះ មិនបានបញ្ជាក់ឲ្យច្បាស់ឡើយថា ជាទ្រព្យសម្បត្តិរដ្ឋ ឬឯកជន តែទំនងជាចង់សំដៅលើឯកជនច្រើនជាង)។

➢ ដាក់ចេញវិធានការទាក់ទងនឹងការកំណត់ថ្លៃទំនិញ និងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

➢ ដាក់ចេញវិធានការទាក់ទងនឹងការបិទទីតាំងសាធារណៈ ឬ ឯកជនណាមួយ ដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

➢ ដាក់ចេញវិធានការឃ្លាំមើល និង តាមដានតាមគ្រប់មធ្យោបាយ ដើម្បីទទួលបានពត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍គ្រប់រូបភាព ក្នុងគោលបំណងឆ្លើយតបចំពោះភាពអាសន្ន។

➢ ហាមឃាត់ ឬ កម្រិតការចែកចាយ ឬ ការផ្សព្វផ្សាយពត៌មាន ដែលអាចបង្កឲ្យមានការភ័យខ្លាចដល់សាធារណជន ឬចលាចល ដែលនាំឲ្យខូចខាតដល់សន្តិសុខជាតិ ឬធ្វើឲ្យមានការភាន់ច្រឡំអំពីស្ថានភាពនៃភាពអាសន្ន។

➢ ដាក់ចេញវិធានការដទៃទៀត ដែលសមស្រប និង ចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

ក្រៅពីប្រគល់សិទ្ធិអំណាចទាំង១២យ៉ាងនេះ ទៅឲ្យរាជរដ្ឋាភិបាល មាត្រា៥ ក៏បានចែងដែរថា វិធានការអនុវត្តពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចត្រូវបានដាក់ចេញសម្រាប់ទូទាំងប្រទេស ឬដែនដីកំណត់ជាក់លាក់ណាមួយ។ កថាខណ្ឌចុងក្រោយនៃមាត្រា៥ សង្កត់ធ្ងន់ថាក្នុងពេលសង្គ្រាម ឬក្នុងកាលៈទេសៈដទៃទៀតដែល សន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយរាជរដ្ឋាភិបាលអាចធ្វើឡើងតាមរបបអាជ្ញាសឹក។ ច្បាប់នេះ មានលក្ខណៈអំណោយផលដល់គណបក្សនយោបាយដែលដឹកនាំប្រទេសជាជាងគណបក្សផ្សេងៗ នៅក្រៅរដ្ឋាភិបា[82] ។ ចំណែក ទោសទណ្ឌដែលចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្នមាន ៤មាត្រា។ មាត្រា៧ កំណត់ថា ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនារារាំង ឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតប

[82] https://vodkhmer.news/2020/05/04/how-govt-use-state-emergency-law/. (០៤ ឧសភា ២០២០)

ចំពោះភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាទឹកប្រាក់ពី ១លានរៀល ទៅ ៥លានរៀល។ អំពើរារាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ កាលបើអំពើនោះ នាំឲ្យមានចលាចលជាសាធារណៈ ឬប៉ះពាល់ដល់សន្តិសុខជាតិ។ មាត្រា៨ ចែងថា ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការដាក់ចេញដោយរាជរដ្ឋាភិបាលក្រោមបញ្ញត្តិនៃមាត្រា៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាទឹកប្រាក់ពី ១សែនរៀល ទៅ ១លានរៀល ។ អំពើមិនគោរពតាមវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាទឹកប្រាក់ពី ១លានរៀល ទៅ ៥លានរៀល កាលបើអំពើនេះនាំឲ្យមានចលាចលជាសាធារណៈ។ មាត្រា៩ សរសេរថា នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចចែងក្នុងនៅមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតីបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៧នៃច្បាប់នេះ។ នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យប្រាក់ពី ១រយលានរៀល ទៅ ១ពាន់លានរៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតីបុគ្គល) នៃក្រមព្រហ្មទណ្ឌ។ មាត្រា៩ បន្តថានីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុង មាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ។ នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យប្រាក់ពី ៥០លានរៀល ទៅ ៥រយលានរៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។ សម្រាប់មាត្រា១០ គឺទាក់ទងនឹងអាជ្ញាធរមានសមត្ថកិច្ច ដោយសរសេរថា អាជ្ញាធរមានសមត្ថកិច្ច ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភ ដើម្បីធ្វើតាមទំនើងចិត្ត ហើយបង្កការខូចខាតរូបរាងកាយ ឬទ្រព្យសម្បត្តិអ្នកដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ យោងតាមមាត្រា៤ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចធ្វើឡើងនៅពេលដែលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈ បណ្តាលមកពីការឆ្លងរាលដាលជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះថ្នាក់មហន្តរាយធ្ងន់ធ្ងរ ដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់ពីការរីករាលដាលដល់ កម្រិតទូទាំងប្រទេស។ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ន បានឆ្លងកាត់កិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។ រាជរដ្ឋា

ភិបាលសម្រេចថា សេចក្តីព្រាងច្បាប់នេះ នឹងមិនឆ្លងកាត់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនោះទេ ដោយនឹងត្រូវបញ្ជូនទៅអង្គការនីតិបញ្ញត្តិតែម្តង[83]។

សរុបមក ពាក្យពេចន៍ដែលមានន័យទូលាយ និងមិនសូវច្បាស់លាស់ នៅក្នុងច្បាប់នេះអាចបកស្រាយបានយ៉ាងទូលាយដើម្បីធ្វើអោយការដាក់ប្រទេសក្នុងភាពអាសន្ន ស្របច្បាប់ស្ទើរគ្រប់ស្ថានភាពទាំងអស់។ ដោយមិនមានការកំណត់អំពីពេលវេលាបញ្ចប់ច្បាស់លាស់ ការប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន អាចនឹងត្រូវបានធ្វើឡើងក្នុងរយៈពេលវែង។ សិទ្ធិសេរីភាពជាច្រើន អាចនឹងត្រូវបានហាមឃាត់ ឬរឹតត្បិត ដោយមិនកំណត់ថេរវេលា។ សិទ្ធិសេរីភាពដែលប៉ះពាល់រួមមាន សិទ្ធិក្នុងការធ្វើដំណើរ សិទ្ធិជួបជុំ ឬ ប្រមូលផ្តុំ ការធ្វើសកម្មភាពការងារ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបញ្ចេញមតិ។ រាជរដ្ឋាភិបាល នឹងទទួលបានអំណាចក្នុងការតាមដានត្រួតពិនិត្យគ្មានព្រំដែន ទៅលើទំនាក់ទំនងរបស់ពលរដ្ឋទាំងអស់ និងការហាមឃាត់ការចែកចាយព័ត៌មានមួយឬច្រើន ដែលអាជ្ញាធរសម្រេចមិនអោយផ្សាយ។ អាជ្ញាធរអាចប្រើប្រាស់ច្បាប់នេះដើម្បីប្រើប្រាស់កងទ័ពគ្រប់គ្រងលើស្ថាប័នស៊ីវិលមួយ ឬច្រើន ក្នុងគោលបំណងរៀបចំ និងគ្រប់គ្រងប្រទេស។ ចុងក្រោយទណ្ឌកម្មព្រហ្មទណ្ឌដែលមិនអាចកំណត់ទុកជាមុន និងមានលក្ខណៈមិនសមាមាត្រនឹងអំពើល្មើស អាចត្រូវបានប្រើប្រាស់ទៅលើប្រជាពលរដ្ឋ តាមរយៈការចោទពីបទល្មើសជាច្រើន ដែលមាននិយមន័យមិនច្បាស់លាស់។ នីតិបុគ្គល ដូចជាអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬសហជីពអាចប្រឈមមុខនឹងទោសធ្ងន់ធ្ងរ ដូចជាការរំលាយចោលប្រសិនបើស្ថាប័ននោះរំលោភនឹងច្បាប់នេះ។ ដូចនេះ ការព្រួយបារម្ភថាច្បាប់នេះនឹងត្រូវបានប្រើប្រាស់ដើម្បីបំបិទសិទ្ធិសេរីភាពរបស់ពលរដ្ឋ[84]។

[83] អំណាចរដ្ឋ១២ចំណុច លើការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (ថ្ងៃទី១ មេសា ២០២០)៖ https://thmeythmey.com/?page=detail&id=90211 .

[84] បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (នៅថ្ងៃទៅ៣១ មីនា ឆ្នាំ២០២០)។

# ជំពូកទី៣
# ដំណោះស្រាយបលើបញ្ហាប្រឈម
# ចំពោះសិទ្ធិបញ្ចេញមតិ

# ជំពូកទី ៣

# ដំណោះស្រាយបលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ

ប្រទេសកម្ពុជា ជាប្រទេសលិទ្ធិប្រជាធិបតេយ្យការគោរពសិទ្ធិមនុស្សស្របតាមបទបញ្ញត្តិអន្តរជាតិ និងជាតិដែលបានការពារសិទ្ធិមនុស្សពេញលេញ។ ប៉ន្តែ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះកម្ពុជាកំពុងមានបញ្ហាជាច្រើនដូនដែលបង្ហាញនៅក្នុងជំពូកទី២ និយាយពីបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ។ រាល់បញ្ហាដែលបានលើកឡើងខាងលើ គឺសុទ្ធតែជាបញ្ហាដែលកើតមាននៅកម្ពុជា វាជាការព្រួយបារម្ភមួយសម្រាប់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលលើបញ្ហាសិទ្ធិមនុស្ស។ ដើម្បីជួយលើកកម្ពស់ និងស្តារសិទ្ធិមនុស្សនៅកម្ពុជាអោយមានភាពល្អវា យើងត្រូវមានដំណោះស្រាយលើបញ្ហា ដែលជាមូលហេតុបង្កអោយមានបញ្ហារំលោភសិទ្ធិមនុស្សកាន់តែមានភាពធ្ងន់ធ្ងរទៅៗ។ ប្រជាពលរដ្ឋ ក៏ដូចជាអង្គការសង្គមស៊ីវីលជាច្រើនដែលមានលើកឡើងពីដំណោះស្រាយ និងផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាលចំពោះដំណោះស្រាយលើបញ្ហាប្រឈមដូចខាងក្រោម។

## ១.១. ដំណោះស្រាយលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី

### ១.១.១. ដំណោះស្រាយលើការរឹតបន្តឹងចំពោះសិទ្ធិបញ្ចេញមតិតាមបែបប្រពៃណី

#### ១.១.១.១. សិទ្ធិទទួលបានពត៌មាន

សិទ្ធិទទួលបានពត៌មាន គឺផ្នែកមួយយ៉ាងសំខាន់នៃលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជាដោយពួកគេអាចយល់ដឹងពីសារៈសំខាននៃសិទ្ធិសេរីភាព និងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី និងសិក្ខាសាលា។ បុគ្គលទាំងអស់មានសិទ្ធិសេរីភាពក្នុងការទទួលបានពត៌មាន ដោយរាប់បញ្ចូលទាំងសិទ្ធិក្នុងការទទួលបានពត៌មាន ដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ និងឯកជន [85] ។ គ្រប់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជារដ្ឋាភិបាលត្រូវតែធ្វើអោយមានតម្លាភាពក្នុងការ ផ្សព្វផ្សាយជូនប្រជាពលរដ្ឋដោយគ្មានការបង្ខិតបង្ខំ គំរាមកំហែង ឬរឹតត្បិតសិទ្ធិសេរីភាពរបស់អ្នកគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយ។ ដូច្នេះ ពេលដែលប្រជាពលរដ្ឋអាចទទួលបានពត៌មានដែលរួមទាំងមតិរបស់អ្នកដទៃអំពីបញ្ហាសាធារណៈ និងបញ្ហានយោបាយផងនោះ ប្រជាពលរដ្ឋអាចប្រើប្រាស់ពត៌មានទាំងនោះដើម្បីបង្កើតបានជាគំនិតរបស់គាត់ផ្ទាល់។ ពេលនោះប្រជាពលរដ្ឋបានទទួលពត៌មានគ្រប់គ្រាន់ ប្រជាពលរដ្ឋអាចយល់ដឹងកាន់តែច្បាស់អំពីទិដ្ឋភាពនៅក្នុងប្រទេសកម្ពុជា ហើយអាចធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតអោយគណបក្សនយោបាយណាមួយ ព្រមទាំង

[85] ច្បាប់ស្តីពីសេរីភាពក្នុងារទទួលបានព័ត៌មាន (២០១២)។

ត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងការពិភាក្សាជាសាធារណៈ និងក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងចន្លោះពេលការបោះឆ្នោតពីអាណត្តិមួយទៅអាណត្តិមួយ។[86]

**ក. ទូរទស្សន៍ និង វិទ្យុ**

មានមុខងារ ជាអ្នកផ្សព្វផ្សាយនូវព័ត៌មានជាតិ និងអន្តរជាតិ ដែលទទួលបានទាក់ទងនឹងដំណើរការនៃការអភិវឌ្ឍរបស់ប្រទេស និងសិទ្ធបញ្ចេញមតិរបស់ប្រជាពលរដ្ឋចំពោះការអភិវឌ្ឍន៍ និងការជិះជាន់គាបសង្កត់ពីក្រុមហ៊ុនឯកជន ដែលមានអ្នកមានអំណាចនៅពីក្រោយមកលើប្រជាពលរដ្ឋ។ បើចំហនូវការផ្សព្វផ្សាយគ្រប់ទូរទស្សន៍ និងវិទ្យុទាំងអស់នៅក្នុងកម្ពុជាអោយមានភាពស្មើគ្នាចំពោះព័ត៌មានដែលទទួលបានទាំងព័ត៌មានជាតិ និងព័ត៌មានអន្តរជាតិ។

**ខ. កាសែត និងទស្សនាវដ្តី**

ដូចដែល បានលើកឡើងខាងលើនៅចំណុចបញ្ហាប្រឈមគ្រប់ កាសែត និងទស្សនាវដ្តីជាច្រើនត្រូវបានការរឹតត្បិតសិទ្ធិក្នុងការបំពេញតួនាទីរបស់ខ្លួនអោយបានពេញលេញណាស់។ ក្នុងនាមជាស្ថាប័នកាសែត និងទស្សនាវដ្តី ចង់ទទួលបានព័ត៌មានពីសំណាក់រាជរដ្ឋាភិបាល និងប្រជាជនអំពីការវិវឌ្ឍទៅរបស់ប្រទេសរាល់ពេលការជូនដំណឹង ឬមានបញ្ហាអ្វីមួយកើតឡើង។ ដូច្នេះ ត្រូវបើអោយទូលាយនូវការចុះទទួលព័ត៌មានអំពីបញ្ហាសង្គម នយោបាយ និងការអភិវឌ្ឍប្រទេសជាតិ។

**គ. សិក្ខាសាលា**

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ផ្នែកសិក្ខាសាលាអំពីសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋពុំបានបើអោយទូលាយនោះទេ។ សិក្ខា ជាផ្នែកមួយនៃការទទួលបានព័ត៌មាននៅតាមទីសាធារណៈឬនៅស្ថាប័នណាមួយអំពីប្រធានបទដែលគេបានរៀបចំនៅក្នុងពេលសិក្ខាសាលា។ ជាវិធីមួយយ៉ាងងាយស្រួលមួយក្នុងការទទួលបានព័ត៌ពិត និងមានប្រភពច្បាស់លាស់ដល់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងស្ថាប័នផ្សេងៗ។ ដូច្នេះ រដ្ឋាភិបាលគួលតែកែប្រែ ឬមានការផ្លាសប្តូរនៅការរិតត្បិត ឬការហាមឃាតមិនអោយធ្វើសិក្ខាសាលានៅតាមទីសាធារណៈ។

**១.១.១.២. សិទ្ធិស្វែងរកពត៌មាន**

សិទ្ធិស្វែងរកពត៌មាន គឺជាសិទ្ធិរបស់មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយពត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែង

[86] សេចក្តីនៃច្បាប់ សិទ្ធិមនុស្ស និងសិទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា ៖ (ឧសភា ២០១១) ទំព័រ ៨៤។

មតិណាមួយក៏ដោយ[87]។ បានន័យថា គ្រប់ប្រជាពលរដ្ឋអាចមាន សិទ្ធិស្វែងរកពត៌មានតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី និងសិក្ខាសាលា។ អោយតែប្រជាពលរដ្ឋចង់ដឹងអំពីពត៌មានសាធារណៈ ឬនយោបាយដែលមិនមែនជាព័តមានផ្ទៃក្នុងរបស់ស្ថាប័នណាមួយ ឬពត៌មានដែលធ្វើអោយមានផលប៉ះពាល់។ ដូច្នេះ រដ្ឋាភិបាលត្រូវតែបើកចំហអោយស្មើភាព និងពត៌មានពិតចំពោះពត៌មានដែលប្រជាពលរដ្ឋចង់ដឹងដោយគ្មានការលាក់បាំង គំរាមកំហែង ឬធ្វើការហាមឃាត់ប្រជាពលរដ្ឋគ្រប់រូបតាមមធ្យោបាយគ្រប់រូបភាពដែលធ្វើអោយមានការបំបិទសិទ្ធិសេរីភាពក្នុងការស្វែងរកពត៌មាន។

**ក. ទូរទស្សន៍ និង វិទ្យុ**

គ្រប់ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុនៅពេលដែលទទួលបានព័ត៌មានហើយដែលទាក់ទងនឹងបញ្ហាសង្គម ការអភិវឌ្ឍប្រទេស បញ្ហាព្រំដែន និងនយោបាយ។ ប៉ុន្តែ ពេលទទួលបានហើយពួកគេមានភាពច្បាប់សាល់ចំពោះព័ត៌មានដែលទទួលបាន ពួកគេអាចធ្វើការស្វែងរកមន្ថែមទៀតអំពីប្រភព ទីតាំង និងពេលវេលាអោយបានកាន់តែច្បាស់លាស់ឡើង។ ទាំងនេះសុទ្ធតែជាសិទ្ធិដែលពួកគេមានសម្រាប់បំពេញតួនាទី ដូច្នេះ គួតែមានវិធានការដោះស្រាយចំពោះបញ្ហាប្រឈមដែលកើតឡើងចំពោះការស្វែងរកព័ត៌មាននេះ។

**ខ. កាសែត និង ទស្សវដ្តី**

ពេលទទួលបានព័ត៌មាននឹងមុនធ្វើការបោះពុម្ពផ្សាយ ការសែត និងទស្សវដ្តីអាចធ្វើការស្វែងរកនូវព័ត៌មានបន្ថែម។ ដើម្បីអោយបានដឹងពីប្រភពព័ត៌មាននេះអោយបានកាន់តែច្បាស់សម្រាប់ស្ថាប័នរបស់ពួក ក្នុងការជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ដូច្នេះរាល់ការបំលោភបំពាន់ទៅអ្នកកាសែត និងទស្សវដ្តី គួរមានការយកចិត្តទុកដាក់ក្នុងការដោះស្រាយពីរាជរដ្ឋាភិបាលដែលកំពុងមានការរិតត្បិតយ៉ាងធ្ងន់ធ្ងរ។

**គ. សិក្ខាសាលា**

ការស្វែងរកព័ត៌មាន វាមានសារៈសំខាន់ណាសម្រាប់ការមុនពេលធ្វើសិក្ខាសាលានៅតាមទីសាធារណៈ និងនៅស្ថាប័នណាមួយ។ ព្រោះថាប្រភព ពេលវេលា ទីកន្លែងសម្រាប់ធ្វើសិក្ខាមានការយកចិត្តទុកពីសំណាក់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល។ ប្រជាពលរដ្ឋ និងសង្គមស៊ីវិលអាចស្វែងរកព័ត៌មាននៅក្នុងសិក្ខាសាលាបាន និងមានទុកចិត្ត។ ដូច្នេះ រាជរដ្ឋាភិបាលគួរបើកចំហឡើងវិញនៅត្រង់ចំណុចការហាមឃាតធ្វើសិក្ខាសាលានានា។

[87] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សៈ មាត្រា១៩ (១០ ១២ ១៩៤៨)។

**១.១.១.៣. សិទ្ធិផ្សព្វផ្សាយពត៌មាន**

សិទ្ធិផ្សព្វផ្សាយពត៌មាន បើយោងតាមមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការផ្សព្វផ្សាយនូវពត៌មានដែលខ្លួនបានស្វែងរកដឹងពីប្រភព និងជាពត៌មានពិតប្រាកដគ្មានការរំលោភ ឬមានផលប៉ះពាល់លើសិទ្ធិបុគ្គល និងស្ថាប័នណាមួយឡើយ។ ប្រជាពលរដ្ឋអាចធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី និងសិក្ខាសាលា។ រដ្ឋាភិបាល មិនគួរធ្វើការរាំងស្ទះប្រជាពលរដ្ឋលើសិទ្ធិផ្សព្វផ្សាយពត៌មាននោះទេ។ យើងចង់ឃើញថា រដ្ឋាភិបាលគាត់បើកចំហនៅក្នុងការផ្តល់សេរីភាពពេញលេញ សម្រាប់ការសម្រេចចិត្តរបស់ម្ចាស់ស្ថានីយ៍វិទ្យុទាំងអស់ ដើម្បីធានាថា ពួកគាត់មានការសម្រេចចិត្តដោយមិនមានការភ័យខ្លាចក្នុងការផ្សព្វផ្សាយកម្មវិធីដែលអាចឱ្យប្រជាពលរដ្ឋទទួលបានពត៌មាន ទទួលបានដំណឹងផ្សេងៗគ្រប់និន្នាការ ឬក៏ពត៌មានដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ពួកគាត់ជាជាងអ្វីដែលពួកគេទទួលបានពត៌មានតែពីម្ខាងៗ។

**ក. ទូរទស្សន៍ និង វិទ្យុ**

ពេលទទួលបាន និងបន្ទាប់ស្វែងរកពីប្រភពព័ត៌មានទូរទស្សន៍ និងវិទ្យុអាចធ្វើការផ្សព្វផ្សាយបានជូនទៅប្រជាពលរដ្ឋ អោយបានដឹងអំពីព័ត៌មានទាំងនេះ។ ជាក់ស្តែងក្នុងសង្គមកម្ពុជាបច្ចុប្បន្ន យើងសង្កេតឃើញមានការបង្កើតនូវច្បាប់ជាច្រើនដែលធ្វើអោយមានការប៉ះពាល់ដល់សិទ្ធិបញ្ចេញក្នុងការផ្សព្វផ្សាយព័ត៌មានពិត។ ដូច្នេះរាជរដ្ឋាភិបាល គួរតែជួយសម្រួលរាល់បញ្ហាទាំងអស់នេះព្រោះថាវាជាតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយសម្រាប់ជាប្រយោជន៍ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មិនពិត។

**ខ. ការសែត និង ទស្សនាវដ្តី**

មានតួនាទីក្នុងការសរសេរអត្ថចុះផ្សាយបន្ទប់ពីបានទទួល និងស្វែងរកពីប្រពភនៃព័ត៌មានរួច ដើម្បីអោយប្រជាពលរដ្ឋបានដឹងអំពីដំណឹងនៃដំណើរការផ្សេងរបស់ប្រទេសជាតិខ្លួន។ រាល់បញ្ហាប្រឈមទាំងអស់ដែលមានការរំលោភបំពាន់ពីសំណាក់រដ្ឋាភិបាលគ្រប់រូបភាព គ្រប់ទម្រង់ សកម្មភាពបំបិទសិទ្ធសេរីភាពក្នុងការចុះផ្សាយរបស់កាសែត និងទស្សនាវដ្តី។ រាជរដ្ឋាភិបាល គួរតែអនុវត្តតាមគោលការណ៍ច្បាប់សិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានចូលជាសមាជិកលើវិស័យសារព័ត៌មាន។

**គ. សិក្ខាសាលា**

ការផ្សព្វផ្សាយព័ត៌មាន តាមរយៈការធ្វើសិក្ខាសាលាវាជាងាយស្រួលមួយសម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ដាច់ស្រយ៉ាលក្នុងការយល់ដឹងពីបញ្ហាសង្គម ការអភិវឌ្ឍ និងនយោបាយ។ តាមរយៈការទទួលបានព័ត៌មាន និងធ្វើការស្វែងយល់ពីព័ត៌មានបានច្បាប់លាស់ ទើបយកមកធ្វើសិក្ខាសាលាបង្ហាញជូនដល់ប្រជា

ពលរដ្ឋអោយបានដឹង។ ដូច្នេះ រដ្ឋាភិបាលគួតែបញ្ឈប់ការហាមឃាត់របស់ខ្លួនទៅលើក្រុមអ្នកធ្វើសិក្ខាសាលានានា ដើម្បីជាប្រយោជន៍ និងលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។

### ១.១.១.៤. ដំណោះស្រាយលើការរឹតបន្តឹងចំពោះសិទ្ធិបង្កើតសមាគម

ដំណោះស្រាយលើការរឹតបន្តឹងចំពោះសិទ្ធិបង្កើតសមាគមទៅលើសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលតម្រូវឲ្យគណបក្សនយោបាយ ត្រូវតែគម្ពល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រទេស និងប្រជាពលរដ្ឋកម្ពុជាឡើយ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគម្ពល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រទេស និងប្រជាពលរដ្ឋឡើយ។ រដ្ឋាភិបាលកម្ពុជា គួរតែរក្សានូវអត្ថន័យមាត្រាទាំងនេះដូចអត្ថន័យដើមតាមមាត្រារដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដដែល ពីព្រោះវាគ្មានការប៉ះពាល់ ឬរឹតត្បិតសិទ្ធិសេរីភាពប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល។ មួយទៀត គឺនូវត្រង់មាត្រា៥៣ ដែលមានការប្រឆាំងដាច់ខាតចំពោះបរទេសដែលជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ទោះបីក្រោមរូបភាពណាក៏ដោយ។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៩ នេះ គឺក្រោយពីអតីតគណបក្សសង្គ្រោះជាតិត្រូវបានរំលាយចោល ហើយប្រធានអតីតគណបក្សនេះ ត្រូវបានឃាត់ខ្លួនក្រោមការចោទប្រកាន់ថា លួចទៅសហការជាមួយបរទេស និងដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជា។ មូលហេតុដែល រដ្ឋាភិបាលផ្តួចផ្តើមធ្វើសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញ ព្រោះការធ្វើវិសោធនកម្មនេះអាចជាអាវុធស្របច្បាប់បន្ថែមទៀតសម្រាប់រដ្ឋាភិបាល ក្នុងការរំលាយគណបក្សសង្គ្រោះជាតិរដ្ឋាភិបាលធ្វើផ្ទុយពីធម្មនុញ្ញភាព និងមានបំណងលុបបំបាត់គ្រប់ទម្រង់នៃការតវ៉ា[88]។ ដូច្នេះហើយ រដ្ឋាភិបាលគួរតែមានការពិភាក្សាដោយសន្តិវិធី ពហុនិយម និងការពិភាក្សានយោបាយដែលបើកចំហជាសាធារណៈនៅពេលចង់ធ្វើសេចក្តីព្រាងអ្វីមួយ។ ដោយសារប្រទេសកម្ពុជា ជាប្រទេសលិទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ អាជ្ញាធរកម្ពុជាគោរពកាតព្វកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

### ១.១.១.៥. ដំណោះស្រាយលើការរឹតបន្តឹងចំពោះសិទ្ធិការជួបប្រជុំជាសាធារណៈ

នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាយើងកំពុងដើរថយក្រោយខាងការគោរពសិទ្ធិមនុស្ស ដោយនៅឆ្នាំ ២០១៣ ការជួបជុំប្រមូលផ្តុំគ្នារបស់កម្មករនិយោជិកត្រូវបានមន្ត្រីនគរបាលធ្វើការបង្ក្រាប និងនៅក្នុងកំឡុងពីរឆ្នាំចុងក្រោយនេះ គឺមានការហាមឃាត់ជាច្រើនករណី។ ប្រទេស ឬរដ្ឋភាគីដែលបានចុះហត្ថលេខាលើកម្រងច្បាប់សិទ្ធិមនុស្ស ត្រូវសន្យាបំពេញភារកិច្ចជូនប្រជាពលរដ្ឋខ្លួន និងធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានទទួលបាន

[88] អត្ថបទ ៖ កម្ពុជាប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែករបស់បរទេស https://thmeythmey.com/?page=detail&id=69407 .

នូវការគោរព ការពារ និងលើកកម្ពស់។ ប្រទេសកម្ពុជា បានក្លាយជាសមាជិកនៃអង្គការសហប្រជាជាតិ និងបានចុះហត្ថលេខាទៅលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងជាប្រទេសហត្ថលេខីនៃកតិកាសញ្ញាអន្តរជាតិមួយចំនួនទាក់ទងសិទ្ធិមនុស្ស នៅពេលដែលប្រទេសកម្ពុជាក្លាយជាសមាជិក ឬជារដ្ឋភាគីរបស់កតិកាសញ្ញានេះ។ ប្រទេសកម្ពុជា ត្រូវតែគោរពប្រតិបត្តិតាមកតិកាសញ្ញានេះឱ្យបានល្អ ជាពិសេសបំពេញកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុង ច្បាប់សិទ្ធិមនុស្សនេះ។ ប៉ុន្តែ ប្រទេសកម្ពុជាកំពុងអនុវត្តតួនាទីរបស់ខ្លួនផ្ទុយនឹងច្បាប់អន្តរជាតិដែលយើងជារដ្ឋសមាជិកដូចជាផ្ទុយនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា១៩ និង មាត្រា២០ ដែលបានចែងថា មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ សម្តែងមតិ និងសេរីភាពក្នុងការជួបប្រជុំជាសាធារណៈ។ ប្រជាពលរដ្ឋ គឺមានសិទ្ធិសេរីភាពគ្រប់គ្រាន់ដើម្បីធ្វើការបញ្ចេញមតិ និងធ្វើការជួបប្រជុំគ្នាតាមច្បាប់កំណត់មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះហើយ រាជរដ្ឋាភិបាលគួរតែគោរពអនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ គឺផ្តល់សិទ្ធិសេរីភាពអោយប្រជាពលរដ្ឋខ្មែរអាចបញ្ចេញមតិរបស់ខ្លួន និងសេរីភាពខាងជួមប្រជុំ។

## ១.២. ដំណោះស្រាយលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិតាមបែបទំនើប

### ១.២.១. ដំណោះស្រាយលើការរឹតបន្តឹងលើប្រព័ន្ធអ៊ីនធើណេត

#### ១.២.១.១. ទូរស័ព្ទដៃ

សង្គមស៊ីវិល ព្រួយបារម្ភចំពោះការលួចថតសំឡេងតាមទូរស័ព្ទប៉ះពាល់សិទ្ធិឯកជន។ ក្រុមសង្គមស៊ីវិលក្នុងស្រុកសម្តែងការព្រួយបារម្ភចំពោះ ការលួចថតសំឡេងសន្ទនាតាមទូរស័ព្ទដោយគ្មានការអនុញ្ញាតដែលជាហានិភ័យខ្ពស់បំផុតចំពោះសិទ្ធិឯកជនរបស់បុគ្គល ឬរបស់ស្ថាប័នណាមួយ។ មន្ត្រីអង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) លោក អំ សំអាត បារម្ភជាខ្លាំងថា សង្គមស៊ីវិលនឹងកាន់តែជួបឧបសគ្គសម្រាប់កិច្ចការរបស់ខ្លួនដែលមានការប្រាស្រ័យទាក់ទងគ្នាតាមទូរស័ព្ទ។ លោកបន្តថា ប្រសិនបើការសន្ទនារបស់ក្រុមសង្គមស៊ីវិល ឬពលរដ្ឋសាមញ្ញតាមប្រព័ន្ធទូរស័ព្ទត្រូវបានគេលួចស្តាប់ ឬលួចថតគ្រប់ពេលវេលា នោះកិច្ចការសម្ងាត់របស់ពួកគាត់នឹងគ្មានសុវត្ថិភាពតទៅទៀតឡើយ។ នៅពេលសង្គមស៊ីវិល ធ្វើការទៅតាមទូរស័ព្ទ ជាពិសេសយើងជាអង្គការសិទ្ធិមនុស្សធ្វើការផ្អែកទៅលើគោលការណ៍ច្បាប់ និងគោរពសិទ្ធិមនុស្ស ហើយយើងគ្មានអ្វីបារម្ភទេ។ ប៉ុន្តែអ្វីដែលយើងនិយាយ ត្រូវបានគេស្តាប់ ហើយកិច្ចការរបស់យើងទាំងអស់គ្មានសុវត្ថិភាពនោះទេ ព្រោះត្រូវគេលួចស្តាប់ទាំងអស់។ ជាក់ស្តែង មាត្រា៣០១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំពើស្តាប់ ឬថតសម្តីដែលនិយាយជាឯកជន ឬជាការសម្ងាត់ដោយគ្មានការយល់ព្រមពីបុគ្គល

ដែលមានការពាក់ព័ន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត។ បញ្ហានេះ អាចសន្មតជាការព្រមព្រៀងទៅបានលុះត្រាបុគ្គលដែលពាក់ព័ន្ធ បានទទួលដំណឹងអំពីការស្លាប់ ឬថតហើយ ហើយបុគ្គលនោះមិនជំទាស់។ ដូច្នេះហើយ រាជរដ្ឋាភិបាល ត្រូវអនុវត្តតួនាទីរបស់ខ្លួនអោយបានទៅតាមច្បាប់បានចែងសម្រាប់ការគ្រប់គ្រងប្រទេស ដើម្បីសុវត្ថិភាពប្រជាពលរដ្ឋ។

### ១.២.១.២. គេហទំព័រនានុលេខន៍ (ប្លុក)

នៅកម្ពុជានាពេលបច្ចុប្បន្ននេះការកើនឡើងនូវសន្ទុះរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសយុវជន គឺមានការយល់ដឹងពីប្រព័ន្ធបណ្តាញសង្គមច្រើន។ ការធ្វើប្លុកមានចំនួនច្រើនក្នុងឆ្នាំ២០២០ នេះ ដែលភាគច្រើនធ្វើទាក់ទងពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនផ្ទាល់។ មានការគាំទ្រ ចាប់អារម្មណ៍ច្រើនពីសំណាក់ប្រជាពលរដ្ឋ ប៉ុន្តែ ដោយសារមានការគំរាមកំហែងពីរាជរដ្ឋាភិបាលដល់សុវត្ថិភាពរស់នៅ ទើបពុំមានយុវជនណាហ៊ានសរសេរ ឬធ្វើប្លុកទាក់ទងនឹងសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ ដោយសារ ការរឹតត្បិតសេរីភាពខាងបញ្ចេញមតិ ជាពិសេសលើសេរីភាពខាងពត៌មានដែលនិយាយពីបញ្ហាសង្គម ការអភិវឌ្ឍន៍ និងបញ្ហានយោបាយ។ រាជរដ្ឋាភិបាល ត្រូតពិនិត្យឡើងវិញនៅត្រង់ចំណុចនេះព្រោះថា ប្រទេសយើងជាប្រទេសសេរីដែលមានការគោរពសិទ្ធិមនុស្ស ព្រោះយើងបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅថ្ងៃពី១០ ខែធ្នូ ឆ្នាំ១៩៤៨។ ហើយនៅត្រង់មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ[89]។ ដូច្នេះ រាជរដ្ឋាភិបាល គួរតែគោរពសិទ្ធិប្រជាពលរដ្ឋដែលរដ្ឋធម្មនុញ្ញបានចែងដូចខាងលើនេះ ដោយផ្តល់សិទ្ធិសេរី និងភាពស្មើគ្នាខាងសិទ្ធិបញ្ចេញមតិ និងសារពត៌មាន។

### ១.២.១.៣. ហ្វេសប៊ុក

ហ្វេសប៊ុក គឺជាប្រព័ន្ធបណ្តាញសង្គមមួយ ដែលមានប្រជាប្រិយមួយ ដែលជាផ្នែកមួយសម្រាប់ផ្សព្វផ្សាយពត៌មានរាល់បញ្ហាដែលទាក់ទងនឹងសង្គម និងនយោបាយ។ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា វាជាផ្នែកមួយសម្រាប់ការបញ្ចេញមតិលើបញ្ហាសង្គម នយោបាយ ជាការចែករំលែកអោយប្រជាពលរដ្ឋបានដឹង។ ប៉ុន្តែវាជាបញ្ហាមួយសម្រាប់ប្រជាពលរដ្ឋខ្មែរ ព្រោះនាពេលបច្ចុប្បន្ន សេរីភាពខាងបញ្ចេញមតិកំពុងមានការធ្លាក់ចុះខ្លាំង នៅអំឡុងឆ្នាំ២០១៦ គឺមានករណីចាប់ខ្លួននិស្សិតដែលបានបង្ហោះសាររិះគន់រាជរដ្ឋាភិបាល។ នៅត្រង់ចំណុចនេះ យើងអាចសន្និដ្ឋានបានថា រដ្ឋាភិបាលមិនបានគោរពតាមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណា

[89] ដូចលេខ ៨១ ខាងលើ។

ចក្រកម្ពុជាទេ គឺការអនុវត្តដើរផ្ទុយពីរដ្ឋធម្មនុញ្ញតែម្តង។ ដូច្នេះ រាជរដ្ឋាភិបាលគួរតែលើកម្ពស់ផ្នែកសិទ្ធិមនុស្សឡើងវិញ ដោយអោយអង្គការសិទ្ធិមនុស្ស និងភ្នាក់ងារពត៌មាន អាចប្រើប្រាស់ហ្វេសប៊ុកដើម្បីជាការចែករំលែកពត៌មានដោយសេរី ហើយមានមនុស្សជាច្រើនបានទទួលពត៌មានពិតប្រាកដដោយគោរពតាមច្បាប់សិទ្ធិមនុស្សជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

### ១.២.១.៤. ធ្វីតធ័រ

ធ្វីតទ័រ សម្រាប់ប្រទេសកម្ពុជាវាជាបណ្តាញសង្គមមួយដែលមិនទាន់មានអ្នកប្រើប្រាស់ច្រើនប៉ុន្មានទេសម្រាប់ប្រជាពលរដ្ឋ និងជាពិសេសយុវជន។ នៅប៉ុន្មានឆ្នាំក្រោយ វាអាចមានការប្រើប្រាស់ច្រើនព្រោះវាត្រូវបានគេប្រើប្រាស់ទូទាំងពិភពលោកក្នុងការចែករំលែងពត៌មាន និងសេរីភាពបញ្ចេញមតិ។ ប៉ុន្តែ ប្រព័ន្ធផ្សព្វផ្សាយនេះត្រូវបានរាជរដ្ឋាភិបាលធ្វើការរិតត្បឹតតាមរយៈការគំរាមកំហែងគ្រប់រូបភាពលើអ្នកដែលរិះគន់លើបញ្ហាសង្គម និងនយោបាយតាមប្រព័ន្ធសង្គម។ ថ្វីត្បិតតែនៅក្នុងប្រទេសកម្ពុជាយើងមិនទាន់មានចំនួនអ្នកប្រើប្រាស់ច្រើន តែរាជរដ្ឋាភិបាលគួរ បើកអោយមានសិទ្ធិសេរីភាពក្នុងធ្វើការបញ្ចេញមតិ ទទួលពត៌មាន ស្វែងរកពត៌មានផ្សព្វផ្សាយពត៌មានបានដោយសេរីនៅលើបណ្តាញសង្គម។ ពីព្រោះប្រទេសកម្ពុជាយើង ជាប្រទេសសេរីដែលមានច្បាប់ការពារចំពោះសិទ្ធិសេរីភាព មានទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

## ១.៣. ដំណោះស្រាយលើបញ្ហាប្រឈមទាក់ទងនឹងច្បាប់ជាតិ

### ១.៣.១. ច្បាប់ថ្មីស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៦/០០៤/២០១៥ កបធ.ច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥[90]។ ច្បាប់នេះ បានធ្វើអោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការប្រឈមនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពក្នុងការអនុវត្តសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ យើងមើលឃើញថា ច្បាប់នេះជាការដាក់កាតព្វកិច្ច និងរំលោភសិទ្ធិស្វ័យភាពបុគ្គល ដូចជាការដាក់របាយការណ៍ជូនក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នីតិវិធីបង់ពន្ធដ៏ស្មុគស្មាញ និងពាក្យពេចន៍ដែលអនុញ្ញាតឱ្យ

[90] ដូចលេខ ៧១ ខាងលើ។

មន្ត្រីរដ្ឋមួយចំនួនធ្វើការបកស្រាយ តាមកាលៈទេសៈ និងតាមស្ថានភាពនយោបាយ រួមទាំងការអនុវត្តន៍ដែលមិនឆ្លុះបញ្ចាំងពីខ្លឹមសារនៃច្បាប់ជាដើម។ ល ។ ការដាក់កាតព្វកិច្ច និងការរំលោភសិទ្ធិស្វ័យភាពបុគ្គលនេះ ជាការអនុវត្តផ្ទុយនឹងក្រមរដ្ឋប្បវេណីជាធរមាន និងកតិកាសញ្ញា អនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។ ដោយសារតែការទទួលរងផលប៉ះពាល់ និងការប្រឈមទាំងនេះហើយ ទើបអង្គការសង្គមស៊ីវិល បានធ្វើការសិក្សា ពិភាក្សា និងវិភាគយ៉ាងស៊ីជម្រៅទៅលើមាត្រានីមួយៗនៃច្បាប់នេះ និងបានដាក់ជូនដល់ក្រសួងមហាផ្ទៃរួចរាល់ នូវសំណើជាលាយលក្ខណ៍អក្សរដែលចាំបាច់ត្រូវកែប្រែ រួមមាន ១៤ មាត្រា មានដូចជាមាត្រា ១, ៧, ៨, ៩, ១០, ១១, ២០, ២៤, ២៥, ២៦, ៣០, ៣១, ៣២ និងមាត្រា ៣៥។ សូមបញ្ជាក់ថា អនុសាសន៍សង្គមស៊ីវិលដែលបានស្នើឡើង ត្រូវបានដាក់បញ្ចូលគ្នាចាប់តាំងពីកិច្ចប្រជុំលើកទី២ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ ពោលគឺពុំមានសំណើផ្សេងគ្នា ឬមិនត្រូវគ្នាណាមួយនោះឡើយ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលស្នើសុំយ៉ាងទទូចចំពោះក្រុមការងាររាជរដ្ឋាភិបាល ដូចខាងក្រោម ៖

១. គួរមានផែនទីបង្ហាញផ្លូវដោយកំណត់ពេលវេលាជាក់លាក់ នៅក្នុងដំណើរការនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាលនេះ ។

២. ទទួលយកសំណើរបស់ក្រុមសមាគម និង អង្គការមិនមែនរដ្ឋាភិបាល និង ពន្លឿនការធ្វើវិសោធនកម្មច្បាប់ឲ្យបានឆាប់រហ័ស ដើម្បីធានាសិទ្ធិ និង សេរីភាពពេញលេញរបស់អង្គការសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ[91] ។

៣. សុំឱ្យមានការជជែកដាច់ដោយឡែកពីគ្នាជាមួយក្រុមផ្សេងៗ ដែលបានដាក់សំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីងាយស្រួលក្នុងការពិភាក្សា ។

ឈ្មោះសមាគម និង អង្គការមិនមែនរដ្ឋាភិបាល គាំទ្រសេចក្តីថ្លែងការណ៍នេះ ៖

- គណកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌ នៅកម្ពុជា (COMFREL)
- សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
- មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និង សន្តិភាព (PDP-Center)
- អង្គការកម្មវិធី អភិវឌ្ឍន៍ ធនធានយុវជន (YRDP)
- មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (CENTRAL)

[91] សេចក្តីថ្លែងការណ៍រួមស្តីពីផលប៉ះពាល់នៃច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងដំណើរធ្វើវិសោធនកម្ម (រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០) ៖ https://www.central-cambodia.org/km/archives/3473 .

- សហព័ន្ធសហជីពកម្មករចំណីអាហារ និង សេវាកម្មកម្ពុជា (CFSWF)
- មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
- សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
- សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
- អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
- សម្ព័ន្ធគណនេយ្យភាពសង្គម កម្ពុជា (ANSA)
- សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និង អភិវឌ្ឍន៍ (KKKHRDA)
- អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
- សមាគមយុវជនខ្មែរ (KYA)
- សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA)
- អង្គការសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ (YCUD)
- អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
- សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)
- អង្គការស្ពានសន្តិភាព (PBO)
- អង្គការតម្លាភាពកម្ពុជា (TIC)
- សហព័ន្ធសហជីពកម្ពុជា (CATU)

### ១.៣.២. ច្បាប់ស្តីពីសហជីព

ច្បាប់នេះគួរតែ ប្រើប្រាស់ពាក្យពេជន៍អោយបានច្បាប់លាស់ និងអោយចំគោលបំណងនៃច្បាប់ចង់កំណត់សម្រាប់ការអនុវត្តទៅក្រុមសហជីព។ ហេតុផលជាច្រើនក្នុងចំណោហេតុផលទាំង ៧ នេះមានលក្ខណៈមិនច្បាស់លាស់ និងអាចត្រូវបានប្រើប្រាស់ដើម្បីបដិសេធការសុំចុះបញ្ជីរបស់សហជីពតាមអំពើចិត្ត ដូចជា ប្រសិនបើគោលដៅ ឬគោលបំណងរបស់សហជីព សមាគម " មិនការពារ ឬលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់បុគ្គលទេនោះ" ឬ " វិសាលភាព ឬកម្មវត្ថុរបស់សហជីព ឬសមាគមនិយោជកមានភាពមិនច្បាស់លាស់ដែលអាចធ្វើអោយសាធារណជនភ័ន្តច្រឡំ" ជាដើម។ ប្រកាសលេខ ២៤៩ ក៏តម្រូវអោយថ្នាក់ដឹកនាំសហជីព ឬសមាគមនិយោជកផ្តល់នូវលិខិតប្រកាសដោយមានផ្តិតស្នាមមេដៃថាពួកគេអាចអាន និងសរសេរភាសាខ្មែរ ហើយពួកគេមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋនោះឡើយ ហេតុដូច្នេះ ករណីនេះផាត់ចេញនូវបុគ្គលដែលមិនចេះអក្សរ ឬអ្នកដែលធ្លាប់មានទោសពីបទល្មើសណាមួយពីមុនមក។ នៅត្រង់

ចំណុចនេះ រាជរដ្ឋាភិបាលគួរតែមានការគិតគូរឡើងវិញ ព្រោះថាប្រទេសយើងជាប្រទេសលិទ្ធិប្រជាធិបតេយ្យ។ ដូច្នេះហើយការគោរពសិទ្ធិសេរីភាពរបស់សហជីព ឬប្រជាពលរដ្ឋគួរតែមានភាពទូលំទូលាយ។

### ១.៣.៣. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

បញ្ហាដែលជាបញ្ហាប្រឈម គឺមាត្រា៨៤ និងមាត្រា១៣៧ នៃច្បាប់ស្តីពីការឆ្នោតជ្រើសតាំងតំណាងរាស្ត្រតម្រូវអោយអង្គការ និងសមាគមក្នុងស្រុក និងអន្តរជាតិទាំងអស់ត្រូវប្រកាន់ជំហរ "អព្យាក្រឹតឥតលម្អៀង" ពាក់ពន្ធនឹងកិច្ចការបោះឆ្នោត។ បញ្ញត្តិដែលប្រើពាក្យពេជន៍មិនច្បាស់លាស់នេះអាចកាត់បន្ថយច្រើនដល់ការបំពេញតួនាទីរបស់សង្គមស៊ីវិលក្នុងនាមជាអ្នកឃ្លាំមើលសាធារណៈ។ មាត្រា ១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា "ជនណាដែលធ្វើការប្រមាថ តាមគ្រប់មធ្យោបាយ ជាសាធារណៈចំពោះគណបក្សនយោបាយណាំមួយ" នឹងត្រូវផាកពិន័យ។ នៅក្នុងមាត្រាខាងលើ យើងត្រូវកែប្រែ និងទទួលយកគំនិតយោបាលពីការរិះគន់ នៅត្រង់ណាដែលធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ។ ហើយរាជរដ្ឋាភិបាលត្រូវអនុវត្ត និងដើរអោយស្របតាមបទដ្ឋានអន្តរជាតិ និងបទដ្ឋានជាតិដែលមានការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

### ១.៣.៤. ច្បាប់ស្តីពីគណបក្សនយោបាយ

បញ្ហាប្រឈមដែលកើតមានក្នុង មាត្រា ១៨ តម្រូវអោយថ្នាក់ដឹកនាំគណបក្សនយោបាយមិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីពទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ។ មាត្រា ៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយចែងអំពីសកម្មភាពដែលត្រូវហាមឃាត់ដែលគណបក្សនយោបាយណាមួយអាចត្រូវផ្អាក ឬត្រូវរំលាយចោល រួមទាំងការ "ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" "ធ្វើអោយប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ" និង "ធ្វើការញុះញង់ដែលអាចនាំអោយមានការបែកបាក់ជាតិ"។ ការប្រើប្រាស់ភាសាទាំងនេះមានភាពមិនច្បាស់លាស់ និងមានលក្ខណៈអត្តនោម័ត្ត ដែលបង្កើនហានិភ័យដែលថា ច្បាប់នេះអាចយកទៅអនុវត្តតាមអំពើចិត្ត និងអាចគំរាមកំហែងដល់វត្តមានរបស់គណបក្សនយោបាយទៀតផង។ ដូច្នេះ រាជរដ្ឋាភិបាលគួរតែរក្សា ឬអនុវត្តតាមច្បាប់ស្តីពីគណបក្សនយោបាយដែលមិនទាន់វិសោធនកម្មនៅពេលចុងក្រោយនេះ ព្រោះថាក្រោយការធ្វើវិសោធនកម្មនេះហើយ គឺមានផលប៉ះពាល់ជាច្រើនដល់គណបក្សនយោបាយ។

### ១.៣.៥. ច្បាប់ស្តីពីការអប់រំ

បញ្ហាដែលគួរដោះស្រាយ គឺមាត្រា ៥២ ចែងថា ប្រសិនបើនីតិបុគ្គលណារំលោភបំពានលើមាត្រា ៣៤ នឹងត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០ ទៅ ២០ លានរៀល។ ចំនួនពិន័យនេះនឹងកើន ២ដងក្នុងករណីមិនរាង

ចាល។ ការពិន័យចុងក្រោយនេះនឹងត្រូវអនុវត្ត "ក្នុងករណីមិនរាងចាល" ដែលប្រព្រឹត្តដោយនីតិបុគ្គលដែលជាគ្រឹះស្ថានសិក្សា។ ក្នុងកាលៈទេសៈនេះ នឹងព្យួរជាបណ្តោះអសន្ន ឬដលហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់គ្រឹះស្ថានសិក្សានោះ ដែលករណីនេះមិនអាចនិយាយថាមានសមាមាត្រឡើយ។ ពីព្រោះ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ មានសេចក្តីណែនាំដល់ស្ថាប័នអប់រំ ស្តីពីការទប់ស្កាត់ការធ្វើសកម្មភាព ឬឃោសនានយោបាយនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជន។ បានហាមឃាត់ច្រើនចំពោះសកម្មភាពនយោបាយនៅគ្រឹះស្ថាន និងស្ថាប័នសិក្សា។ មាត្រា ៣៤ នៃច្បាប់ស្តីពីការអប់រំចែងថា "ការធ្វើសកម្មភាពនយោបាយ និង/ឬការឃោសនានយោបាយអោយគណបក្សនយោបាយណាមួយក្នុងគ្រឹះស្ថាប័នអប់រំ គ្រឹះស្ថាប័នសិក្សាត្រូវហាមឃាត"។ តាមការវិភាគរបស់អ្នកវិភាគទាក់ទងនឹងបញ្ហាដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា បានវិភាគថាបញ្ហាខាងលើវាជាការរឹតត្បិតសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីសិទ្ធិប្រជាពលរដ្ឋក្នុងការបញ្ចេញមតិដែលទាក់ទងនឹងបញ្ហានយោបាយបានយ៉ាងទូលំទូលាយ។ ដូច្នេះ រាជរដ្ឋាភិបាលគួរតែគិត នៅត្រង់បញ្ហាប្រឈមនេះឡើងវិញ ដើម្បីជួយស្តារការរំលោភសិទ្ធិមនុស្សនៅកម្ពុជា។

### ១.៣.៦. ច្បាប់ស្តីពីទូរគមនាគមន៍

នៅក្នុងរយៈពេលចុងក្រោយនេះប្រទេសកម្ពុជា សិទ្ធិបច្ចេវិទ្យា ជាក់ស្តែងសេរីភាពខាងបញ្ចេញមតិលើបណ្តាញអ៊ីនធឺណេត បានក្លាយទៅជាឧបសគ្គឈានមុខគេក្នុងការការពារសិទ្ធិមនុស្សក្នុងប្រទេស។ ស្របពេលនឹងការរីកសាយភាយយ៉ាងឆាប់រហ័សចំពោះការប្រើប្រាស់អ៊ីនធឺណេតទូទាំងប្រទេសកម្ពុជា ប្រជាពលរដ្ឋសាមញ្ញមានលទ្ធភាពទទួលបានពត៌មានដែលមិនធ្លាប់មានពីមុនមក ផ្តល់អំណាចដល់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងវិស័យនយោបាយដែលមិនធ្លាប់មានពីមុនមកដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរបច្ចេកវិទ្យាឆ្ពោះទៅរកការប្រើប្រាស់វេទិកាលើបណ្តាញសង្គមអ៊ីនធឺណេត ដើម្បីធ្វើការសម្តែងមតិទាក់ទងនឹងបញ្ហានានាដែលមានក្នុងសង្គម បញ្ហានយោបាយជាដើម។ ដោយសារប្រជាពលរដ្ឋ មានការយល់ដឹងបានទូលំទូលាយរដ្ឋាភិបាលបានចាប់ធ្វើការផ្លាស់ប្តូរប្រព័ន្ធត្រួតពិនិត្យតាមដានថ្មី ដែលធ្វើអោយប្រជាពលរដ្ឋមានរាប់លាននាក់ស្ថិតក្រោមការត្រួតពិនិត្យយ៉ាងល្អិតល្អន់ដោយផ្ទាល់ពីសំណាក់រដ្ឋាភិបាល។ ជាពិសេស រដ្ឋាភិបាលបានបង្កើនសមត្ថភាពរបស់ខ្លួនដល់អាជ្ញាធរ ដើម្បីធ្វើការឃាយីតាមផ្លូវតុលាការដល់អ្នកដែលជំទាស់នឹងផលប្រយោជន៍របស់រដ្ឋាភិបាល។ ការដែលស្នើសុំបង្កើតច្បាប់ស្តីពីទូរគមនាគមន៍ កាលពីឆ្នាំ២០១៦ នេះ គឺរដ្ឋាភិបាលមានបំណងប្រើប្រាស់លទ្ធភាពតាមដានប្រជាពលរដ្ឋ និងការបង្កើនអំណាចក្នុងការបំបិទសម្លេងរិះគន់។

### ១.៣.៧. សេចក្តីព្រាងច្បាប់អំពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត

បញ្ហាផ្លូវច្បាប់ ដែលលេចចេញពីការឆ្លោះទៅរកការសំដែងមតិបណ្តាញអ៊ីនធឺណេត មិនបានបង្ហាញពីភាពខ្មៅ និងសនោះទេ។ បញ្ហាបន្ទាន់បំផុតមួយ ដែលត្រូវធ្វើបន្ទាប់ពីរដ្ឋាភិបាលបានស្នើពីសេចក្តីព្រាងច្បាប់អំពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត គឺទាមទារអោយរាជរដ្ឋាភិបាល និងប្រព័ន្ធតុលាការកម្ពុជាត្រូវតែមានការផ្លាស់ប្តូរ និងបង្កើតវិធីសាស្រ្តសមហេតុផលមួយចំពោះការផ្តល់មតិយោបល់លើបណ្តាញអ៊ីនធឺណេត។ នៅក្នុងករណីមួយចំនួនដែលមានបុគ្គលដែលប្រើប្រាស់អ៊ីនធឺណេត គឺជាអ្នកដែលបង្ហោះទាំងនោះមិនគួរត្រូវបានចាត់ទុកថាបទល្មើសព្រហ្មទណ្ឌនោះទេ នៅក្នុងសង្គមប្រជាធិបតេយ្យដ៏ល្អ។ ពាក់ព័ន្ធនឹងមតិយោបល់ ដែលសំដៅលើបុគ្គលសាធារណៈច្បាប់សិទ្ធិមនុស្សអន្តរជាតិទាមទារអោយមានការអធ្យាស្រ័យច្រើនចំពោះ ការបញ្ចេញមតិពាក់ព័ន្ធនឹងមន្រ្តីសាធារណៈ។ ខណៈពេលដែលមានការប្រើប្រាស់ច្បាប់នេះមានការកំណត់មុខសញ្ញាបុគ្គលដែលបង្ហោះខ្លឹមសារលើបណ្តាញអ៊ីនធឺណេតការបង្កើតច្បាប់ថ្មីនេះ បានធ្វើអោយមានព្រួយបារម្ភ ថែមទាំងវាមិនចាំបាច់ផងដែរ។ ច្បាប់ស្តីពីឧក្រិតកម្មអ៊ីនធឺណេត ធ្វើឡើងមិនអោយស៊ីសង្វាក់ជាមួយនឹងការធានារបស់ច្បាប់សិទ្ធិមនុស្ស និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ នៅត្រង់ចំណុចខ្លះនៃច្បាប់នេះ ក៏មានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជារួចហើយ និងការដាក់ទណ្ឌកម្មគឺមានភាពធ្ងន់ធ្ងរចំពោះអ្នកដែលមានការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណេត។ ដូច្នេះ រដ្ឋាភិបាលគួរតែធ្វើការលុបចោល ឬកែប្រែនូវសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មអ៊ីនធឺណេតអោយមានធូរស្រាល ព្រោះថាច្បាប់នេះមានភាពរឹតត្បិតសិទ្ធិសេរីភាពរបស់ប្រជាពល និងអង្គការសង្គមស៊ីវិលខាងផ្នែកបញ្ចេញមតិនៅកម្ពុជា។ ចំណុចសំខាន់ប្រព័ន្ធអ៊ីនធឺណេត គឺជាផ្នែកមួយនៃការសម្តែងមតិរបស់ប្រជាពលរដ្ឋ និងរបស់អង្គការសង្គមស៊ីវិលដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពសង្គមកម្ពុជាជាក់ស្តែងអំពីដំណើរ ការអភិវឌ្ឍន៍បញ្ហានានាទាក់ទងនឹងនយោបាយ ។

### ១.៣.៨. ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន បានអនុម័តដោយសំឡេង ១១៥ នៃចំនួនសមាជិកសភាទាំងមូល។ សម័យប្រជុំពេញអង្គលើកទី៤ នីតិកាលពីទី៦ នាព្រឹកថ្ងៃទី១០ ខែមេសា ក្រោមអធិបតីភាពសម្តេច ហេង សំរិន ប្រធានរដ្ឋសភាព្រមទាំងមានវត្តមានសម្តេចតេជោ ហ៊ុនសែន នាយករដ្ឋមន្រ្តី សម្តេចក្រឡា ហោម ស ខេង ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ព្រមទាំងសមាជិករដ្ឋសភា សរុប ១១៥នាក់ ។ លោកប៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌បានលើកឡើងថា សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ននេះ មាន ១២មាត្រា និង ៥ជំពូក ហើយសេចក្តីព្រាងច្បាប់នេះ បានបើកិច្ចប្រជុំជាមួយសមាជិកគណៈកម្មការនានា នៃក្រុមប្រឹក្សាអ្នកច្បាប់នៅរដ្ឋសភា និងជាមួយរដ្ឋមន្រ្តី

ក្រសួងយុត្តិធម៌ផងដែរ។ លោកបន្តថា សេចក្តីព្រាងច្បាប់នេះ គាក់តែងឡើងស្របតាមច្បាប់រដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានលើកឡើងដែរថា សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្មារតីនៃមាត្រា ២២ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងថា នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រប្រកាស ប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋប្រធានព្រឹទ្ធសភា។ ផ្អែកតាមមាត្រា ២២ថ្មីនេះ ការសម្រេចដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន គឺត្រូវធ្វើឡើងនៅពេលដែល ប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស ពេលមានគ្រោះអាសន្ន បន្ទាន់ចំពោះសុខភាពសាធារណៈ បណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយ ធ្ងន់ធ្ងរ ដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេសជាដើម។ ប៉ុន្តែមាត្រា ២២ថ្មី ក៏ដូចជាមាត្រាដទៃទៀតនៃរដ្ឋធម្មនុញ្ញ ពុំបានចែងអំពីវិធានការគ្រប់គ្រងប្រទេសជាតិក្រោយពីត្រូវបានប្រកាសដាក់ឲ្យស្ថិតនៅក្នុងភាពអាសន្ន គឺជាតម្រូវការចាំបាច់មិនអាចខ្វះបានដើម្បីកំណត់អំពីសិទ្ធិអំណាចរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការចាំបាច់នានាសំដៅឆ្លើយតបទៅនឹងស្ថានភាពអាសន្នក្នុងកាលៈទេសៈដូចបានរៀបខាងលើ បន្ទាប់ពីប្រទេសជាតិ ត្រូវបានប្រកាសដាក់ឲ្យស្ថិតនៅក្នុងអាសន្ន។ លោកបានបន្តថា សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់មូលដ្ឋានគតិយុត្តិធានាដល់ការអនុវត្តមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញផងនិងជាមូលដ្ឋានគតិយុត្តិកំណត់អំពីសិទ្ធិអំណាច របស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការនានាដែលមានចរិកជាការហាមឃាត់ ឬការកម្រិតនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែវិធានការនេះមានភាពចាំបាច់មិនអាចខ្វះបានដើម្បី ឆ្លើយតបទៅនឹងស្ថានភាពរបស់ប្រទេសជាតិក្នុងគ្រាអាសន្នសំដៅការការពារសន្តិសុខជាតិនឹងសណ្តាប់ធ្នាប់ធារណៈ ការពារអាយុជីវិតនិងសុខ ភាពរបស់ ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថានផងដែរ។ លោកថា ឆ្លងតាមការសិក្សាផ្អែកនៅតាមបណ្តាប្រទេសលើសកលលោក គឺប្រទេសជាតិមិនអាចខ្វះបានក្នុងការមានច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។ លោកបន្ថែមថា សេចក្តីព្រាងច្បាប់ក៏បានលើកឡើងថា វិធានការអនុវត្តពេលប្រទេសជាតិស្ថិត ក្នុងភាពអាសន្ននៅពេលអាចត្រូវបានដាក់ចេញសម្រាប់ទូទាំងប្រទេស ឬដែនដីកំណត់ជាក់លាក់ណាមួយ។ ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតយន្តការ ឬប្រគល់សិទ្ធិអំណាចទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬប្រើប្រាស់កម្លាំងប្រដាប់អាវុធ ដើម្បីធានាដល់ការអនុវត្តវិធានការខាងលើ។ ក្នុងពេលសង្គ្រាម ឬក្នុងកាលៈទេសៈ ដទៃទៀត ដែលសន្តិសុខជាតិប្រឈម

មុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរកាគ្រប់គ្រងប្រទេសជាតិ ស្ថិតក្នុងភាពអាសន្ននេះ អាចធ្វើឡើងតាមរបបអាជ្ញាសឹក។[92] ការលើកឡើងរបស់រាជរដ្ឋាភិបាលពិតជាត្រឹមត្រូវ នឹងមានការទទួលខុសត្រូវខ្ពស់ចំពោះការការពារប្រជាពលរដ្ឋរបស់ខ្លួន។

ប៉ុន្តែនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រង ប្រទេសជាតិក្នុងភាពអាសន្ននេះមានចំណុចខ្លះមានពាក្យពេចន៍ដែលមានទូលាយ និងមិនសូវច្បាស់លាស់ នៅក្នុងច្បាប់នេះអាចកបស្រាយបានយ៉ាងទូលាយ ដើម្បីធ្វើអោយការដាក់ប្រទេសក្នុងភាពអាសន្នស្របច្បាប់ស្ទើរគ្រប់ស្ថានភាពទាំងអស់។ ដោយមិនមានការកំណត់អំពីពេលវេលាបញ្ចប់ច្បាស់លាស់ ការប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន មានការហាមឃាត់ ឬរឹតត្បិត អាចនឹងត្រូវបានធ្វើក្នុងរយៈពេលវែង។ ដែលធ្វើអោយប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើដំណើរ សិទ្ធិជួមជុំ ឬប្រមូលផ្ដុំ ការធ្វើសកម្មភាពការងារ ការគ្រប់គ្រង់ទ្រព្យសម្បត្តិ និងការបញ្ចេញមតិ។ ហើយមិនបានបញ្ជាំងឆន្ទៈនយោបាយស្មោះត្រង់ បម្រើផលប្រយោជន៍រួមរបស់ពលរដ្ឋនោះទេ។ តែផ្ទុយទៅវិញ ច្បាប់នេះមានមហិច្ឆតាគំរាមកំហែងសំឡេងរិះគន់ទាំងឡាយ ក្នុងប្រព័ន្ធទំនាក់ទំនងសង្គម និងផ្ដល់ឱកាសឱ្យអ្នកមានអំណាច កាប់បំផ្លាញព្រៃឈើ និងធ្វើអាជីវកម្មឈើខ្នាតធំជាបន្តទៀត។ ក្រោយពីច្បាប់នេះបានប្រកាសអោយប្រើ មានអង្គការសង្គមស៊ីវិល អ្នកវិភាគច្បាប់មួយចំនួន បានបកស្រាយពីផលប៉ះពាល់ជាច្រើនដូចបានរៀបរាប់ខាងលើ។ ប្រជាពលរដ្ឋ និងក្រុមអង្គការសង្គមស៊ីវិលនានាដែលមានក្ដីបារម្ភណ៍ចំពោះផលប៉ះពាល់ខាងសិទ្ធិសេរីភាពរបស់ខ្លួន។ ដោយប្រទេសកម្ពុជាជាប្រទេសលិទ្ធិប្រជាធិបតេយ្យគោរពសិទ្ធិមនុស្ស ដូច្នេះ រាជរដ្ឋាភិបាលគួរតែមានការកំណត់អំពីពេលវេលាអោយបានច្បាប់លាស់ណាមួយនៅពេលប្រទេសមានភាពប្រក្រតីវិញ ច្បាប់នេះត្រូវនិរាករណ៍ចោលវិញដោយគ្មានលក្ខខណ្ឌអ្វីឡើយ។

92 អត្ថបទ៖ រដ្ឋសភាអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយសំឡេង១១៥៖ https://dap-news.com/national/2020/04/10/47597 .

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សិទ្ធិសេរីភាពនៃការបញ្ចេញមតិពិតជាដើរតួយ៉ាងសំខាន់ក្នុងសង្គមប្រជាធិបតេយ្យ ដោយសារវាបានឆ្លុះបញ្ចាំងពីការប្រើប្រាស់នូវសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងប្រទេស។ នៅក្នុងប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើបទដ្ឋានគតិយុត្តិអន្តរជាតិជាច្រើនធំៗ ដើម្បីធានាការគោរពសិទ្ធិមនុស្សនៅកម្ពុជាដូចជា រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាដើម។ រួមមានបទដ្ឋានជាតិជាច្រើនទៀតដែលស្ថិតក្រោមដំបូលនៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្នុងការធានាអោយបាននូវសេរីភាពបញ្ចេញមតិមួយយ៉ាងទូលំទូលាយ និងពេញលេញនៅកម្ពុជា។ ថ្វីបើមានច្បាប់ជាតិ និងអន្តរជាតិការពារ ក៏នូវតែមានបញ្ហាប្រឈមនៃសិទ្ធិសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជានៅតែមានស្ថានភាពធ្ងន់ធ្ងរ ហើយច្បាប់កម្ពុជាជាច្រើនបានគាប់សង្កត់មកលើសិទ្ធិសេរីភាពបញ្ចេញមតិគួរអោយកត់សម្គាល់។ ថ្មីៗនេះក៏មានច្បាប់បង្កើតដោយរាជរដ្ឋាភិបាលធ្វើអោយប៉ះពាល់ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានរឹតត្បឹតសិទ្ធិសេរីភាពរបស់ពួកគេ។ ដូចដែលបានរៀបរាប់ខាងលើប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាមានសារព័ត៌មានឯករាជ្យមួយចំនួនតែងតែរងនូវការគំរាមកំហែង និងរារាំងការផ្សព្វផ្សាយព័ត៌មានពិតអំពីបញ្ហានានានៅក្នុងប្រទេសកម្ពុជា។ ហើយប្រព័ន្ធសារព័ត៌មានជាច្រើនបដិសេធមិនព្រមផ្សាយព័ត៌មានដែលទាក់ទងនឹងគណបក្សប្រឆាំង និងបញ្ហាដែលកើតមានឡើងពីការដឹកនាំប្រទេសរបស់រាជរដ្ឋាភិបាលឡើយ។ លើសពីនេះទៀតប្រព័ន្ធអ៊ីនធឺណេត គឺជាមធ្យោបាយដែលអាចធ្វើការបញ្ចេញមតិក្នុងការចែកចាយព័ត៌មាននៅក្នុងកម្ពុជា ហើយប្រជាពលរដ្ឋកម្ពុជាអាចប្រើប្រាស់សិទ្ធិសេរីភាព របស់ខ្លួនក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតសម្រាប់ធ្វើការពិភាក្សាពីបញ្ហា នយោបាយជជែកពិភាក្សាបញ្ហាសង្គម និងបញ្ហានៃដំណើរការដឹកនាំប្រទេស។ ប៉ុន្តែ នៅពេលបច្ចុប្បន្នរាជរដ្ឋាភិបាលបានបង្កើតច្បាប់សម្រាប់ការគ្រប់គ្រងលើប្រព័ន្ធធីណេតដែលមានខ្លឹមសារគាបសង្កត់ទាក់ទងនឹងនយោបាយ ការរឹតត្បឹតលើសិទ្ធិសេរីភាពបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណេត។ នឹងច្បាប់ដែលដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដែលធ្វើអោយរាជរដ្ឋាភិបាលមានអំណាចសម្រាប់ការរំលោភ និងបំបិទសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋដោយស្របច្បាប់មន្ថែមទៀត។

ដើម្បីជាការចូលរួមក្នុងការជួយកាត់បន្ថយបញ្ហាប្រឈមចំពោះ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជាអោយមានភាពប្រសើរឡើង គឺដោយសារមានការចូលរួមជ្រោមជ្រែងពីសំណាក់អង្គការសង្គមស៊ីវិលជាច្រើន ដែលបានធ្វើការឆ្លុះបញ្ចាំងនូវតថភាពសង្គមជាក់ស្តែងដែលប្រជាពលរដ្ឋចង់បាន។ រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតអោយមានអង្គការសង្គមស៊ីវិលជាច្រើនដែលមានភាពចម្រុះ និងមានសកម្មរស់រវើកក្នុងការការពារសិទ្ធិ

សេរីភាពរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែជាក់ស្តែងបុគ្គល ឬក្រុមអង្គការសង្គមស៊ីវិលណាដែលធ្វើការវិភាគ ផ្តល់មតិយោបល់ដែលពាក់ព័ន្ធទៅលើប្រធានបទចម្រូងចម្រាស់ទាក់ទងបញ្ហាសង្គម នយោបាយ តែងតែត្រូវរដ្ឋាភិបាលដៅមុខសញ្ញាក្នុងគោលបំណងបំបិទមតិប្រឆាំង។ ដូចដែលបានរៀបរាប់ខាងលើ ការគំរាមកំហែង ការប្រើប្រាស់ហិង្សា ការសម្លុតបំភ័យ និងការយាយីតាមប្រព័ន្ធតុលាការ ជាវិធីទូទៅដែលអាជ្ញាធរប្រើដើម្បីបំបិទមាត់តួអង្គសង្គមស៊ីវិល និងប្រជាពលរដ្ឋ។ ជំនួសអោយការធ្វើការជាមួយអង្គការសង្គមស៊ីវិល ឬប្រជាពលរដ្ឋ រាជរដ្ឋាភិបាលអះអាងថាអង្គការសង្គមស៊ីវិល ឬប្រជាពលរដ្ឋណាដែលហ៊ានរិះគន់លើគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាស់ជាមានទំនាក់ទំនងជាមួយនឹងគណបក្សប្រឆាំង។ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលតែងតែមានការគាបសង្កត់រួមជាមួយនឹងសេរីភាពខាងជួបប្រជុំ និងធ្វើសមាគមពីសំណាក់រដ្ឋាភិបាលផ្ទាល់។ រដ្ឋាភិបាលបានប្រើប្រាស់កងកម្លាំងអាជ្ញាធរអោយបង្ក្រាប់ទៅលើក្រុមបាតុករ ហើយច្បាប់ស្តីពីសមាគម និងអង្គការសង្គមស៊ីវិលដែលរដ្ឋាភិបាលទើបបង្កើតឡើងមានការគំរាមកំហែង រឹតបន្តឹងមកលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលយ៉ាងធ្ងន់ធ្ងរ។ មិនតែប៉ុណ្ណោះសិទ្ធិសេរីភាពបញ្ចេញមតិក៏ត្រូវបានគាប់សង្កត់ផងដែរនៅក្នុងវិស័យអប់រំនៅកម្ពុជា ព្រោះថារដ្ឋាភិបាលបានហាមមិនអោយនិយាយរឿងនយោបាយនៅក្នុងស្ថាប័នទាំងរដ្ឋ និងទាំងឯកជន។

យើងខ្ញុំគិតថា នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្នកំពុងមានបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិយ៉ាងធ្ងន់ធ្ងររបស់ប្រជាពលរដ្ឋ នឹងអង្គការសង្គមស៊ីវឹងបើប្រៀបធៀបទៅនឹងសម័យមុន។ ក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងគួរតែពិចារណាទៅលើបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ ហេតុអ្វីបានរដ្ឋាភិបាលធ្វើអោយមានបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិកើតមានឡើងជាបន្តបន្ទាប់ ហើយការអនុវត្តច្បាប់សិទ្ធិមនុស្សមានលក្ខណៈមិនត្រឹមត្រូវ និងគ្មានតម្លាភាពចំពោះប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល។ ប្រសិនបើ រដ្ឋាភិបាលទទួលយកការរិះគន់ពីសំណាក់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល នាងខ្ញុំជឿជាក់ថាបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិនឹងដោះស្រាយបាន។

# អនុសាសន៍

# អនុសាសន៍

ដោយបានពិចារណាទៅលើស្ថានភាព សិទ្ធិបញ្ចេញមតិនៅកម្ពុជានាពេលបច្ចុប្បន្ននេះ គឺមានបញ្ហាប្រឈមចំពោះសិទ្ធិបញ្ចេញមតិគួរអោយបារម្ភណ៍ជាខ្លាំង យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនជូនទៅរាជរដ្ឋាភិបាលកម្ពុជាចំពោះបញ្ហាមួយចំនួនដូចជា បញ្ហាច្បាប់ បញ្ហាប្រព័ន្ធផ្សព្វផ្សាយ និងបញ្ហាអង្គការសង្គមស៊ីវិលដើម្បីធ្វើអោយសិទ្ធិបញ្ចេញមតិនៅកម្ពុជាមានភាពប្រសើរជាងពេលបច្ចុប្បន្ន និងធានាអោយមានការប្រើប្រាស់នូវសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលបានពេញលេញ និងទូលំទូលាយ។

<u>រាជរដ្ឋាភិបាល</u>

- គោរពការធានាថាមាននៃសិទ្ធិនៃការបញ្ចេញមតិដែលមាននៅក្នុងប្រទេសកម្ពុជា និងច្បាប់អន្តរជាតិដោយធានាថាមិនមានការហាមឃាត់ចំពោះគេហទំព័រណាដែលរិះគន់រដ្ឋាភិបាល។
- ស្នើសុំធ្វើសោធនាកម្មច្បាប់ក្នុងក្រមព្រហ្មទណ្ឌ ដែលបានរឹតត្បិតលើសិទ្ធិបញ្ចេញមតិ ឬដែលអាចនឹងត្រូវបានប្រើប្រាស់ដើម្បីរឹតត្បឹតលើសិទ្ធិបញ្ចេញមតិ ដោយស្របច្បាប់ដោយប្រើពាក្យពេចន៍ច្បាប់អោយកាន់តែមានភាពច្បាស់លាស់។
- ធានាថាករណីផ្លូវច្បាប់ពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ត្រូវយកច្បាប់ស្តីពីរបបសាព័ត៌មានមកប្រើមិនមែនក្រមព្រហ្មទណ្ឌដែលមានលក្ខណៈរឹតបន្តឹងនោះទេ។
- ធានាអោយបាននូវការគ្រប់គ្រងសារព័ត៌មានដោយឯករាជ្យ ដែលមិនលម្អៀងទៅកាន់គណបក្សកាន់អំណាច នៅពេលដេលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណ និងសេរីភាពក្នុងការធ្វើ ប្រតិបត្តិការ ដើម្បីនាំអោយមានស្ថាប័នសារព័ត៌មានចម្រុះ និងដើម្បីលើកកម្ពស់វិជ្ជាជីវៈ និងភាពមិនលម្អៀងក្នុងចំណោមអ្នកសារព័ត៌មាន និងអ្នកវិជ្ជាជីវៈសារព័ត៌មានដទៃទៀត។
- ជម្រុញអោយមានការស៊ើបអង្កេត និងដាក់ទណ្ឌកម្មទៅលើអ្នកដែលបានប្រព្រឹត្តការគំរាមគំហែង ការសម្លុត បំភ័យ និងអ្នកប្រើប្រាស់អំពើហិង្សាមកលើអ្នកសារព័ត៌មាន។
- ជួយសម្រួលដល់ការប្រើប្រាស់អ៊ីនធឺណេតសម្រាប់ប្រជាជនកម្ពុជាទាំងអស់ និងបង្កើតគោនយោបាយដើម្បីធានាថាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការចែកចាយធំនៃការប្រើប្រាស់អ៊ីនធឺណេតអាចត្រូវបានបង្កើតឡើងនៅក្នុងប្រទេស។
- ធានាថាច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ប្រសិនបើត្រូវបានអនុម័ត ជាដំបូងគឺទទួលយកនូវគំនិតរបស់សង្គមស៊ីវិលមកពិចារណា និងមិនមានបញ្ញត្តិ ឬពាក្យពេចន៍មិនច្បាស់លាស់ដែលអាចនឹងត្រូវប្រើដើម្បីបង្ក្រាបលើសិទ្ធិបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធឺណេតទេ។

- រដ្ឋាភិបាលត្រូវទទួលយកសេរីភាពព័ត៌មានដែលមានលើបណ្តាញសង្គមដោយការទាញយកប្រយោជន៍ពីលទ្ធភាពបណ្តាញសង្គមដែលមានដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពនៃសកម្មភាពរាជរដ្ឋាភិបាល និងការបោះពុម្ពផ្សាយជាផ្លូវការនៃព័ត៌មានលើបណ្តាញសង្គម។
- វិនិយោគលើការអប់រំយុវជនកម្ពុជាដែលជាទំពាំងស្នងឬស្សី ដើម្បីធានាថាសាកលវិទ្យាល័យជាកន្លែងដោះដូរព័ត៌មាន និងគំនិតដោយសេរីដែលអនុញ្ញាតអោយយុវជនអាចប្រមូលផ្តុំ និងបង្កើតគំនិតផ្ទាល់ខ្លួន។
- រដ្ឋាភិបាលត្រូវតែធានាថា ច្បាប់បាតុកម្មមិនត្រូវបានប្រើប្រាស់ដោយរបៀបរើសអើង ដើម្បីរារាំងដល់ក្រុមដែលមិនពេញចិត្តណាមួយពីការជួបប្រជុំដោយសន្តិវិធី ឬបញ្ចេញមតិយោបល់ដែល ផ្ទុយទៅនឹងទស្សនៈរបស់គណបក្សកាន់អំណាច។ ការជួបប្រជុំដោយសន្តិវិធី ដើម្បីបញ្ចេញមតិមិនយល់ស្របជាមួយនឹងបុគ្គលនានាស្ថិតក្នុងអំណាច មិនគួរត្រូវបានមើលឃើញជាស្វ័យប្រវត្តិថាជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិទេ។
- អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិត្រូវតែធានាថាសិទ្ធិមានសេរីភាពក្នុងការដើរហើរតាមរដ្ឋធម្មនុញ្ញត្រូវបានគោរព។ ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិធ្វើដំណើរទៅចូលរួមស្តាប់សវនាការ និងបាតុកម្មដោយសន្តិវិធី។

**<u>ប្រព័ន្ធផ្សព្វផ្សាយ</u>**

- ការប្តេជ្ញាចិត្តក្នុងបទប្បញ្ញត្តិឯករាជ្យនៃប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីដោយមិនមានការ លំអៀងទៅគណបក្សនាំមុខគេ និងធានាសិទ្ធិសេរីភាពក្នុងការប្រតិបត្តិការក្នុងគោលបំណង ដើម្បីនាំយកប្រព័ន្ធផ្សព្វផ្សាយពហុនិយម និងដើម្បីលើកកម្ពស់វិជ្ជាជីវៈ និងភាពមិនលំអៀងក្នុងចំណោមអ្នកសែត និងអ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។
- ធានាថាករណីនៃការឃាយីប្រឆាំងនឹងអ្នកកាសែត ត្រូវបានស៊ើបអង្កេតត្រឹមត្រូវហើយថាជនល្មើសត្រូវបាននាំយកមកកាត់ទោស។
- កន្លែងលក់ប្រព័ន្ធផ្សព្វផ្សាយគួរតែត្រូវបានអនុញ្ញាតអោយផ្សព្វផ្សាយព័ត៌មានសិទ្ធិសេរី និងយុត្តិធម៌នៅក្នុងពេលបោះឆ្នោត និងមិនគួរត្រូវបានដាក់កម្រិតនៅក្នុងការធ្វើរបាយការណ៍ស្តីពីសកម្មភាព ឬគំនិតរបស់គណបក្សនយោបាយណាមួយ។
- អ្នកកាសែតមិនត្រូវប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬដាក់ពន្ធនាគារសម្រាប់ការរាយការណ៍លើបញ្ហានយោបាយ។

- ការគំរាមកំហែងឃាឃី និងអំពើហិង្សាប្រឆាំងនឹងអ្នកសារព័ត៌មានគួរតែត្រូវបានស៊ើបអង្កេត និងការផ្តន្ទាទោស។
- ធានាថាច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាប្រសិនបើបានអនុម័តដំបូងត្រូវចំណាយពេលបញ្ចូលអង្គការសង្គមស៊ីវិលចូលទៅក្នុងគណនី និងទីពីរមិនមានបទប្បញ្ញត្តិណាមួយ ឬពាក្យមិនច្បាស់លាស់ដែលអាចត្រូវបានប្រើដើម្បីរារាំងសិទ្ធិនៃការបញ្ចេញមតិនៅលើបណ្តាញសង្គម។

**<u>សង្គមស៊ីវិល</u>**

- បង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យជាតិ ស្របតាមគោលការណ៍ទីក្រុងប៉ារីស ដើម្បីការពារតួនាទីនៃសង្គមស៊ីវិលដែលមានសិទ្ធិរបស់ពួកគេដើម្បីសេរីភាពខាងការបញ្ចេញមតិសមាគម និង/ឬ ការជួបប្រជុំគ្នារំលោភ។
- ផ្តល់ការអប់រំដល់អាជ្ញាធរដើម្បីធានាថា ពួកគេបានដឹងអំពីបទប្បញ្ញត្តិនៃច្បាប់បាតុកម្ម និងថាពួកគេនឹងមិនបន្តស្នើសុំលិខិតអនុញ្ញាតពីអង្គការសង្គមស៊ីវិល ដែលមិនចាំបាច់នៅក្រោមច្បាប់។
- ចូលរួមជាមួយអង្គការសង្គមស៊ីវិលតាមរយៈវេទិកាសាធារណៈសិក្ខាសាលា និងការប្រជុំនៅក្នុងគោលបំណងដើម្បីស្តាប់អំពីបញ្ហាប្រឈម និងដើម្បីធ្វើអោយកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនេះ។
- ធ្វើអោយការប្តេជ្ញាចិត្តដ៏រឹងមាំក្នុងការស៊ើមអង្កេតយ៉ាងហ្មត់ចត់អំពើហិង្សា ឬការបំភិតបំភ័យបានធ្វើឡើងប្រឆាំងនឹងភ្នាក់ងារសង្គមស៊ីវិល និងដើម្បីនាំជនល្មើសទៅកាត់ទោស។

# ឯកសារយោង

## ច្បាប់ជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/ ០៧០៤/ ០០១, ២១ កញ្ញា ១៩៩៣។

ច្បាប់ស្តីពីរបបសារព័ត៌មាន, នស/ រកម/ ០៨៩៥/ ០០៧/ ០១ កញ្ញា ១៩៩៥។

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, លេខ នស/ រកម/ ១២០៩/ ០១២, ០៥ ធ្នូ ២០០៩។

ច្បាប់ស្តីពីសេរីភាពក្នុងការរទទួលបានព័ត៌មាន (២០១២)។

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល, លេខ កបធ.ច/ ១៥៦/០០៤/២០១៥ / ១២ សីហា ២០១៥។

## ច្បាប់អន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តថ្ងៃទី១០ ធ្នូ ១៩៤៩)។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (អនុម័តនៅថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ មករា ១៩៧៦)។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តកាលពីថ្ងៃទី១៦ ធ្នូ ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃទី២៣ មីនា ១៩៧៦)។

## សៀវភៅ

ស្ពានទៅកាន់សន្តិភាពកម្ពុជា៖ សៀវភៅពលរដ្ឋវិជ្ជាៈ សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា (ឧសភា ២០១១)។

នួន សុធិមន្ត, វិទ្យាសាស្ត្រនយោបាយៈ គំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០)។
សៀវភៅនីតិសិទ្ធិមនុស្ស រៀបរៀងដោយសាស្ត្រាចារ្យៈ ឆឹង ស៊ីនាង ទំព័រ ១០០។

ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (ភ្នំពេញៈ សុខលាភបោះពុម្ព, (២០០៨)។

កម្រងទស្សនសង្គម និងនយោបាយ ចងក្រងដោយសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ឆ្នាំ ២០១៦។

## របាយការណ៍ និងការបោះពុម្ព

Ben Kiernan, The Pol Pot regime: race power, and genocide in Cambodia under the Khmer Rouge [របបប៉ុល ពតៈ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានៅក្រោមរបបខ្មែរក្រហម] (២០០៨), ៥៤៤។

Baron de Montesquieu៖ A short Biography:

https://www.rjgeib.com/thoughts/montesquieu/montesquieu-bio.html .

Encyclopedia Britannica: https://www.britannica.com/biography/Mary-Wollstonecraft .

Cambonomist, https://cambonomist.com/news/govt-approved-voc-khmer-office-registration/ .

ការរិះគន់លើបញ្ហាព្រំដែន កែសម្រួលដោយ ហួន ឌីណា៖ https://www.khmertimeskh.com .

https://vodkhmer.news/2019/11/25/local-radios-welcome-the-return-of-u-s-funded-radios/ .

សេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិល «អង្គការសង្គមស៊ីវិលសូមអំពាវនាវអោយច្រានចោលនូវសេចក្តីព្រាងវិសោធកម្មលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ» ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ http://www.licadho-cambodia.org/preerelease.php?perm=431 .

ការវិភាគរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លើសេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (លើកទី៥ ខែមិថុនា ឆ្នាំ២០១៥)។

អ្នកជំនាញអង្គការសហប្រជាជាតិលើកឡើងថា វិសោធកម្មរដ្ឋធម្មនុញ្ញនៅកម្ពុជាប៉ះពាល់ដល់លិទ្ធិប្រជាធិបតេយ្យ ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ https://www.ohchr.org/EN/NewEvets/DisplayNews.aspx?NewsID=22674&LangID=E .

របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន ដែលអនុវត្តរួមគ្នាដោយ ម.ស.ម.ក សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ https://cchrcambodia.org/admin/media/report/report/english/FFMP_Second%20Annual%Report_EN.pdf .

សេរីភាពខាងការជួបប្រជុំ៖ https://cchrcambodia.org/index_old.php?url=our_work/our_work.php&id=3&lang=khm .

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ កំណត់ត្រាសង្ខេបសេរីភាពបញ្ចេញមតិ និងការគាបសង្កត់លើបណ្ដាយអ៊ីនធឺណេតនៅកម្ពុជា (ខែមេសា ឆ្នាំ២០១៣)៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.htm .

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ កំណត់ត្រាសង្ខេបសេរីភាពបញ្ចេញមតិ និងការគាបសង្កត់លើបណ្ដាយអ៊ីនធឺណេតនៅកម្ពុជា (ខែមេសា ឆ្នាំ២០១៣)៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.htm .

កំណត់ត្រាសង្ខេបទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (កុម្ភៈ ២០១៦)។

កំណត់ត្រាសង្ខេបទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (កុម្ភៈ ២០១៦)។

ច្បាប់ថ្មីស្តីពីទូរគមនាគមន៍ប៉ះពាល់ដល់សិទ្ធិ និងសេរីភាពបុគ្គល (ចេញផ្សាយខែមិនា ឆ្នាំ២០១៦) ៖ https://www.licadho-cambodia.org/reports.php?perm=214&khmer.

ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជាកង្វល់ថ្មី៖ http://www.rfi.fr/km/cambodia-offense-crime-of-technology-is-new-matter-02-05-2014 .

អំណាចរដ្ឋ១២ចំណុច លើការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (ថ្ងៃទី១ មេសា ២០២០)៖ https://thmeythmey.com/?page=detail&id=90211 .

បទវិភាគច្បាប់សង្ខេបនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (នៅថ្ងៃទៅ៣១ មីនា ឆ្នាំ២០២០)។

សេចក្តីនៃច្បាប់ សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា ៖ (ឧសភា ២០១១) ទំព័រ ៨៨។

អត្ថបទ ៖ កម្ពុជាប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែករបស់បរទេស https://thmeythmey.com/?page=detail&id=69407 .

សេចក្តីថ្លែងការណ៍រួមស្តីពីផលប៉ះពាល់នៃច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងដំណើរធ្វើវិសោធនកម្ម (រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០) ៖ https://www.central-cambodia.org/km/archives/3473 .

អត្ថបទ៖ រដ្ឋសភាអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយសំឡេង១១៥៖ https://dap-news.com/national/2020/04/10/47597 .

# សេចក្ដីប្រកាសព័ត៌មាន និងអត្ថបទសារព័ត៌មាន

គេហទំព័រក្រសួងព័ត៌មាន សេចក្ដីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន http://a2i.gov.kh/។

វីអូអេ៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.html .

ខេមបូចា និង OPCC ថា សេរីភាពសារព័ត៌មានកម្ពុជាបន្តរឹតត្បិតក្រោមឥទ្ធិពលអ្នកមានអំណាច៖ https://vodkhmer.news/2020/05/03/cambodias-press-freedom-restricted-say-camboja-and-opcc/

អត្ថបទ៖ សេរីភាពសារព័ត៌នៅកម្ពុជា និងជុំវិញពិភពលោក៖ https://khmer.voanews.com/p/7013.html .

វីអូអេ៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.html .

ធីមីលើ 'ក្រសួងបដិសេធការបិទគេហទំព័រ' ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១)។

វីអូអេ៖ https://khmer.voanews.com/a/Cambodian-netizens-face-risk-as-government-tightens-online-control/4108472.html .

វីអូអេ (12 តុលា 2015)៖ https://khmer.voanews.com/a/media-experts-warn-against-a-cyber-crime-law-that-hurts-online-freedom/3002585.html .

វីអូឌី: https://vodkhmer.news/2020/05/04/how-govt-use-state-emergency-law/. (សូត សុខប្រាថ្នា, ០៤ ឧសភា ២០២០)។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| បទដ្ឋានគតិយុត្តិ |
|---|
| រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ |
| សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| ច្បាប់ស្តីពីរបបសារព័ត៌មាន |
| ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី |
| ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន |
| រូបភាពបញ្ចេញមតិ |

# កតិកាសញ្ញាអន្តរជាតិ

# ស្តីពី

# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# និងពិធីសារបន្ថែម

ខែមករា ឆ្នាំ២០០៩

# កតិកាសញ្ញាអន្តរជាតិ ស្ដីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងពិធីសារបន្ថែម

## សេចក្ដីផ្ដើម

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័ត កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ហើយកតិកាសញ្ញានេះបានចូលជាធរមានតាមច្បាប់អន្តរជាតិ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ។

នេះគឺជាកតិកាសញ្ញាមួយ នៃសន្ធិសញ្ញាអន្តរជាតិចំនួនពីរដែលរៀបរៀងឡើង ដើម្បីផ្ដល់អានុភាពតាមផ្លូវច្បាប់ ដល់ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ ។ ចេតនាដំបូង គឺព្រៀងសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយប៉ុណ្ណោះ ប៉ុន្តែការខ្វែងគំនិតនយោបាយនៅក្នុងសហគមន៍អន្តរជាតិ អាចដោះស្រាយបានដោយការព្រមព្រៀងគ្នា តាក់តែងសន្ធិសញ្ញាចំនួនពីរស្របគ្នា ។ អាស្រ័យហេតុនេះ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាកញ្ចក់ឆ្លុះគ្នាជាមួយនឹង កតិកាសញ្ញាអន្តរជាតិ ស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ឯកសារទាំងពីរនេះ តាក់តែងឡើងតាមទម្រង់ប្រហាក់ប្រហែលគ្នា និងមានបទប្បញ្ញត្តិរួមគ្នាជាច្រើន ។ ដោយរួមបញ្ចូលគ្នាជាមួយសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាទាំងពីនេះតែងតែចាត់ទុកជា“ធម្មនុញ្ញអន្តរជាតិស្ដីពីសិទ្ធិមនុស្ស”។

ដោយមិនគិតដល់ការបែងចែកសិទ្ធិមនុស្សជាពីរកតិកាសញ្ញាផ្សេងគ្នា និងការអនុម័តជាបន្តបន្ទាប់នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដែលគ្របដណ្ដប់លើបញ្ហាផ្សេងៗគ្នាជាច្រើន អង្គការសហប្រជាជាតិបានគូសបញ្ជាក់ជាប្រចាំពីសកលភាព ការទាក់ទងគ្នាទៅវិញទៅមក និងភាពពំនាក់អាស្រ័យគ្នានៃសិទ្ធិមនុស្សទាំងអស់ ។ និយាយម្យ៉ាងទៀត សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនសំខាន់ជាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏មិនសំខាន់ជាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ ។ មនុស្សទាំងអស់មានសិទ្ធិទទួលបានសិទ្ធិមនុស្សស្មើៗគ្នា ។

## ផ្នែកទី ៣

### មាត្រា ៦

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិធ្វើការងារ រួមមានសិទ្ធិរបស់មនុស្សគ្រប់រូប មានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬព្រមទទួលយកដោយសេរី និងចាត់វិធានការសមស្រប ដើម្បីការពារសិទ្ធិនេះ ។

២. វិធានការដែលរដ្ឋភាគីនៃកតិកាសញ្ញានេះប្រកាន់យក ដើម្បីធានាការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ ត្រូវរួមបញ្ចូល ការតម្រង់ទិសខាងបច្ចេកទេស និងវិជ្ជាជីវៈ និងកម្មវិធីបណ្តុះបណ្តាលគោលនយោបាយ និងបច្ចេកទេស ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ថេរ ខាងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការងារពេញលេញដែលមានផលប្រយោជន៍ក្នុងលក្ខខណ្ឌការពារ សេរីភាពជាមូលដ្ឋានខាងនយោបាយ និងសេដ្ឋកិច្ចចំពោះបុគ្គលគ្រប់រូប ។

### មាត្រា ៧

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ដើម្បីទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផល ដែលធានាជាពិសេសនូវ :

(ក) ប្រាក់កម្រៃដែលផ្តល់ជាអប្បបរមាឱ្យអ្នកធ្វើការ នូវ:

១. បៀវត្សរ៍ប្រកបដោយសមធម៌ និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា ដោយមិនមានការបែងចែកណាមួយ ជាពិសេស ស្ត្រីត្រូវតែមានការធានានូវលក្ខខណ្ឌការងារដែលផ្តល់ឱ្យពួកគេ មិនតិចជាងលក្ខខណ្ឌដែលបុរសបានទទួល ដោយត្រូវបានប្រាក់កម្រៃស្មើគ្នា ចំពោះការងារដូចគ្នា ។

២. ជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងគ្រួសារ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

(ខ) លក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ ។

(គ) ឱកាសដូចគ្នាសម្រាប់បុគ្គលគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារ ទៅកម្រិតខ្ពស់សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងពីអតីតភាពការងារ និងសមត្ថភាព ។

## មាត្រា ៨

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាឱ្យបាននូវ :

(ក) សិទ្ធិសម្រាប់ជនគ្រប់រូប បង្កើតសហជីព និងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួន ដោយស្ថិតក្រោមវិធានទាំងឡាយដែលកំណត់ដោយអង្គការពាក់ព័ន្ធ ដើម្បីលើកស្ទួយ និងការពារផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន ។ ការប្រើប្រាស់សិទ្ធិនេះ មិនអាចរឹតត្បិតបានទេ លើកលែងតែការរឹតត្បិតនោះ មានចែងនៅក្នុងច្បាប់ និងជាវិធានការចាំបាច់ ក្នុងសង្គមប្រជាធិបតេយ្យ ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

(ខ) សិទ្ធិរបស់សហជីពបង្កើតសហព័ន្ធ ឬសម្ព័ន្ធជាតិ និងសិទ្ធិរបស់សហព័ន្ធ និងសម្ព័ន្ធជាតិ បង្កើត ឬចូលរួមក្នុងអង្គការសហជីពអន្តរជាតិ ។

(គ) សិទ្ធិរបស់សហជីព ធ្វើសកម្មភាពដោយសេរី ដោយគ្មានកម្រិតព្រំដែន លើកលែងតែ កម្រិតព្រំដែននោះមានចែងក្នុងច្បាប់ និងជាវិធានការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ សម្រាប់ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

(ឃ) សិទ្ធិធ្វើកូដកម្មដែលត្រូវប្រើប្រាស់ឱ្យស្របតាមច្បាប់របស់ប្រទេសនីមួយៗ ។

២. មាត្រានេះ មិនរារាំងដល់ការដាក់ការរឹតត្បិតស្របច្បាប់ លើការប្រើប្រាស់សិទ្ធិទាំងនេះ ដោយសមាជិកកងកម្លាំងប្រដាប់អាវុធ ឬនគរបាល ឬមុខងារសាធារណៈឡើយ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីទាំងអស់នៃអនុសញ្ញាឆ្នាំ១៩៤៨ នៃអង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិសហជីព ចាត់វិធានការខាងផ្លូវច្បាប់ដែលប៉ះពាល់ ឬអនុវត្តច្បាប់ តាមបែបដែលធ្វើឱ្យប៉ះពាល់ដល់ការធានាទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញានោះ ។

### មាត្រា ៩

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមផង ។

### មាត្រា ១០

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា :

១. កិច្ចគាំពារនិងជំនួយដ៏ទូលំទូលាយបំផុតដែលអាចធ្វើទៅបានត្រូវតែផ្តល់ឱ្យគ្រួសារ ដែលជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ជាពិសេសសម្រាប់ការកសាងគ្រួសារ និងនៅពេលដែលគ្រួសារមានការទទួលខុសត្រូវចំពោះការថែរក្សា និងការអប់រំបុត្រធីតាក្នុងបន្ទុក ។ អាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយមានការយល់ព្រមដោយសេរីពីអនាគតប្តី-ប្រពន្ធ ។

២. កិច្ចគាំពារពិសេសមួយ ត្រូវផ្តល់ឱ្យម្តាយទាំងឡាយ សម្រាប់រយៈពេលសមរម្យមួយ នៅមុន និងក្រោយពេលសម្រាលកូន ។ ក្នុងរយៈពេលនេះ ម្តាយជានិយោជិក ត្រូវបានទទួលនូវការសម្រាកមានប្រាក់ខែ ឬការសម្រាកដែលមានការផ្តល់សន្តិសុខសង្គមគ្រប់គ្រាន់ ។

៣. វិធានការការពារ និងជំនួយពិសេស ត្រូវធ្វើឡើងជាគុណប្រយោជន៍ដល់កុមារ និងយុវជនទាំងអស់ ដោយគ្មានការរើសអើងណាមួយ ដោយមូលហេតុខ្សែលោហិត ឬលក្ខខណ្ឌអ្វីផ្សេងទៀតឡើយ ។ កុមារ និងយុវជនទាំងអស់ ត្រូវទទួលបាននូវការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការជួលកុមារ និងយុវជនឱ្យធ្វើការ ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌ ឬសុខភាពរបស់ពួកគេ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ឬដែលអាចធ្វើឱ្យខូចដល់ការលូតលាស់ធម្មតារបស់ពួកគេ ត្រូវផ្តន្ទាទោសតាមច្បាប់ ។ រដ្ឋត្រូវកំណត់អាយុជួលឱ្យធ្វើការងារ ហើយការជួលកុមារឱ្យធ្វើការងារក្រោមអាយុកំណត់នេះ ត្រូវហាមឃាត់ និងផ្តន្ទាទោសតាមច្បាប់ ។

## មាត្រា ១១

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបាន កម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សំលៀក បំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសម្រេចបាននូវសិទ្ធិនេះ និងទទួលស្គាល់ សារៈសំខាន់ចាំបាច់នៃសហប្រតិបត្តិការអន្តរជាតិ តាមការយល់ព្រមគ្នាដោយសេរី ។

២. ដោយទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប រួចចាកផុតពីសេចក្តីស្រេក ឃ្លាន រដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយខ្លួនឯង និងតាមរយៈកិច្ចសហការអន្តរជាតិ ត្រូវចាត់ វិធានការ រួមមានកម្មវិធីពិសេសៗជាក់លាក់ ដែលចាំបាច់ដូចតទៅ :

(ក) ដើម្បីធ្វើឱ្យប្រសើរវិធីនៃការផលិត ការរក្សាទុក និងការចែកចាយម្ហូប អាហារ ដោយការប្រើប្រាស់ពេញលេញនូវចំណេះដឹងខាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដោយ ការផ្សព្វផ្សាយគោលការណ៍នៃការអប់រំស្តីពីអាហារូបត្ថម្ភ និងដោយការអភិវឌ្ឍន៍ ឬការកែ ទម្រង់របបដីធ្លី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកប ដោយប្រសិទ្ធភាពខ្ពស់បំផុត ។

(ខ) ដើម្បីធានាការបែងចែកដោយសមធម៌ នូវធនធានស្បៀងអាហារពិភពលោក ទៅតាមសេចក្តីត្រូវការ ដោយគិតទៅដល់បញ្ហាទាំងឡាយដែលចោទឡើងចំពោះប្រទេសនាំ ចូល ក៏ដូចជាប្រទេសនាំចេញស្បៀងអាហារ ។

## មាត្រា ១២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប មានកម្រិត សុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ។

២. វិធានការនានា ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះចាត់ ដើម្បីធានាការប្រើសិទ្ធិ នេះឱ្យបានពេញលេញ ត្រូវរាប់បញ្ចូលនូវវិធានការដែលចាំបាច់ដើម្បីធានា :

(ក) វិធានការសម្រាប់ការកាត់បន្ថយអត្រាមរណៈ នៃទារកក្នុងពោះម្តាយ និងមរណៈនៃកុមារ និងសម្រាប់ការរីកលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ ។

(ខ) ការធ្វើឱ្យប្រសើរគ្រប់ទិដ្ឋភាពនៃអនាម័យខាងផ្នែកបរិស្ថាន និងឧស្សាហកម្ម។

(គ) វិធីបង្ការ ការព្យាបាល និងការត្រួតពិនិត្យជំងឺឆ្លង ជំងឺរាតត្បាត ជំងឺបណ្តាលមកពីវិជ្ជាជីវៈ និងជំងឺដទៃទៀត ព្រមទាំងប្រយុទ្ធប្រឆាំងនឹងជំងឺទាំងនេះផង ។

(ឃ) ការបង្កើតលក្ខខណ្ឌសម្រាប់ធានាដល់ជនគ្រប់រូប នូវសេវាសុខាភិបាលគ្រប់ផ្នែក និងជំនួយផ្នែកសុខាភិបាលក្នុងពេលមានជំងឺ ។

## មាត្រា ១៣

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូប ដើម្បីទទួលបានការអប់រំ ។ រដ្ឋភាគី ព្រមព្រៀងគ្នាថា ការអប់រំត្រូវនាំឆ្ពោះទៅរកការរីកចម្រើនពេញលេញ នៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងអត្ថន័យនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស និងពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។ រដ្ឋភាគី ព្រមព្រៀងគ្នាបន្ថែមទៀតថា ការអប់រំត្រូវធ្វើឱ្យមនុស្សគ្រប់រូប អាចដើរតួនាទីមានប្រយោជន៍ក្នុងសង្គមសេរី លើកស្ទួយការយោគយល់ ការអត់ឱន និងមិត្តភាពរវាងប្រជាជាតិ និងរវាងក្រុមពូជសាសន៍ ក្រុមជាតិពន្ធុ ឬក្រុមសាសនាទាំងអស់ ព្រមទាំងជ្រោមជ្រែងសកម្មភាពរបស់អង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិភាព ។

២. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ :

(ក) ការអប់រំកម្រិតបឋមសិក្សា ត្រូវតែជាកាតព្វកិច្ច ហើយឥតបង់ថ្លៃ សម្រាប់ទាំងអស់គ្នា ។

(ខ) ការអប់រំកម្រិតមធ្យមសិក្សា តាមទម្រង់ទ្រាយផ្សេងៗ រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យម ត្រូវតែបើកឱ្យមានជាទូទៅ និងឱ្យមនុស្សគ្រប់គ្នា អាចចូលរៀនបាន តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់ នូវការសិក្សាដោយឥតបង់ថ្លៃ ។

(គ) ការអប់រំកម្រិតឧត្តមសិក្សា ត្រូវតែបើកចំហដល់មនុស្សគ្រប់រូបដោយស្មើភាព តាមសមត្ថភាពរបស់មនុស្សម្នាក់ៗ តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ ។

(ឃ) ការអប់រំមូលដ្ឋាន ត្រូវតែជំរុញ ឬពង្រឹង តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន សម្រាប់អ្នកដែលមិនបានទទួល ឬមិនបានបញ្ចប់កម្រិតបឋមសិក្សារបស់ខ្លួន ។

(ង) ត្រូវតែបន្តយ៉ាងសកម្មលើការអភិវឌ្ឍន៍បណ្ដាញសិក្សាធិការគ្រប់លំដាប់ បង្កើតប្រព័ន្ធអាហារូបករណ៍ឱ្យបានគ្រប់គ្រាន់ និងបង្កើនជាលំដាប់នូវលក្ខខណ្ឌសម្ភារៈ របស់បុគ្គលិកសិក្សា ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់មាតាបិតា និងអាណាព្យាបាលស្របច្បាប់បើសមស្រប ដើម្បីជ្រើសរើសសាលារៀនក្រៅពីសាលារៀនសាធារណៈឱ្យកូនរបស់ខ្លួន ប៉ុន្តែត្រូវស្របតាមវិធានអប្បបរមាដែលរដ្ឋអាចកំណត់ ឬអនុម័តក្នុងវិស័យអប់រំ និងរ៉ាប់រងការអប់រំ សាសនា និងសីលធម៌របស់កូន ស្របតាមជំនឿផ្ទាល់របស់ពួកគេ ។

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវយកមកបកស្រាយ ថាប៉ះពាល់ដល់សេរីភាពនៃរូបវ័ន្តបុគ្គល និងនីតិបុគ្គល ក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សា លើកលែងតែគោលការណ៍ដែលបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ត្រូវបានគោរព និងឱ្យតែការអប់រំដែលផ្ដល់ឱ្យនៅក្នុងគ្រឹះស្ថានទាំងនោះ ស្របទៅនឹងបទដ្ឋានអប្បបរមាដែលអាចកំណត់ដោយរដ្ឋ ។

## មាត្រា ១៤

នៅពេលក្លាយជាភាគីនៃកតិកាសញ្ញានេះ រដ្ឋភាគី ដែលមិនទាន់អាចធានាការអប់រំកម្រិតបឋម ជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ នៅក្នុងដែនដីចំណុះនៃប្រទេសខ្លួន ឬដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន សន្យាបង្កើត និងអនុម័ត ក្នុងរយៈពេល២ឆ្នាំ នូវផែនការលំអិតនៃវិធានការចាំបាច់ ដើម្បីធ្វើឱ្យបានសម្រេចជាលំដាប់តាមចំនួនឆ្នាំសមរម្យដែលកំណត់ក្នុងផែនការនេះនូវការអនុវត្តន៍ពេញលេញនៃគោលការណ៍អប់រំកម្រិតបឋមជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃសម្រាប់ទាំងអស់គ្នា ។

## មាត្រា ១៥

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិនៃបុគ្គលគ្រប់រូប ដើម្បី :

(ក) ចូលរួមក្នុងជីវភាពវប្បធម៌ ។

(ខ) ទទួលអត្ថប្រយោជន៍ពីវឌ្ឍនភាព និងការអនុវត្តន៍វិទ្យាសាស្ត្រ ។

(គ) ទទួលអត្ថប្រយោជន៍ ពីការការពារផលប្រយោជន៍ខាងសីលធម៌ និងខាងសម្ភារៈ ដែលកើតពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈដែលខ្លួនជាអ្នកបង្កើត ។

២. វិធានការ ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះ ប្រកាន់យក ដើម្បីធានាដល់ការប្រើប្រាស់ពេញលេញនូវសិទ្ធនេះ ត្រូវរួមបញ្ចូលវិធានការចាំបាច់សម្រាប់ធានាដល់ការថែរក្សា ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយខាងវិទ្យាសាស្ត្រ និងវប្បធម៌ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពដែលមិនអាចខ្វះបានសម្រាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងសកម្មភាពប្រឌិតញាណ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់អត្ថប្រយោជន៍ដែលបានមកពីការលើកទឹកចិត្ត និងការអភិវឌ្ឍន៍នៃសហប្រតិបត្តិការ និងការទាក់ទងជាអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌ ។

## ផ្នែកទី ៤

## មាត្រា ១៦

១. ដោយអនុលោមទៅតាមបទបញ្ញត្តិនានានៃផ្នែកនេះនៃកតិកាសញ្ញានេះ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាដាក់ជូននូវរបាយការណ៍ស្ដីពីវិធានការដែលខ្លួនបានអនុម័ត និងស្ដីពីការរីកចម្រើនដែលសម្រេចបាន ដើម្បីធានាការគោរពសិទ្ធិ ដែលត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

២.(ក) របាយការណ៍ទាំងអស់ ត្រូវដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះ ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីពិនិត្យ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



# ជំពូកទី ១

## អំពីអធិបតេយ្យ

**មាត្រា ១.-**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

**មាត្រា ២.-**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣-១៩៦៩ ។

# ជំពូកទី ២
# អំពីព្រះមហាក្សត្រ

**មាត្រា ៧.‐**

ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។



**មាត្រា ៨.‐**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និង ការគោរពសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩.‐**

ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

**មាត្រា ១០.‐**

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។ ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជ្យសម្បត្តិឡើយ ។

## ជំពូកទី ៣
## អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.‐**

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.‐**

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិត មិនត្រូវឱ្យមានឡើយ ។



**មាត្រា ៣៣.‐**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។



**មាត្រា ៣៧.–**

សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.–**

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារ ជីវិត កិត្តិយស និង សេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

តុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។



**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណង ជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និង សំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយ ជិត និង តាំងទីលំនៅក្នុងស្ថានភាពស្រប ច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព ។ ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅ ឬ វិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និង តាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈ វត្ថុ និង លើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់

សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និង សណ្តាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។



ដែលនឹងដកហូតកម្មសិទ្ធិ អំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និង យុត្តិធម៌ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



២០១០

ក្រសួងយុត្តិធម៌

Ministère de la Justice

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបរិហារកេរ្តិ៍ និងការជេរប្រមាថ

**មាត្រា ៣០៥.-** បទបរិហារកេរ្តិ៍ជាសាធារណៈ

គ្រប់ការអះអាងបំផ្លើស ឬ ការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ កិត្តិស័ព្ទនៃបុគ្គល ឬ នៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ :

១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ ។

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៦.-** អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន

ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៧.-** បទជេរប្រមាថជាសាធារណៈ

[illegible]ប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬ គ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់[illegible]ស[illegible]លើអំពើណាមួយ គឺជាការជេរប្រមាថ ។

បុគ្គលនោះ ។ ក្នុងករណីនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា ៣១០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

## ផ្នែកទី ៣
## ការប្តឹងបរិហារបង្កាច់កេរ្តិ៍

**មាត្រា ៣១១.-** បទប្តឹងបរិហារបង្កាច់កេរ្តិ៍

ការប្តឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្តឹងបរិហារអំពីអំពើដែលគេដឹងថា មិនពិត ហើយដែលនាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬ វិន័យ កាលបើការប្តឹងបរិហារនេះ ត្រូវបានផ្ញើទៅដល់ :

-អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការ ដូចជាចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក ឬ

-បុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣១២.-** ទោសដែលត្រូវអនុវត្ត និងលក្ខខណ្ឌនៃការចោទប្រកាន់

ការប្តឹងបរិហារបង្កាច់កេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បណ្តឹងអាជ្ញានៃបទល្មើសនេះ ផុតអាជ្ញាយុកាលក្នុងរយៈពេល ១ (មួយ) ឆ្នាំ ។ ចំណុចចាប់ផ្តើមនៃអាជ្ញាយុកាលនេះ ត្រូវចាប់គិតពីថ្ងៃដែលបណ្តឹងបរិហារបង្កាច់កេរ្តិ៍ត្រូវបានផ្តល់ ឬ ថ្ងៃដែលពាក្យប្តឹងបានដាក់មកអាជ្ញាធរមានសមត្ថកិច្ច ។

៧-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការគំរាមកំហែងថានឹងធ្វើការបំផ្លិចបំផ្លាញ ធ្វើឱ្យខ្ទេចខ្ទាំ ឬ ធ្វើឱ្យខូចខាត

**មាត្រា ៤២៣.-** បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត

អំពើគំរាមកំហែងថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឱ្យខ្ទេចខ្ទាំ ឬ ការធ្វើឱ្យខូចខាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ប្រសិនបើការគំរាមកំហែងនេះបានធ្វើម្តងហើយម្តងទៀត ឬ ដោយបានសម្តែងចេញតាមលិខិត តាមរូបភាព ឬ វត្ថុដទៃទៀត ។

[redacted]



នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

**មាត្រា ៤២៧.–** បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ

អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដោយទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



Kol

[redacted]

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៤៩៣.-** ការរឹបអូសក្នុងករណីមានការបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៤៩១ (បទបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ) នៃក្រមនេះ តុលាការអាចប្រកាសរឹបអូសអាវុធ ឬវត្ថុដែលអាចនាំឱ្យមានគ្រោះថ្នាក់ចំពោះបុគ្គល ។

## ផ្នែកទី ៣

## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

**មាត្រា ៤៩៤.-** លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត :

១-ដោយសម្តីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬ នៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬ គំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយ នៅក្នុងចំណោមសាធារណជន ឬ តាំងឱ្យសាធារណជនមើល ។

៣-ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៤៩៥.-** បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ ប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤

## ការប៉ះពាល់ដល់អាជ្ញាធររបស់រដ្ឋ

### ផ្នែកទោល

### ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ

**មាត្រា ៥០២.-** បទប្រមាថ

ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល ។

ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬ ចំពោះពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥០៣.-** បទប្រឆាំងនឹងអ្នករាជការសាធារណៈ

ការប្រឆាំងនឹងអ្នករាជការសាធារណៈ គឺជាអំពើប្រឆាំងដោយប្រើការតទល់ដោយហិង្សា នឹងអ្នករាជការសាធារណៈដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជារបស់អាជ្ញាធរសាធារណៈ ឬ សេចក្តីសម្រេចរបស់តុលាការ ។

បទប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ២ (ពីរ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំ



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
20/04/12 ksl

សែន) រៀល ។

**មាត្រា ៥០៤.-** ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ

ការប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល នៅក្នុងករណីដូចតទៅ :

១-ការប្រឆាំងនឹងអ្នករាជការសាធារណៈ បានប្រព្រឹត្តដោយបុគ្គលច្រើនរូប ធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

២-ចារីមានអាវុធ ។

**មាត្រា ៥០៥.-** បទញុះញង់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ

ការញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ១(មួយ) ខែ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥០៦.-** បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ

អំពើប្រឆាំងដោយហិង្សាទៅលើការអនុវត្តការងារសាធារណៈ ឬ ការងារដែលមានប្រយោជន៍ជាសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥០៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍

សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥

## ការប៉ះពាល់ដល់សាសនារបស់រដ្ឋ

### ផ្នែកទី ១

### បទល្មើសប៉ះពាល់ដល់ព្រះពុទ្ធសាសនា

**មាត្រា ៥០៨.–** បទស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ថ្ងៃ ទៅ ៣(បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល អំពើស្លៀកដណ្តប់ជាសាធារណៈ ដោយគ្មានសិទ្ធិនឹងស្លៀកដណ្តប់នូវស្បង់ ចីពរ សម្រាប់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

**មាត្រា ៥០៩.–** បទលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ ការលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តនៅក្នុងបូជនីយដ្ឋានសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១០.–** បទធ្វើឱ្យខូចខាតដល់បូជនីយដ្ឋានសាសនា ឬ បូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ អំពើដែលប្រព្រឹត្តដោយចេតនាបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតបូជនីយដ្ឋានដែលបូជាចំពោះព្រះពុទ្ធសាសនា ឬ បូជនីយវត្ថុក្នុងសាសនានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១១.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសពេញលេញដែរ ។

[redacted]



សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥
## ការប៉ះពាល់ដល់សាសនារបស់រដ្ឋ
## ផ្នែកទី ១
## បទល្មើសប៉ះពាល់ដល់ព្រះពុទ្ធសាសនា

**មាត្រា ៥០៨.–** បទស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ថ្ងៃ ទៅ ៣(បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល អំពើស្លៀកដណ្តប់ជាសាធារណៈ ដោយគ្មានសិទ្ធិនឹងស្លៀកដណ្តប់នូវស្បង់ ចីពរ សម្រាប់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

**មាត្រា ៥០៩.–** បទលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ ការលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តនៅក្នុងបូជនីយដ្ឋានសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១០.–** បទធ្វើឱ្យខូចខាតដល់បូជនីយដ្ឋានសាសនា ឬ បូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ អំពើដែលប្រព្រឹត្តដោយចេតនាបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតបូជនីយដ្ឋានដែលបូជាចំពោះព្រះពុទ្ធសាសនា ឬ បូជនីយវត្ថុក្នុងសាសនានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១១.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមនោះដែរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង



[redacted]

១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ២
## ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ

**មាត្រា ៥២០.-** បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

អំពើរបស់អ្នករាជការសាធារណៈ ក្នុងមុខការរបស់ខ្លួន ដែលមិនព្រមអនុវត្តសាលដីកា សាលក្រម ដីកា ឬរាល់បញ្ជារបស់អាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥២១.-** បទផ្តល់ដោយខុសច្បាប់នូវបញ្ជាឱ្យឃុំ ឬដោះលែង

អំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទោះបីក្រោមរូបភាពណាក៏ដោយ ចេញបញ្ជាដោយខុសច្បាប់ឱ្យឃុំ ឬឱ្យដោះលែងជនជាប់ឃុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល ។

**មាត្រា ៥២២.-** បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដោយ[illegible]ដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលទៅ

[redacted]



លើសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥២៣.–** បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ

អំពើរិះគន់លិខិត ឬ សេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

**មាត្រា ៥២៤.–** បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ

អំពើដែលប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាលនូវអំពើជាបទល្មើស កាលបើការប្តឹងបរិហារនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥២៥.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៥២០ (បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ) ដល់មាត្រា ៥២៤ (បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៥២៦.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាង

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត



[redacted]

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ

### ផ្នែកទី ១

### ការប្ដឹងទៅតុលាការ

**មាត្រា ៥២៧.-** បទសម្លុតកុំឱ្យដាក់ពាក្យបណ្ដឹង

អំពើគំរាមកំហែងសម្លុត ដើម្បីបង្ខំជនរងគ្រោះ កុំឱ្យដាក់ពាក្យបណ្ដឹង ឬ ដកពាក្យបណ្ដឹងរបស់ខ្លួន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះ សម្ដែងចេញជាលទ្ធផល ។

**មាត្រា ៥២៨.-** បទមិនប្ដឹងហិរហារបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍ [illegible]ពីរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះ- [illegible] ដែលមិនបានប្ដឹងហិរហារដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ
### ផ្នែកទី ១
### ការរារាំងទៅតុលាការ

**មាត្រា ៥២៧.-** បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង

អំពើគំរាមកំហែងសម្លុត ដើម្បីបង្ខំជនរងគ្រោះ កុំឱ្យដាក់ពាក្យបណ្តឹង ឬ ដកពាក្យបណ្តឹងរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះ សម្តែងចេញជាលទ្ធផល ។

**មាត្រា ៥២៨.-** បទមិនប្តឹងហិហារបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍ ...ទីរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះ- ... ដែលមិនបានប្តឹងហិហារដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ

### ផ្នែកទី ១

### ការរារាំងនៅតុលាការ

**មាត្រា ៥២៧.-** បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង

អំពើគំរាមកំហែងសម្លុត ដើម្បីបញ្ចុះបញ្ចូលជនរងគ្រោះ កុំឱ្យដាក់ពាក្យបណ្តឹង ឬ ដកពាក្យបណ្តឹងរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះ សម្តែងចេញជាលទ្ធផល ។

**មាត្រា ៥២៨.-** បទមិនប្តឹងហេតុការណ៍បទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ... ពីរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះ-... ដែលមិនបានប្តឹងហេតុការណ៍ដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត

# ច្បាប់

## ស្ដីពី

# របបសារព័ត៌មាន

# ច្បាប់
## ស្តីពី
# របបសារព័ត៌មាន

## ជំពូកទី ១
## សិទ្ធិនិងសេរីភាពខាងសារព័ត៌មាន

មាត្រា ១.-

ច្បាប់នេះកំណត់របបសារព័ត៌មាននិងធានាការពារសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

សារព័ត៌មានមានសិទ្ធិរក្សាការសម្ងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន ។

មាត្រា ៣.

ដើម្បីរក្សាឯករាជ្យនៃសារព័ត៌មាន ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយត្រូវហាមឃាត់ ។

មាត្រា ៤.-

ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត ។

ព័ត៌មានផ្លូវការដែលជាកម្មវត្ថុនៃមាត្រានេះសំដៅចំពោះ ៖

១- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍របស់រដ្ឋសភារួបទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាផង លើកលែងតែក្នុងករណីរដ្ឋសភាធ្វើការប្រជុំសម្ងាត់ដូចមានចែងក្នុងមាត្រា ៨៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍នៃផ្នែកនីតិប្រតិបត្តិរួមទាំងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី និងមន្ត្រីនានាផង ។

៣- គ្រប់សម្ភិទ្ធភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែក្នុងករណី ដូចខាងក្រោមនេះ ៖

- តុលាការហាមមិនឲ្យបើកចំហដល់សាធារណជន
- បញ្ញត្តិដោយមាត្រា ១៦ នៃច្បាប់នេះដែលទាក់ទងទៅនឹងរាជកំបាំងរបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជំរះក្តី
- សំណុំរឿងដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ ។

មាត្រា ៥.-

១- គោលការណ៍ទូទៅ

សារពត៌មាន មានសិទ្ធិទទួលពត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែពត៌មានណាដែលបណ្តាលឲ្យ ៖

- អន្តរាយដល់សន្តិសុខជាតិ
- អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ
- មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយរាប់ទាំងសំណុំរឿងរបស់មន្ត្រីរាជការ សំណុំរឿងពេទ្យ សំណុំរឿង និងឯកសារផ្លូវការសម្ងាត់ៗដទៃទៀតជាដើម
- មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ ដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវតាមច្បាប់ណាមួយ និងការលាតត្រដាងនូវពត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ជា ឬការត្រួតពិនិត្យរបស់ស្ថាប័នហិរញ្ញវត្ថុ
- ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំឲ្យមានជំនុំជំរះក្តីដោយអយុត្តិធម៌
- មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ ឬត្រូវបំពេញបេសកកម្មរបស់ខ្លួន ។

២- ការស្នើសុំពត៌មាន

ការស្នើសុំពត៌មានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីពត៌មានដែលស្នើសុំទៅស្ថាប័ននានា ។

មន្ត្រីមានសមត្ថកិច្ចដែលគ្រប់គ្រងស្ថាប័ននោះ ត្រូវឆ្លើយតបទៅនឹងពាក្យសុំក្នុងរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) យ៉ាងយូរ ។ ប្រសិនបើការស្នើសុំនោះ ត្រូវបានបដិសេធទាំងស្រុង ឬខ្លះៗនោះ ហេតុផលនៃការបដិសេធត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

## ជំពូកទី ២
## ការទទួលខុសត្រូវនៃអ្នកសារពត៌មាន

មាត្រា ៦.-

អ្នកសារពត៌មានមានសិទ្ធិបង្កើតសមាគមអ្នកសារពត៌មាន ។ សមាគមអ្នកសារពត៌មាននោះត្រូវមានលក្ខណៈឯករាជ្យ ។ សមាគមអ្នកសារពត៌មាននីមួយៗ ត្រូវអនុម័តលក្ខន្តិកៈរបស់ខ្លួនដែលមិនផ្ទុយនឹងច្បាប់ជាធរមានដោយមានការយល់ព្រមពីសមាជិកតាមការបោះឆ្នោត ។ អ្នកដឹកនាំសមាគមអ្នកសារពត៌មានដែលជាសមាជិកក្រុមអភិបាល ត្រូវបានការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ ។

មាត្រា ៧.-

សមាគមអ្នកសារពត៌មាននីមួយៗត្រូវតាក់តែងក្រមសីលធម៌ដើម្បីអនុវត្តក្នុងសមាគមរបស់ខ្លួនដែលអ្នកសារពត៌មានមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ជាអាទិ៍ដូចតទៅ ៖

១- គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន ។
២- ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឲ្យត្រឹមត្រូវ និងសមស្របតាមគតិយុត្តិធម៌ ។
៣- ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ ។ អ្នកសារពត៌មានមិនត្រូវបំបាត់ចោលនូវពត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ ។
៤- ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ ។
៥- ត្រូវធ្វើការកែតម្រូវនូវពត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឲ្យមានការយល់ច្រឡំ ។
៦- ត្រូវចៀសវាងការផ្សព្វផ្សាយពត៌មាន ដែលញុះញង់ឲ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត ។
៧- ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល ។
៨- ត្រូវគោរពឲ្យបានហ្មត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរ ក្នុងការសរសេរអត្ថបទ ។
៩- ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា ។
១០- ហាមរំលោភលើសិទ្ធិ ដើម្បីមានការជំនុំជំរះក្តី ដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២- ត្រូវចាត់ទុកចំណុចដូចខាងក្រោមនេះជាការរំលោភដ៏ធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ៖

- ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃមកដាក់ថាជារបស់ខ្លួន
- បន្លំឲ្យគេយល់ខុស ដូចជាការសរសេរបញ្ឆិតបញ្ឆៀងដើម្បីឲ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុម បក្សណាមួយ
- ការប្លន់បង្ខាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ
- ការទទួលសំណូកក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយនូវព័ត៌មានណាមួយ ។

មាត្រា ៨.-

មុនពេលចាប់ផ្តើមចែកចាយសារព័ត៌មាន និយោជក ឬនិពន្ធនាយក ត្រូវធ្វើពាក្យមួយច្បាប់ (០១ច្បាប់) ជូនមកក្រសួងព័ត៌មានដើម្បីបញ្ជាក់រំពឹងអត្តសញ្ញាណរបស់ខ្លួន ។ ក្រសួងនេះត្រូវចេញបង្កាន់ដៃឲ្យទៅសារព័ត៌មានពេលបានទទួលសំណុំបែបបទទាំងមូល ។

ក្នុងករណីដែលនាយកការផ្សាយជាសមាជិករដ្ឋសភា ឬស្ថាប័នដែលមានអភ័យឯកសិទ្ធិ សារព័ត៌មាននោះត្រូវចាត់តាំងឲ្យមានសហនាយកការផ្សាយម្នាក់ទៀត ។

និយោជក ឬនិពន្ធនាយកដែលមិនគោរពបែបបទនេះជាមុន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីប្រាំសែនរៀល (៥០០ ០០០រៀល) ទៅមួយលានប្រាំសែនរៀល(១ ៥០០ ០០០រៀល) ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេឡើង ។

មាត្រា ៩.-

សំណុំបែបបទដែលនិយោជក ឬនិពន្ធនាយក ត្រូវបំពេញមានជាអាទិ៍ :

- អត្តសញ្ញាណប័ណ្ណនៃសារព័ត៌មាន
- ឈ្មោះ និងអាស័យដ្ឋានរបស់និយោជក ឬនិពន្ធនាយក
- ឈ្មោះ និងអាស័យដ្ឋានរបស់រោងពុម្ព
- លិខិតថ្កោលទោស

រាល់ការផ្លាស់ប្តូរព័ត៌មានខាងលើនេះ ត្រូវជូនដំណឹងទៅក្រសួងព័ត៌មានប្រាំថ្ងៃ (៥ ថ្ងៃ) មុន លើកលែងតែករណីប្រធានសក្តិ ។

មាត្រា ១០.-

ជនណាម្នាក់ដែលយល់ថាអត្ថបទណាមួយ ទោះជាសរសេរបញ្ឆិតបញ្ឆៀងក៏ដោយ រូបគំនូរ ឬរូបថតណាមួយនៃសារព័ត៌មានណាមួយដែលមានលក្ខណៈខុសពីការពិត ធ្វើឲ្យខូចខាត

ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួន មានសិទ្ធិទាមទារឲ្យសារពត៌មាននោះធ្វើការកែតម្រូវឬមានសិទ្ធិឆ្លើយតប និងធ្វើបណ្តឹងពីបទបរិហារកេរ្តិ៍ ពីបទមួលបង្កាច់ ឬពីបទជេរប្រមាថ ចំពោះការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ។ ចម្លើយកែតម្រូវ ឬឆ្លើយតបត្រូវចុះផ្សាយក្នុងរយៈពេលប្រាំពីរថ្ងៃ (៧ថ្ងៃ) យ៉ាងយូរ ឬនៅលេខបន្ទាប់ក្រោយពីបានទទួលការទាមទារឲ្យកែតម្រូវ ឬឆ្លើយតប ។

ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលអះអាងឬការទំលាក់កំហុសដែលអ្នកសារពត៌មានយកមកចុះផ្សាយដោយផ្ទាល់ឬក៏យកមកចុះផ្សាយបន្តខុសពីការពិត ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈនោះ គឺជាការមួលបង្កាច់ដែលច្បាប់ហាមឃាត់ ។

បើតុលាការរកឃើញថា ការផ្សាយណាមានលក្ខណៈខុសពីការពិតតាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឲ្យសារពត៌មាននោះ ៖

- ចុះផ្សាយនូវការកែតម្រូវ ឬ
- សងជំងឺចិត្ត ឬ
- ចុះផ្សាយនូវការកែតម្រូវផង និងបង់ប្រាក់សងជំងឺចិត្តផង ។

អត្ថបទកែតម្រូវដែលអ្នកសារពត៌មាន មានភារកិច្ចផ្សាយ ត្រូវចុះផ្សាយនៅទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នានឹងអត្ថបទដែលបានចាត់ទុកថា ជាអត្ថបទធ្វើឲ្យខូចខាតកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់គេ ។

លើសពីនេះតុលាការអាចផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ទៀតក៏បាន ។

ម្យ៉ាងទៀតក្នុងករណីដែលមានការវិនិច្ឆ័យអំពីអំពើណាមួយដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឲ្យបិទផ្សាយសេចក្តីសំរេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយឬច្រើននិងឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយទាំងអស់ដោយកំរិតត្រឹម មួយលានរៀល (១.០០០.០០០ រៀល) យ៉ាងច្រើនបំផុត ។

មាត្រា ១២.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា។

ការប្រព្រឹត្តបទល្មើសដែលមានចែងខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

បុគ្គលរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ។

គ្រប់ករណីទាំងអស់ តុលាការត្រូវពិនិត្យទៅលើទំនាក់ទំនងដោយផ្ទាល់រវាងអត្ថបទញុះញង់និងអំពើនោះ ។ អត្ថបទដែលមានចំណាស់លើសពីបីខែ (៣ ខែ) មិនអាចយកមកសំអាងក្នុងការចោទប្រកាន់បានឡើយ ។

មាត្រា ១២.-

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ ។

និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០ រៀល) ទៅដប់ប្រាំលានរៀល (១៥.០០០.០០០ រៀល) ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

ក្រសួងព័ត៌មាននិងក្រសួងមហាផ្ទៃ មានសិទ្ធិប្រមូលយកអត្ថបទល្មើសនិងសារព័ត៌មានលេខចេញផ្សាយអត្ថបទល្មើសដែលចេញផ្សាយដោយសារព័ត៌មាននោះ ។ ក្រសួងព័ត៌មាន មានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួសពីសាមសិបថ្ងៃ (៣០ថ្ងៃ) ហើយបញ្ជូនសំណុំរឿងទៅតុលាការ ។

មាត្រា ១៣ .-

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តការមិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ ។ ការផ្សាយបែបនេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ពីរលានរៀល (២ ០០០ ០០០ រៀល) ទៅ ដប់លានរៀល (១០ ០០០ ០០០ រៀល) ។

មាត្រា ១៤.-

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិជាអាទិ៍ ៖

- ពាក្យអសុរោះមិនគួរគប្បី ដូចជា អា មីង ជាដើម
- ពាក្យដែលពិពណ៌នាចំៗ អំពីសកម្មភាពរួមរក្ស
- រូបគំនូរ ឬរូបថត ដែលបង្ហាញនូវ កេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងតែទិសដៅសំរាប់អប់រំចេញ
- រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនិងសត្វតិរច្ឆាន ។

ការរំលោភទៅលើមាត្រានេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅ ប្រាំលានរៀល (៥ ០០០ ០០០ រៀល) ។

មាត្រា ១៥.-

លើកលែងតែមានការអនុញ្ញាតពីតុលាការ សារពត៌មានពុំអាចផ្សាយដំណឹង រូបថត ឬគំនូរ ដែលអាចឲ្យអ្នកអានស្គាល់ឈ្មោះ និងអត្តសញ្ញាណនៃ ៖

- ភាគីក្នុងរឿងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែងលះប្តីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ
- យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ (១៨ ឆ្នាំ) ក្នុងរឿងវិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ
- ស្ត្រីដែលទទួលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬអំពើចាប់បង្ខំសេពសន្ថវៈ ។

ក្នុងករណីដែលសាមីជន ឬអ្នកអាណាព្យាបាលយល់ព្រមជាលាយលក្ខណ៍អក្សរ សារពត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះ នាំឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។

បុគ្គលណា ដែលត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្តឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្ត ។ ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅប្រាំលានរៀល (៥ ០០០ ០០០ រៀល) ។

មាត្រា ១៦.-

ដំណឹងផ្សាយពាណិជ្ជកម្ម អាចចាត់ទុកថាមានលក្ខណៈភូតកុហក បើការផ្សាយនោះ មានន័យបំផ្លើសហួសហេតុអំពីគុណភាព ឬគុណសម្បត្តិផលិតផល ឬសេវាណាមួយ បណ្តាលឲ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីគុណភាព ឬគុណសម្បត្តិនោះ ។

ការផ្សាយពាណិជ្ជកម្មរបៀបនេះត្រូវហាមឃាត់ ប៉ុន្តែសារពត៌មានដែលចុះផ្សាយដំណឹងភូតកុហកនេះ មិនមែនជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ទេ លើកលែងតែសារពត៌មាននេះ នៅតែបន្តផ្សាយដំណឹងនេះ ក្រោយពីបានទទួលការហាមប្រាមជាលាយលក្ខណ៍អក្សរពីតុលាការ ឬពីក្រសួងមានសមត្ថកិច្ចរួចហើយ ។

ផ្ទុយទៅវិញអ្នកម្ចាស់ឃោសនាពាណិជ្ជកម្ម ជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ និងចំពោះតុលាការ បើមានការប្តឹងផ្តល់អំពីបុគ្គល ឬសមាគមអ្នកប្រើប្រាស់ណាមួយ ដែលបានទទួលការខូចខាតប្រយោជន៍បណ្តាលមកពីការផ្សាយពាណិជ្ជកម្មភូតកុហកនេះ ។

ការផ្សាយពាណិជ្ជកម្មភូតកុហក អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅ ប្រាំលានរៀល (៥ ០០០ ០០០ រៀល) ។

ដោយសារការបញ្ញាញមតិទៀត ។

មាត្រា ២៧.

បទប្បញ្ញត្តិទាំងឡាយដែលមានពីមុនមកហើយផ្ទុយនឹងស្មារតីច្បាប់នេះត្រូវ ចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជា

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហ៊ុន សែន

បានយកទៅជម្រាបជូនសម្តេច នាយករដ្ឋមន្ត្រីទី ១ និង ទី ២

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក ម៉ារ៉េត

# ច្បាប់

## ស្តីពី

## ការធ្វើបាតុកម្មដោយសន្តិវិធី

ROYAUME du CAMBODGE
LE MINISTRE du PALAIS

# ព្រះរាជក្រម

នស/រកម/១២០៩/០២៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

## ជំពូកទី ២
## នីតិវិធីនៃការជូនដំណឹងអំពីការធ្វើបាតុកម្មដោយសន្តិវិធី

**មាត្រា ៥.—**

ក្រុមបុគ្គលណា ដែលមានបំណងរៀបចំធ្វើបាតុកម្មដោយសន្តិវិធី នៅទីកន្លែងសាធារណៈណាមួយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ ។

**មាត្រា ៦.—**

លិខិតជូនដំណឹងនោះត្រូវបញ្ជាក់អំពី :

-នាមត្រកូល នាមខ្លួន និង អាសយដ្ឋានអចិន្ត្រៃយ៍ សម្រាប់ទំនាក់ទំនងរបស់អ្នកដឹកនាំចំនួនបី (៣)នាក់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងផង

-គោលបំណងនៃការធ្វើបាតុកម្មដោយសន្តិវិធី

-កាលបរិច្ឆេទ ពេលវេលា និង រយៈពេល នៃការធ្វើបាតុកម្មដោយសន្តិវិធី ទីកន្លែង និង ផ្លូវដែលត្រូវប្រើប្រាស់សម្រាប់សកម្មភាព ចំនួនអ្នកចូលរួម ព្រមទាំងចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

អ្នកដាក់លិខិតជូនដំណឹងទាំងរស់ត្រូវធានាថាគោរព ហើយអនុវត្តតាមតួនាទី និងភារកិច្ចទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ។

**មាត្រា ៧.—**

លិខិតជូនដំណឹងត្រូវដាក់នៅសាលារាជធានី ឬ សាលាខេត្ត យ៉ាងហោចណាស់ប្រាំ (៥)ថ្ងៃ នៃថ្ងៃធ្វើការងារមុនពេលកំណត់ នៃការធ្វើបាតុកម្មដោយសន្តិវិធី ។

**មាត្រា ៨.—**

នៅពេលបានទទួលលិខិតជូនដំណឹងហើយ សាលារាជធានី ឬ សាលាខេត្ត :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ច្បាប់នេះ មានគោលបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និង កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ ។

**មាត្រា ៣.–**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់ការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួនធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនអនុវត្តចំពោះ :

១-ការជួបប្រជុំ ឬ ការប្រមូលផ្តុំគ្នា ឬ ការហែក្បួនក្នុងយុទ្ធនាការឃោសនាបោះឆ្នោតណាមួយ ។

២-ការប្រមូលផ្តុំគ្នាខាងក្នុង និង ខាងក្រៅរែបប្រយរបងរោងចក្រ ឬ សហគ្រាស ឬ ស្ថាប័ននានា ពាក់ព័ន្ធនឹងវិវាទការងារ ដែលត្រូវដាក់បញ្ចូលក្នុងដែនអនុវត្តនៃច្បាប់ការងារ ។

៣-ការដើរហែក្បួនល្អហយាត្រា ដើរហែសព និងការប្រមូលផ្តុំគ្នាដទៃទៀតក្នុងគោលបំណងបម្រើសាសនា សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីជាតិ និងសកម្មភាពផ្សព្វផ្សាយអប់រំ ដើម្បីផលប្រយោជន៍សង្គម ។

**មាត្រា ៤.–**

បាតុកម្មដោយសន្តិវិធី សំដៅលើការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួន ដោយមនុស្សមួយក្រុម ដើម្បីទាមទារ តវ៉ា ឬ សម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈរបស់ [illegible]នតាំងស្ថេរភាព ឬ មធ្យោបាយផ្សេងៗដោយសន្តិវិធី ។

១-ត្រូវចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ជូនអ្នកដែលបានដាក់លិខិតជូនដំណឹង ។

២-ត្រូវផ្សព្វផ្សាយលិខិតជូនដំណឹងនេះជាបន្ទាន់ នៅទីកន្លែងណាមួយ ដែលងាយមើលឃើញ នៅក្នុងអគាររដ្ឋបាល ឬ នៅក្នុងគេហទំព័រផ្លូវការរបស់ខ្លួន ។

៣-ត្រូវបញ្ជូនច្បាប់ថតចម្លងនៃលិខិតជូនដំណឹងនេះ ទៅស្នាក់ការនគរបាលមូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និង អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានការពាក់ព័ន្ធនឹងទីកន្លែងធ្វើបាតុកម្មនោះ ។

មាត្រា ៩.-

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ:

-ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ ។

-មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ។

មាត្រា ១០.-

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវពិនិត្យ និង ធ្វើការឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរត្រឹមបី(៣)ថ្ងៃ នៃថ្ងៃការងារ ដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន ។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច ខកខានមិនបានឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី មានន័យថាអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច បានព្រមព្រៀងហើយ ។

មាត្រា ១១.-

ក្នុងករណីដែលអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ច មានព័ត៌មានច្បាស់ថា

ការធ្វើបាតុកម្មនេះ នឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធររដ្ឋធានី ឬ ខេត្ត ត្រូវធ្វើការឆ្លើយតប ដោយជូនដំណឹងជាបន្ទាន់ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ ។

**មាត្រា ១២.-**

ក្រោយពីបានពិភាក្សាគ្នាហើយ បើភាគីទាំងពីរនៅតែមិនព្រមព្រៀងគ្នាទៀតនោះ អាជ្ញាធររដ្ឋធានី ឬ ខេត្តមានសមត្ថកិច្ច ត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង ត្រូវផ្តល់ជូនដល់ម្ចាស់លិខិតជូនដំណឹងវិញ ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន(២៤)ម៉ោង មុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ។ ឯកសារថតចម្លងនៃការសម្រេច រួមទាំងព័ត៌មានលំអិត នៃការកែប្រែដែលបានព្រមព្រៀងគ្នា ត្រូវផ្តល់ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងជូនទៅអាជ្ញាធរដទៃទៀត ដែលមានតំបន់អាចនឹងទទួលរងនូវការប៉ះពាល់ ដោយសារការធ្វើបាតុកម្មដោយសន្តិវិធីនេះ ។

**មាត្រា ១៤.-**

មិនតម្រូវឱ្យមានការបញ្ជាក់ និងធានាសព្វគ្រប់ដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌទី ១ នៃច្បាប់នេះទេ ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរមានចុះហត្ថលេខា ឬ ស្នាមមេដៃ និងភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង របស់អ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ចំនួនបី(៣)នាក់ ដល់អាជ្ញាធររដ្ឋធានី ឬ ខេត្តមានសមត្ថកិច្ចនៅមូលដ្ឋាននោះ យ៉ាងហោចណាស់ឱ្យបានមុនដប់ពីរ(១២)ម៉ោងក្នុងថ្ងៃការងារ ឬ មុនសាមសិបប្រាំមួយ(៣៦)ម៉ោងក្នុងថ្ងៃឈប់សម្រាក ប្រសិនបើការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានគេធ្វើឡើងនៅតាមទីកន្លែងដូចខាងក្រោម :

១-នៅកន្លែងបញ្ចេញមតិជាសាធារណៈ ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ ឬ តាមបទបញ្ជា ហើយដែលការធ្វើបាតុកម្មដោយសន្តិវិធីនោះ មានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ សម្រាប់រាជធានី ឬ ខេត្តនីមួយៗ ឬ

២-នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬ ជាទ្រព្យសម្បត្តិសម្ហូហភាពក្នុងករណីមានការយល់ព្រមពីម្ចាស់ទ្រព្យ ឬ ពីគណៈគ្រប់គ្រង ដែលជាអ្នកមើលការខុសត្រូវលើទ្រព្យសម្បត្តិសម្ហូហភាពនោះ ហើយការធ្វើបាតុកម្មដោយសន្តិវិធីមានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ ។

ប៉ុន្តែ ក្នុងករណីដែលចំនួនក្រុមនៃការធ្វើបាតុកម្មដោយសន្តិវិធី មានចាប់ពី ពីរ(២) ក្រុមផ្សេងគ្នាឡើងទៅ ហើយចង់ធ្វើនៅកន្លែងតែមួយ និង ពេលវេលាតែមួយនោះ អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ចត្រូវសម្រេចឱ្យ ក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬ អាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀត ដែលមានចម្ងាយយ៉ាងតិច ប្រាំរយ(៥០០)ម៉ែត្រ ។

ការធ្វើបាតុកម្មដោយសន្តិវិធី ដូចមានចែងក្នុងមាត្រានេះ អាចប្រព្រឹត្តទៅបាន តែក្នុងចន្លោះពេលពីម៉ោងប្រាំមួយ(៦)ព្រឹក ដល់ម៉ោងប្រាំមួយ(៦)ល្ងាចប៉ុណ្ណោះ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់
## អ្នកដឹកនាំធ្វើបាតុកម្ម និង អាជ្ញាធរមានសមត្ថកិច្ច

មាត្រា ១៥.-

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលបានទទួលការព្រមព្រៀង មានការហែក្បួនលើផ្លូវសាធារណៈ អាជ្ញាធរដែនដីឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានី ឬ មន្ត្រីដែលត្រូវបានចាត់តាំងជាតំណាង ត្រូវសហការជាមួយនគរបាលមូលដ្ឋាន និង កងរាជអាវុធហត្ថ ដើម្បីទប់ស្កាត់ផលអាក្រក់ដែលនឹងអាចកើតមាន ដោយធ្វើការកំណត់ផ្លូវខាងលើឱ្យមានភាពងាយស្រួល និង សម្រួលចរាចរណ៍សម្រាប់យានយន្ត ដើម្បីកុំឱ្យមានការរំខានធ្ងន់ធ្ងរ ដល់ដំណើរការអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឬ ជំនួញផ្សេងៗ ។

**មាត្រា ១៦.-**

អ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ត្រូវទទួលខុសត្រូវក្នុងការចាត់វិធានការសមស្រប ដើម្បីរក្សាឱ្យបានថា ការធ្វើបាតុកម្មនេះ នឹងប្រព្រឹត្តទៅដោយសន្តិវិធី និង តាមលក្ខខណ្ឌ ដូចខាងក្រោម :

១-ជូនដំណឹងដល់អ្នកចូលរួមអំពីការទទួលខុសត្រូវរបស់ខ្លួន ដូចមានចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

២-ពិភាក្សា និង សហការជាមួយមន្ត្រីមូលដ្ឋាន និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ដើម្បីធានាឱ្យការធ្វើបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធី ។

៣-រក្សាសណ្តាប់ធ្នាប់របៀបរៀបរយឱ្យបានល្អ និង ត្រឹមត្រូវតាមពេលវេលា និង ទីកន្លែងកំណត់ គិតពីការចាប់ផ្តើមរហូតដល់ការបញ្ចប់ទៅវិញ នៃការធ្វើបាតុកម្មដោយសន្តិវិធី ។

**មាត្រា ១៧.-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការការពារដល់ក្បួនបាតុកម្មដោយសន្តិវិធី ដើម្បីធានារក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អប្រសើរ ហើយមិនត្រូវជ្រៀតជ្រែកដល់ការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធីឡើយ ។

**មាត្រា ១៨.-**

នៅពេលមានការស្នើសុំជំនួយពីអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរមានសមត្ថកិច្ច ត្រូវខិតខំឆ្លើយតបដោយយកចិត្តទុកដាក់នូវសំណូមពរសមស្រប ដោយផ្អែកលើមូលដ្ឋានច្បាប់ ដើម្បីធានាដល់ការអនុវត្តសិទ្ធិសេរីភាពធ្វើបាតុកម្មដោយសន្តិវិធី និង ការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈប្រកបដោយភាពថ្លៃថ្នូរ ។

**មាត្រា ១៩.-**

អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានចាត់តាំងឱ្យរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ នៅកន្លែងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះ និង អត្តលេខសម្គាល់ខ្លួន បង្ហាញនៅផ្នែកខាងមុខ និងត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតអត់ធ្មត់ជាដាច់ខាត ។

មាត្រា ២០.-

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលមានការព្រមព្រៀង រាប់ទាំងការព្រមព្រៀង ដោយអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមិនបានឆ្លើយតបដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះផង មិនត្រូវបានបំបែកទេ ។

ក្នុងករណីបាតុកម្មដោយសន្តិវិធី បានក្លាយជាអំពើហិង្សា អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និង បញ្ឈប់បាតុកម្មនេះជាបន្ទាន់ ។

ទោះបីជាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ ប៉ុន្តែបើមិនបានដាក់លិខិតជូនដំណឹងស្របតាមមាត្រា ៥ មាត្រា ៦ និង មាត្រា ១៤ នៃច្បាប់នេះ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់វិធានការបញ្ឈប់បាតុកម្មនេះបាន ។

## ជំពូកទី ៤

## នីតិវិធីដោះស្រាយបទល្មើស និង ទោសប្បញ្ញត្តិ

មាត្រា ២១.-

ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ មាត្រា ១៦ និង មាត្រា ២០ កថាខណ្ឌទី ២ និង ទី ៣ នៃច្បាប់នេះ ។

មាត្រា ២២.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះមន្ត្រីអាជ្ញាធរដែនដី ឬ មន្ត្រីអាជ្ញាធរមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ និង មាត្រា ២០ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃច្បាប់នេះ ។

មាត្រា ២៣.-

ក្នុងករណីបាតុករណាមានកាន់ឧបករណ៍ ដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ ឬ [illegible] ប្រព្រឹត្តអំពើណាមួយដែលជាការរំលោភបំពានសិទ្ធិសេរីភាព ឬ ធ្វើទុក្ខទោសដល់អ្នកដទៃ ឬ ប្រព្រឹត្តអំពើណាមួយដែលជាការជ្រៀតជ្រែកសិទ្ធិសេរីភាពឬ ធ្វើទុក្ខទោសដល់អ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតឧបករណ៍ទាំងនោះចេញ ឬ ហាមប្រាមកុំ [illegible] ប្រព្រឹត្តអំពើនេះទៀត ។ ប្រសិនបើជននោះមានការរឹងរូសមិនព្រមប្រគល់

ឱ្យ ឬ មិនព្រមឈប់ប្រព្រឹត្តអំពើនេះ សមត្ថកិច្ចត្រូវធ្វើការឃាត់ខ្លួនជាបណ្តោះអាសន្នរហូតដល់បាតុកម្មដោយសន្តិវិធីត្រូវបានបញ្ចប់សព្វគ្រប់ ទើបធ្វើការដោះលែងវិញ លើកលែងតែមានបទល្មើសអ្វីផ្សេងទៀត ។

## មាត្រា ២៤.-

ក្នុងករណីបាតុករណាមានកាន់អាវុធ ឬ ជាតិផ្ទុះ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតអាវុធ ឬ ជាតិផ្ទុះទាំងនោះ និងធ្វើការឃាត់ខ្លួន រួចហើយបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ។

## មាត្រា ២៥.-

ជនណាឆ្លៀតឱកាសក្នុងពេលធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីប្រព្រឹត្តអំពើលួច ប្លន់ ឬ បណ្តាលឱ្យអន្តរាយទ្រព្យសម្បត្តិឯកជន ឬ ទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## មាត្រា ២៦.-

ប្រសិនបើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធីបង្កជាអំពើហិង្សាបណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិឯកជនក្តី ឬ ទ្រព្យសម្បត្តិសាធារណៈក្តី ការជួសជុលការខូចខាតត្រូវជាបន្ទុករបស់ជនល្មើស និង អ្នកសមគំនិត ។

ក្នុងករណីអ្នកទាំងនោះមិនមានលទ្ធភាពធ្វើការជួសជុលការខូចខាត អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្កសំណុំរឿងបញ្ជូនទៅតុលាការ ។

## មាត្រា ២៧.-

បើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធី បង្កជាអំពើហិង្សា ជនណាដែលបានប្រព្រឹត្តល្មើសបណ្តាលឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ បាតុករ ឬ បុគ្គលដទៃទៀត មានរបួសស្នាម ឬ បណ្តាលឱ្យស្លាប់ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី៥

អន្តរប្បញ្ញត្តិ

មាត្រា ២៨.-

ក្នុងរយៈពេលប្រាំមួយ(៦)ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជធានី និង ខេត្ត នីមួយៗត្រូវបង្កើត "កន្លែងបញ្ចេញមតិជាសាធារណៈ" ដោយត្រូវជ្រើសរើសទីធ្លា ឬ មណ្ឌល សមស្របមួយកន្លែងដែលមនុស្សទូទៅងាយស្ដាប់ឮ និង មើលឃើញ នៅក្នុងទឹកដីនៃដែន សមត្ថកិច្ចរបស់ខ្លួន សម្រាប់ធ្វើបាតុកម្មដោយសន្តិវិធី ឬ បញ្ចេញមតិជាសាធារណៈ ដូច មានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា ២៩.-

ច្បាប់ស្ដីពីបាតុកម្ម ដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ១១៥ក្រ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩១ និងបទប្បញ្ញត្តិ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣០.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

[illegible] ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខៈ១០៦៧ ច.ល
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩



**BY YEMSRACH YETNEBERK**

# Cartoons

**FOR FREEDOM OF EXPRESSION**

WORLD PRESS FREEDOM DAY 2019



BY ZOHORE

Cartoons
FOR FREEDOM OF EXPRESSION
WORLD PRESS FREEDOM DAY 2019




**BY SHERIF ARAFA**

# Cartoons

**FOR FREEDOM OF EXPRESSION**

WORLD PRESS FREEDOM DAY 2019



**BY OSAMA HAJJAJ**

# Cartoons
## FOR FREEDOM OF EXPRESSION
WORLD PRESS FREEDOM DAY 2019



**BY KAZANEVSKY**

# Cartoons

**FOR FREEDOM OF EXPRESSION**

WORLD PRESS FREEDOM DAY 2019




Cartoons
FOR FREEDOM OF EXPRESSION
WORLD PRESS FREEDOM DAY 2019


យើងត្រូវការសេរីភាពលើប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា
You Tube



SAY NO ! UNION, ASSOCIATIO
D LAWS
SAY
NO




**BY RAYMA**

# Cartoons
**FOR FREEDOM OF EXPRESSION**
WORLD PRESS FREEDOM DAY 2019